# ព្រឹត្តិបត្រមេធាវី

## លេខ ២១

## ខែ មេសា-មិថុនា ឆ្នាំ ២០១៩

រក្សាសិទ្ធិ © 2019 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនបញ្ជាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

ស្របតាមគោលការណ៍សេរីភាពនៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

សូមរក្សាសិទ្ធិ © ដោយអនុលោមតាមច្បាប់ស្តីពី “សិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែល” ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ហើយរាល់ការថតចម្លងឡើងវិញ ដោយគ្មានការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់។

ទំព័រ

# មាតិកា

**សារពីប្រធានគណៈមេធាវី** ........ III

**រដ្ឋប្បវេណី**

**អចលនវត្ថុ និងផលុបភោគក្រោមក្រមរដ្ឋប្បវេណី** ........ 1

១. សេចក្តីផ្តើម ........ 1

២. អចលនវត្ថុ ........ 1

២.១ និយមន័យទូទៅ ........ 1

២.២ គោលការណ៍សមាសភាគនៃវត្ថុ ........ 2

២.៣ ករណីលើកលែងចំពោះគោលការណ៍សមាសភាគ ........ 4

៣. ផលុបភោគ ........ 8

៣.១ គោលគំនិតទូទៅ ........ 8

៣.២ សិទ្ធិចេញពីផលុបភោគ ........ 8

៣.៣ ការបង្កើតផលុបភោគ ........ 10

៣.៤ កម្មវត្ថុនៃផលុបភោគ ........ 11

៣.៥ តម្លៃថ្នូរ ........ 13

៤. សេចក្តីសន្និដ្ឋាន ........ 16

**ច្បាប់អន្តរជាតិ**

**តើគ្រប់កិច្ចព្រមព្រៀងទាំងអស់ត្រូវឆ្លងការអនុម័តយល់ព្រមពីសភា ដើម្បីឲ្យកម្ពុជាអាចក្លាយជាភាគីឬ?** ........ 21

១. សេចក្តីផ្តើម ..................................................................................21

២. ខ្លឹមសារ..........................................................................................21

២.១. ការអនុវត្តជាអន្តរជាតិ ......................................................................21

២.២. ករណីកម្ពុជា ..................................................................................25

៣. សង្ខេប..............................................................................................27

## ការជំនុំជម្រះក្តីដោយយុត្តិធម៌

**សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា**........................31

១. សេចក្តីផ្តើម ..................................................................................31

២.សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងកាតព្វកិច្ចរបស់កម្ពុជា ..................................................................33

៣. ការអនុវត្តស្តង់ដារជំនុំជម្រះដោយយុត្តិធម៌នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ ..........36

៣.១ សិទ្ធិបុរេជំនុំជម្រះ ..........................................................................37

៣.២ សិទ្ធិនៅពេលជំនុំជម្រះ ....................................................................43

៣.៣ សិទ្ធិក្រោយការជំនុំជម្រះ ..................................................................58

៤. សេចក្តីបញ្ចប់ ..................................................................................64

## សកម្មភាពរបស់គណៈមេធាវី

**១.ទំនាក់ទំនងជាតិ និងអន្តរជាតិ**.........................................................69

១.១.ទំនាក់ទំនងជាតិ..............................................................................69

១.២.ទំនាក់ទំនងអន្តរជាតិ ........................................................................73

**២.សកម្មភាពបុណ្យចូលឆ្នាំខ្មែរ**..............................................................77

**៣.កិច្ចប្រជុំប្រចាំខែ** ...........................................................................79

# សារពីប្រធានគណៈមេធាវី




គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជាមានកិត្តិយស សូមបោះពុម្ពបន្តនូវ ព្រឹត្តិបត្រមេធាវីលេខ ២១ សម្រាប់ត្រីមាសទី២ ខែមេសា-មិថុនា ឆ្នាំ២០១៩។ ព្រឹត្តិបត្រមេធាវីនេះ បានសម្រេចឡើងដោយ ការប្រឹងប្រែង លះបង់ពេលវេលាដ៏មានតម្លៃ របស់អ្នកនិពន្ធនីមួយៗ ដើម្បីចែករំលែក ចំណេះដឹង និងបទពិសោធន៍របស់គាត់។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់ អ្នកនិពន្ធដែលបានរួមចំណែក វិភាគទានអត្ថបទរបស់ខ្លួន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរង ប្រធាន បុគ្គលិក និងអ្នកស្ម័គ្រចិត្តនៃនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវីដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានា ដូចជា រដ្ឋប្បវេណី ច្បាប់អន្តរជាតិ និងសិទ្ធិទទួលបាននូវយុត្តិធម៌ ជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពី សកម្មភាពនៃគណៈមេធាវី ដើម្បីឲ្យសហភាតាជាមេធាវីបានជ្រាបពីកិច្ចដំណើរការនៃគណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី ២ "ពង្រឹងនិងការពារវិជ្ជាជីវៈ"** នៃ**ផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មានអ្នកជំនាញខាងច្បាប់ជាច្រើន ដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើ

សេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់មេធាវី និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។ គណៈមេធាវីស្វាគមន៍ជានិច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមរយៈលោកមេធាវី **កុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh ឬលោកមេធាវី **កែ ប៊ុនធឿន** តាមអ៊ីម៉ែល bunthoeurn@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!

ថ្ងៃសុក្រ ១១រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ២០១៩

**សួន វិសាល**

ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា

# រដ្ឋប្បវេណី

# អចលនវត្ថុ និងផលុបភោគក្រោមក្រមរដ្ឋប្បវេណី

ដោយ រ៉ា សុផាន់ណារិទ្ធ*

## ១. សេចក្តីផ្តើម

មានសិទ្ធិច្រើនប្រភេទដែលច្បាប់បានបង្កើតឲ្យមាន ឬអាចទទួលបានលើ ឬចេញពីអចលនវត្ថុ ដូចជា កម្មសិទ្ធិ សិទ្ធិកាន់កាប់ សិទ្ធិជួលអចិន្ត្រៃយ៍ ភតិសន្យា ផលុបភោគ សេវភាព សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ សិទ្ធិដែលត្រូវបានបង្កើតឡើងដោយសម្បទានដីធ្លី ព្រមទាំងសិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ប្រាតិភោគដោយអនុប្បទានជាដើម។ អត្ថបទនេះនឹងសិក្សាសង្ខេបអំពីនិយមន័យទូទៅនៃអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុមួយ គឺផលុបភោគ។

## ២. អចលនវត្ថុ

### ២.១ និយមន័យទូទៅ

អចលនវត្ថុត្រូវបានគេស្គាល់ក្រោមច្បាប់ជាមូលដ្ឋាន ថាជាដីធ្លី និងវត្ថុជាប់នៅលើដីដែលមិនអាចផ្លាស់ទីបាន។ ជាក់ស្តែង ដីធ្លី គឺជាសារធាតុគោលចម្បងនៃអចលនវត្ថុ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងជាគោលអំពីក្របខណ្ឌគតិយុត្តមួយផ្នែក នៃអចលនវត្ថុដោយសំដៅលើដីធ្លី៖ សិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី នៃរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ[1]។ ក្រមរដ្ឋប្បវេណីឆ្នាំ២០១១[2] ច្បាប់ភូមិបាល[3] និងច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗ បានផ្តល់អត្ថន័យលម្អិតបន្ថែមអំពី អចលនវត្ថុ។

---

* លោក រ៉ា សុផាន់ណារិទ្ធ គឺជាប្រធានផ្នែកកិច្ចការច្បាប់ នៃក្រុមហ៊ុនឯកជន នៅរាជធានីភ្នំពេញ

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៤ កថាខណ្ឌទី១

[2] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ (តទៅក្នុងអត្ថបទនេះ ត្រូវហៅថា "ក្រមរដ្ឋប្បវេណីឆ្នាំ ២០១១")

[3] ច្បាប់ភូមិបាល ដែលត្រូវបានប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ (តទៅក្នុងអត្ថបទនេះ ត្រូវហៅថា "ច្បាប់ភូមិបាល")

**កំណត់សម្គាល់៖** រាល់មាត្រាដែលបានដកស្រង់នៅក្នុងអត្ថបទនេះ គឺសំដៅទៅលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លើកលែងតែមានការកំណត់ផ្ទុយពីនេះ។ ចំពោះមាត្រាដែលដកស្រង់ដែលពាក់ព័ន្ធនឹងច្បាប់ភូមិបាលគឺសំដៅទៅលើច្បាប់ភូមិបាលឆ្នាំ២០០១ លើកលែងតែមានកំណត់ផ្សេង។

តាមក្រមរដ្ឋប្បវេណី[4] អចលនវត្ថុសំដៅទៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍។ លក្ខខណ្ឌសំខាន់នៃវត្ថុជាប់នឹងដីដែលត្រូវបានចាត់ទុកជាផ្នែកនៃដី (សមាសភាគនៃដី) គឺ "...មិនអាចផ្លាស់ប្តូរទីកន្លែងបាន"។ តាមគោលការណ៍សមាសភាគនៃដីក្រោមក្រមរដ្ឋប្បវេណី[5] វត្ថុដែលនៅជាប់នឹងដី (ពិសេស អគារ ឬសំណង់សាងសង់លើដី) ហើយមិនអាចប្តូរកន្លែងបាន គឺជាសមាសភាគនៃដី ប្រសិនបើវត្ថុដែលជាប់នឹងដីនោះមិនបំបែកពីដី (ជាប់នៅលើដីផ្ទាល់) ហើយមិនអាចក្លាយជាកម្មវត្ថុ នៃសិទ្ធិឯករាជ្យបាន[6] (សូមមើលបន្តផ្នែក ២.២ ខាងក្រោម សម្រាប់ចំណុចនេះ)។ នេះដូចគ្នាដែរ សម្រាប់ពូជសាបនៅលើដី ដំណាំដែលបានដាំ និងរុក្ខជាតិដែលរស់នៅលើដី។

## ២.២ គោលការណ៍សមាសភាគនៃវត្ថុ

តាមរយៈការលើកឡើងខាងលើ លក្ខខណ្ឌសំខាន់មួយទៀត សម្រាប់វត្ថុជាប់នឹងដី ដែលត្រូវបានចាត់ទុកជាផ្នែកនៃដី (សមាសភាគនៃដី) គឺ "...មិនអាចក្លាយជាកម្មវត្ថុ នៃសិទ្ធិឯករាជ្យបាន"។ សំណួរសួរថាតើក្នុងករណីណាដែលវត្ថុមួយមិនអាចក្លាយជាកម្មវត្ថុ នៃសិទ្ធិឯករាជ្យបាន? តាមគោលការណ៍ទូទៅនៃសមាសភាគវត្ថុក្នុងក្រមរដ្ឋប្បវេណី[7] ភាគនៃវត្ថុមួយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបាន (ពោលគឺមិនអាចបំបែកចេញតែឯងពីវត្ថុចម្បងបាន ហើយត្រូវស្ថិតនៅក្រោមរាល់សិទ្ធិទាំងឡាយដែលវត្ថុចម្បងស្ថិតក្រោម) ប្រសិនបើការបែងចែក ឬបំបែកភាគនោះ នឹងធ្វើឲ្យវត្ថុចម្បងត្រូវបំបែក (ខូចសភាពដើម) ឬផ្លាស់ប្តូរលក្ខណៈដើម។ តាម

[4] មាត្រា ១២០ កថាខណ្ឌទី ២

[5] មាត្រា ១២២

[6] មានករណីលើកលែងចែងដោយច្បាប់ដែលយើងនឹងពិភាក្សាក្នុងផ្នែកបន្តបន្ទាប់ខាងក្រោម។

[7] មាត្រា ១២១ ថ្មី ក្រមរដ្ឋប្បវេណី (មាត្រា ១២១ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១ ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ (តទៅក្នុងអត្ថបទនេះ ត្រូវហៅថា "ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី") ។

ទស្សនៈមួយចំនួន[8] ការបំបែកវត្ថុ គឺមិនត្រឹមតែជាការបែកបាក់ខាងក្រៅប៉ុណ្ណោះទេ តែមានទាំងសកម្មភាពទាំងឡាយ (មិនចាំបាច់ទាល់តែបែកបាក់) ដែលធ្វើឲ្យខូចខ្លាំងនូវតម្លៃនៃវត្ថុទាំងមូល ឬធ្វើឲ្យបាត់បង់នូវគោលបំណងដើមនៃការប្រើប្រាស់វត្ថុនោះ (ឧទាហរណ៍ ប្រែវាលស្រែ ទៅជាវាលរ៉ែ)។

ចំពោះអគារវិញ វត្ថុធាតុភ្ជាប់នឹងអគារ ដូចជា គ្រឿងអគារ គ្រឿងសង្ហារឹម ស្លាក វត្ថុតុបតែង ជាអាទិ៍ នឹងក្លាយជាសមាសភាគនៃអគារ ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបាន ប្រសិនបើវត្ថុធាតុទាំងនោះមិនអាចបែងចែកបាន ដោយមិនបំបែកអគារ ឬដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះ[9]។ ត្រង់នេះ គេសង្កេតឃើញថា មានលក្ខណៈខុសពីសមាសភាគនៃវត្ថុក្រោមមាត្រា១២១ថ្មី នៃក្រមរដ្ឋប្បវេណី ត្រង់ថា មាត្រា១២១ថ្មី ផ្តោតលើ ភាពមិនបំបែកនៃវត្ថុចម្បង ឬមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុចម្បង[10] ខណៈដែលមាត្រា១២៥ (អំពីសមាសភាគនៃអគារ) ហាក់ចែងទៅលើ ភាពមិនបំបែកនៃវត្ថុចម្បង (អគារ) ឬភាពមិនប្តូរលក្ខណៈដើមនៃវត្ថុធាតុដែលជាសមាសភាគ (គ្រឿងអគារ ស្លាក វត្ថុតុបតែង ជាអាទិ៍)។ ក្រមរដ្ឋប្បវេណីផ្តល់វិសាលភាពទូលំទូលាយបន្តិចទាក់ទងនឹងអ្វីដែលអាចក្លាយជាសមាសភាគនៃអគារ។ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់វិញ[11] ផ្នែកនៃអគាររាប់បញ្ចូលតែវត្ថុដែលត្រូវប្រើសម្រាប់សាងសង់អគារផងដែរ។

---

[8] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីរៀបចំដោយ គណៈកម្មាធិការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី បោះផ្សាយដោយក្រសួងយុត្តិធម៌ ភ្នំពេញ ២០០៩ (តទៅក្នុងអត្ថបទនេះ ត្រូវហៅថា «សេចក្តីកំណត់ចំពោះមាត្រា [...] នៃក្រមរដ្ឋប្បវេណី»), សេចក្តីកំណត់ចំពោះមាត្រា១២១ នៃក្រមរដ្ឋប្បវេណី។

[9] មាត្រា ១២៥

[10] គួរកត់សម្គាល់ថា មាត្រា ៨១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានធ្វើវិសោធនកម្ម មាត្រា ១២១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១ នៃឃ្លា "លក្ខណៈដើមនៃសមាសភាគនោះ" ទៅជា "លក្ខណៈដើមនៃវត្ថុនោះ" ពោលគឺ គោលការណ៍សមាសភាគ នៃមាត្រា ១២១ មុនវិសោធនកម្មសំដៅដល់ ភាពមិនអាចបំបែកបាននៃវត្ថុចម្បង និង ភាពមិនផ្លាស់ប្តូរលក្ខណៈដើមនៃសមាសភាគដែលចង់បំបែក។

[11] ត្រង់មាត្រា ៩៤ កថាខណ្ឌទី ២។ (សូមបញ្ជាក់ថា សំណៅយោងដល់ច្បាប់បរទេសទាំងឡាយ ក្នុងអត្ថបទនេះ គឺយោងទៅលើអត្ថបទបកប្រែជាភាសាអង់គ្លេស ចេញពីអត្ថបទច្បាប់ភាសាដើមនៃប្រទេសនីមួយៗ ដែលនេះអាចនឹងមានអសង្គតភាពតូចតាចពីភាសាដើមខ្លះ)។

## ២.៣ ករណីលើកលែងចំពោះគោលការណ៍សមាសភាគ[12]

លើកលែងចំពោះគោលការណ៍សមាសភាគខាងលើ ប្រសិនបើអគារ ឬសំណង់ ឬ រុក្ខជាតិ ឬដំណាំដែលបានដាំដែលជាការអនុវត្តសិទ្ធិចំពោះដីអ្នកដទៃ (ឧទាហរណ៍ សិទ្ធិជួល អចិន្ត្រៃយ៍ ឬផលុបភោគ ជាដើម)។ ក្នុងករណីនេះ អគារ សំណង់ រុក្ខជាតិ ឬដំណាំ មិនត្រូវក្លាយជាកម្មសិទ្ធិរបស់ម្ចាស់ដី តែត្រូវចាត់ទុកជាសមាសភាគនៃសិទ្ធិលើដីរបស់ម្ចាស់សិទ្ធិ។ ម្ចាស់សិទ្ធិគឺជាកម្មសិទ្ធិករលើអគារ ឬសំណង់ជាអាទិ៍ ក្នុងវិសាលភាពនៃសិទ្ធិដែលខ្លួនមានលើដី។ ដូច្នេះ ប្រសិនបើសិទ្ធិលើដីផុតរលត់ កម្មសិទ្ធិលើអគារ ឬសំណង់ជាអាទិ៍ ក៏នឹងត្រូវរលត់ដែរ។ ជាមួយគ្នានេះ វត្ថុដែលត្រូវបានភ្ជាប់ជាមួយដី ក្នុងគោលបំណងបណ្ដោះអាសន្ន ក៏មិនត្រូវក្លាយជាសមាសភាគនៃដី។ គេអាចបង្កើតកម្មសិទ្ធិលើវត្ថុនោះ ក្នុងនាមជាកម្មសិទ្ធិលើចលនវត្ថុ។

### ២.៣.១ វត្ថុចម្បង និង វត្ថុចំណុះ

តាមគោលការណ៍សមាសភាគខាងលើ ឃើញថា សិទ្ធិតែមួយត្រូវមានវិសាលភាពលើវត្ថុមួយ ព្រមទាំងសមាសភាគនៃវត្ថុនោះ។ តែក្រមរដ្ឋប្បវេណីក៏បានអនុញ្ញាតឲ្យវត្ថុពីរ ដែលឯករាជ្យដាច់ចេញពីគ្នា (វត្ថុមួយមិនមែនជាសមាសភាគនៃវត្ថុមួយទៀត) អាចស្ថិតនៅក្រោមសិទ្ធិជាក់លាក់តែមួយបាន តាមរយៈរូបភាព វត្ថុចម្បង និងវត្ថុចំណុះ[13]។ វត្ថុចំណុះ គឺជាវត្ថុមួយដែលមិនមែនជាសមាសភាគនៃវត្ថុមួយទៀត តែកម្មសិទ្ធិករនៃវត្ថុចម្បងបានភ្ជាប់វត្ថុនោះទៅនឹងវត្ថុចម្បង សម្រាប់គោលបំណងសេដ្ឋកិច្ចនៃវត្ថុចម្បង[14]។ ក្នុងទំនាក់ទំនងសេដ្ឋកិច្ចជាក់ស្ដែងជាច្រើន គេមិនត្រឹមតែចាត់ចែងសិទ្ធិ (ជាពិសេស ផ្ទេរសិទ្ធិ) ទៅលើតែសំបកផ្ទះ ឬអគារទទេនោះទេ គឺអាចមានវត្ថុដាច់ដោយឡែកផ្សេងៗទៀត (ពិសេសគ្រឿងសង្ហារិម ឬគ្រឿងបន្ថែមដែលអាចដកចេញចូលបាន ដូចជា តុ ទូ កៅអី) បូករួមជាមួយនឹងផ្ទះ អគារ។ ទាំងនេះគឺជាវត្ថុឯករាជ្យដែលត្រូវបានដាក់រួមជាមួយវត្ថុឯករាជ្យមួយទៀត ក្នុងគោលបំណងសេដ្ឋកិច្ចណាមួយ (ឧទាហរណ៍ បង្កើនតម្លៃផ្ទះ អគារ) តាមរយៈនៃការបង្កើត និងផ្ទេរសិទ្ធិតែមួយ (មិនចាំបាច់នៅដោយឡែកពីគ្នា ហើយផ្ទេរសិទ្ធិច្រើនដង)។

ក្នុងក្រមរដ្ឋប្បវេណី តាមរយៈការភ្ជាប់ខាងលើ ការបង្កើត និងការផ្ទេរកម្មសិទ្ធិចំពោះវត្ថុចម្បង ត្រូវមានអានុភាពទៅលើវត្ថុចំណុះដែរ លើកលែងតែមានការសន្យាពិសេស[15]។ ការភ្ជាប់៖

---

[12] មាត្រា ១២៣ និង ១២៤

[13] មាត្រា ១២៦

[14] មាត្រា ១២៦ កថាខណ្ឌទី ១

[15] មាត្រា ១២៦ កថាខណ្ឌទី ២

តើ *ការភ្ជាប់* រវាងវត្ថុទាំងពីរខាងលើ សំដៅទៅលើការភ្ជាប់ដូចម្តេចខ្លះ? គេអាចនិយាយថា តុកៅអី ត្រូវបានភ្ជាប់នឹងផ្ទះជាប្រយោល ឬតាមការប្រើប្រាស់ (ដាក់តាំងក្នុងផ្ទះ ប្តូរកន្លែងពេលណាក៏បាន) រាំងនន ត្រូវបានភ្ជាប់នឹងផ្ទះដោយផ្ទាល់ (ចាក់ចងភ្ជាប់នឹងជញ្ជាំងផ្ទះផ្ទាល់)។

ចំណុចខុសគ្នាសំខាន់មួយ រវាងទស្សនៈនៃ វត្ថុចម្បង និងវត្ថុចំណុះ និងគោលការណ៍សមាសភាគវត្ថុ គឺត្រង់ថា វត្ថុមួយ និងសមាសភាគរបស់វត្ថុនោះ ត្រូវបានកំណត់ក្រោមលក្ខខណ្ឌច្បាប់ ថាត្រូវតែស្ថិតក្រោមសិទ្ធិតែមួយមិនអាចបំបែកបាន។ ម្ចាស់វត្ថុមិនអាចបង្កើតកិច្ចសន្យាពិសេស ឬបំបែកវត្ថុ និងសមាសភាគវត្ថុខុសពីលក្ខខណ្ឌច្បាប់។ ឧទាហរណ៍ មិនអាចដកទ្វារទុក ហើយលក់តែសំបកផ្ទះ ដោយហេតុថា ទ្វារគឺជាសមាសភាគមួយនៃផ្ទះដែលមិនអាចបំបែកបាន ឬលក់អគារមួយ តែប្រមូលទុកស្លាកសញ្ញាចរាចរណ៍ពីទីតាំងចំណតក្នុងអគារ (ស្លាកសញ្ញាទាំងនេះ បើទោះជាចល័ត មិនជាប់នឹងអគារ គឺជាផ្នែកសំខាន់មួយសម្រាប់ទីតាំងចំណតអគារដែលបើដកចេញនឹងប៉ះពាល់ដល់លក្ខណៈដើមនៃទីតាំងចំណត ព្រោះគ្មានសញ្ញាសម្គាល់។ ដោយឡែក ថ្វីត្បិតវត្ថុចម្បង និងវត្ថុចំណុះត្រូវស្ថិតក្រោមការបង្កើត និងការផ្ទេរសិទ្ធិតែមួយ ប៉ុន្តែច្បាប់អនុញ្ញាតឲ្យកម្មសិទ្ធិករអាចបង្កើតការសន្យាពិសេសខុសពីនេះបាន។ ឧទាហរណ៍ ម្ចាស់ផ្ទះម្នាក់ទិញផ្ទះដែលមានតុកៅអីមកជាមួយ (ម្ចាស់ផ្ទះមុន ភ្ជាប់តុកៅអីជាមួយនឹងផ្ទះហើយលក់) ហើយម្ចាស់ផ្ទះក្រោយ លក់បន្តតែផ្ទះ ដោយដកតុកៅអីទុកមិនលក់។

### ២.៣.២ ប្រភេទអចលនវត្ថុក្រោមច្បាប់ភូមិបាល

ច្បាប់ភូមិបាលមិនបានផ្តល់និយមន័យនៃអចលនវត្ថុពិស្តារដូចក្រមរដ្ឋប្បវេណី ប៉ុន្តែបានចែង និងផ្តល់គោលគំនិតផ្នែកច្បាប់សំខាន់មួយចំនួនអំពីប្រភេទនៃអចលនវត្ថុ។ ក្រោមច្បាប់ភូមិបាល អចលនវត្ថុត្រូវបានចែកជាបីប្រភេទ៖ អចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា និងអចលនវត្ថុតាមការកំណត់របស់ច្បាប់[16]។ ទោះបីក្រមរដ្ឋប្បវេណីមិនបានចែងជាក់លាក់ដូចច្បាប់ភូមិបាលក្នុងករណីនេះ តែតាមពិតប្រភេទនៃអចលនវត្ថុទាំងបីខាងលើ ត្រូវបានបង្កប់ព្រមទាំងចែងលម្អិតក្នុងក្រមរដ្ឋប្បវេណីដែរ។

### ក. អចលនវត្ថុពីកំណើត

ច្បាប់ភូមិបាលកំណត់អចលវត្ថុពីកំណើត មានដូចជា ដីព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិនអាចដាំដុះ ដីលិចទឹកដោយទឹកនៅនឹង ឬទឹកហូរ និងសំណង់ ឬការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាច

[16] មាត្រា ២ ច្បាប់ភូមិបាល

រំកិល ឬផ្លាស់ប្តូរកន្លែងបាន[17]។ ច្បាប់ភូមិបាលចែងអំពីដីធ្លីច្រើនប្រភេទ ខណៈក្រមរដ្ឋប្បវេណីចែងអំពី ដីធ្លីជាទូទៅ (ស្រដៀងគ្នានឹងក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ជប៉ុន និងបារាំង)។ លក្ខខណ្ឌនៃសំណង់ស្ថិតជាប់ដីមិនអាចផ្លាស់ប្តូរកន្លែងបាន មានលក្ខណៈស្របនឹងនិយមន័យមួយផ្នែកនៃអចលនវត្ថុ ក្រោមមាត្រា១២០ និងគោលការណ៍សមាសភាគនៃដី ក្រោមមាត្រា១២២ នៃក្រមរដ្ឋប្បវេណី ដែលបានពិភាក្សាខាងលើ។ ចំពោះសំណង់ ការផ្លាស់ប្តូរណាមួយនៃសំណង់ចេញពីដីមិនអាចចាត់ទុកជាការប្រើប្រាស់តាមសភាពធម្មជាតិរបស់វានោះទេ ព្រោះសំណង់ និង ដី ស្ថិតនៅជាប់គ្នា បើកាលណាមានការផ្ទេរ គឺត្រូវផ្ទេរទាំងអស់តែម្តង ដោយអាស្រ័យនឹងភាពជាអចិន្ត្រៃយ៍នៃសំណង់ដែលបានបង្កើតឡើងដោយអំពើរបស់មនុស្សដែលភ្ជាប់ទៅនឹងដី[18]។

### ខ. អចលនវត្ថុពីភ័ព្វវាសនា

អចលនវត្ថុពីភ័ព្វវាសនាមានវត្ថុដែលជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបំបែកចេញបានដោយ មិនធ្វើឲ្យមានការខូចខាត ឬមិនដូរសភាពដើម ដូចជាដើមឈើ ឧបករណ៍តែងលំអរជាដើម[19]។ អត្ថន័យនេះស្រដៀងគ្នានឹងគោលការណ៍សមាសភាគ នៃក្រមរដ្ឋប្បវេណីដែរ ពោលគឺវត្ថុដែលមិនអាចបំបែកចេញបាន ដោយមិនធ្វើឲ្យមានការខូចខាត ឬមិនដូរសភាពដើម នៃដី ឬវត្ថុនោះ ត្រូវចាត់ទុកជាសមាសភាគនៃដី ក្រោមរូបភាពជាអចលនវត្ថុពីភ័ព្វវាសនា។ ត្រង់នេះច្បាប់ភូមិបាលហាក់សំដៅអចលនវត្ថុពីភ័ព្វវាសនាតែវត្ថុដែល *ជាប់* នឹងដី ឬអគារ។ ឧទាហរណ៍ជាក់ស្តែង ដើមឈើដាំជាប់នឹងដីមុខផ្ទះ អាចត្រូវចាត់ទុកជាអចលនវត្ថុតាមភ័ព្វវាសនា តែអរគីដេមួយផើងព្យួរមុខផ្ទះមិនមែនឡើយ ដោយសារគេអាចដកចេញដោយមិនឲ្យខូចខាតដល់ផ្ទះ ឬផ្កានោះ។ រូបចម្លាក់ថ្មដែលដាក់តាំងមានស៊ីម៉ង់ត៍ភ្ជាប់នឹងកម្រាលឥដ្ឋផ្ទះ ជាអចលនវត្ថុពីភ័ព្វវាសនា ខុសពីរូបចម្លាក់ឈើ ដែលគេអាចដកចេញដោយមិនឲ្យមានខូចខាត។

[17] មាត្រា ២ កថាខណ្ឌទី ២ ច្បាប់ភូមិបាល

[18] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ១ រៀបចំដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រម ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល នៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD) សិទ្ធិអ្នកនិពន្ធ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ឆ្នាំ ២០១៣ (តទៅហៅថា «សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី JICA») ទំព័រ ៣៤។

[19] និយមន័យតាមច្បាប់ភូមិបាល មាត្រា ២ កថាខណ្ឌទី ៣។

គួរកត់សម្គាល់ថា ច្បាប់បរទេសមួយចំនួន ពិសេសក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និងបារាំង មានចែងលម្អិតអំពីចលនវត្ថុមួយចំនួនដែលប្រែក្លាយទៅជាអចលនវត្ថុពីភ័ព្វវាសនា ក្នុងករណីចលនវត្ថុទាំងនោះត្រូវបានភ្ជាប់ខ្លួនជាបរិវារ ឬត្រូវបានប្រើប្រាស់ចាំបាច់ ឬមានប្រយោជន៍ក្នុងអាជីវកម្មក្នុងគោលបំណងនៃអចលនវត្ថុពីកំណើតមួយ។ ឧទាហរណ៍ យានយន្តភ្ជួរស្រែ ប្រសិនបើត្រូវបានប្រើប្រាស់ជាចាំបាច់សម្រាប់ភ្ជួរស្រែរបស់ម្ចាស់ ឬសត្វដែលចាំបាច់សម្រាប់អាជីវកម្ម ដូចជាគោក្របីសម្រាប់ភ្ជួរស្រែ ឬសត្វឃ្មុំ និងសម្បុកឃ្មុំក្នុងកសិដ្ឋានចិញ្ចឹមឃ្មុំ ឬជ្រូកនៅទីសត្តឃាតជ្រូក[20]។ ក្រមរដ្ឋប្បវេណី និងច្បាប់ភូមិបាលមិនបានចែងគោលគំនិតជាក់លាក់ដូចខាងលើ តែមានគោលការណ៍ជាទូទៅ ដូចជាសមាសភាគនៃវត្ថុ និងគោលការណ៍វត្ថុចម្បង និងវត្ថុចំណុះ ដែលជាគោលការណ៍ច្បាប់ទូទៅដែលអាចអោយគេទាញចលនវត្ថុខាងលើឲ្យក្លាយជាអចលនវត្ថុដែរ (ឧទាហរណ៍ ម្ចាស់ស្រែបានភ្ជាប់យានយន្តភ្ជួរស្រែជាផ្នែកចំណុះមួយនៃដីស្រែ ឬឃ្មុំជាសមាសភាគមួយនៃដីកសិដ្ឋានចិញ្ចឹមឃ្មុំ)។

### គ. អចលនវត្ថុតាមការកំណត់របស់ច្បាប់

អចលនវត្ថុតាមការកំណត់របស់ច្បាប់ មានសិទ្ធិភណ្ឌិកទាំងឡាយលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ[21]។ តាមក្រមរដ្ឋប្បវេណី សិទ្ធិភណ្ឌិក ឬហៅថាសិទ្ធិប្រត្យក្ស សំដៅទៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះដែលអាចអះអាងចំពោះបុគ្គលដទៃទៀត[22]។ យោងតាមច្បាប់ភូមិបាលឆ្នាំ១៩៩២[23] វត្ថុមួយចំនួនដែលដឹកនាំបានតាមកំណើតរបស់វា តែច្បាប់រាប់បញ្ចូលជាអចលនវត្ថុនឹងត្រូវបានចាត់ទុកថាជាអចលនវត្ថុតាមសន្មតរបស់ច្បាប់ ដូចជា ទូកដែលមានចំណុះចាប់ពី ៣០ តោនឡើងទៅ និងផ្ទះផែ ដែលមានចំណុះដូចគ្នា។

---

[20] សូមមើលជាឧទាហរណ៍ មាត្រា ៥២៤ ក្រមរដ្ឋប្បវេណីបារាំង និងមាត្រា ៩៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់។

[21] និយមន័យតាមច្បាប់ភូមិបាល មាត្រា ២ កថាខណ្ឌទី ៤។

[22] សូមមើលផ្នែកនិយមន័យ នៃសិទ្ធិប្រត្យក្ស/សិទ្ធិភណ្ឌិក ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១ និងមាត្រា ១៣០។ សូមមើលមាត្រា ១៣២ នៃក្រមដដែល អំពីសិទ្ធិប្រត្យក្សទាំងឡាយដែលក្រមមានចែង។

[23] ច្បាប់ភូមិបាល ឆ្នាំ១៩៩២ ដែលត្រូវបានប្រកាសឲ្យប្រើដោយ ក្រឹត្យ/ច្បាប់/១០០ ក្រ/១៣ តុលា ១៩៩២ តទៅហៅថា «ច្បាប់ភូមិបាលឆ្នាំ១៩៩២»។

# ៣. ផលុបភោគ

## ៣.១ គោលគំនិតទូទៅ

**និយមន័យ.** ផលុបភោគ[24] សំដៅទៅលើសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃក្នុងអំឡុងពេលកំណត់ណាមួយ។ ប្រសិនបើមិនបានកំណត់អំឡុងពេលនៃអត្ថិភាពទេ ផលុបភោគត្រូវចាត់ទុកថាមានអត្ថិភាពរហូតផលុបភោគី[25] ទទួលមរណភាព (ពោលគឺ រយៈពេលអតិបរមានៃផលុបភោគគឺមួយជីវិតនៃផលុបភោគី)។ លើសពីនេះ គេអាចកំណត់អំឡុងពេលអត្ថិភាពនៃផលុបភោគ រហូតដល់ពេលណាមួយដែលហេតុការណ៍ណាមួយបានកើតឡើង (កើតឡើង ឬបញ្ឈប់ទៅវិញ)។ ឧទាហរណ៍ ផលុបភោគរហូតដល់ពេលចប់ប្រមូលផលស្រែ ឬរហូតដល់ពេលមានភ្លៀងធ្លាក់[26]។ ផលុបភោគត្រូវរលត់ទៅវិញ នៅពេលផលុបភោគីទទួលមរណភាព ឬបញ្ចប់អំឡុងពេលដែលបានកំណត់ក្នុងកិច្ចសន្យាបង្កើតផលុបភោគ[27]។

## ៣.២ សិទ្ធិចេញពីផលុបភោគ

**ផលធម្មជាតិ.** សិទ្ធិចម្បងពីរ ចេញពីផលុបភោគគឺ សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលធម្មជាតិ និងផលស៊ីវិលដែលកើតចេញពីអចលនវត្ថុ។ ផល[28]គឺជាអត្ថប្រយោជន៍ដែលកើតចេញពីវត្ថុអ្វីមួយ ខណៈផលធម្មជាតិគឺជាវត្ថុដែលកើតចេញមកពីវត្ថុដើមពីធម្មជាតិដោយឯកឯង តាមគោលបំណងធម្មជាតិរបស់វត្ថុនោះ។ ឧទាហរណ៍ ផ្លែឈើមិនមាននរណាដាំ ឬទឹកដោះសត្វ ឬសាច់សត្វ ដែលគេចិញ្ចឹម។

---

[24] មាត្រា ២៥៦ កថាខណ្ឌទី ១។

[25] ផលុបភោគី គឺជាបុគ្គលដែលទទួលបានផលុបភោគ។

[26] មូលហេតុដែលអនុញ្ញាតអោយអំឡុងពេលនៃផលុបភោគអាចគិតត្រឹមព្រឹត្តិការណ៍ណាមួយ (ជាជាងកាលកំណត់ជាក់លាក់ដូចកិច្ចសន្យាជួល) ដោយហេតុថា ពេលខ្លះ ហេតុផលដែលនាំឲ្យមានផលុបភោគ គឺគេចង់បានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលជាក់លាក់ទៅលើអចលនវត្ថុអ្វីមួយ និងផលជាក់លាក់ណាមួយពីអចលនវត្ថុនោះក្នុងកាលៈទេសៈ ឬរដូវកាលជាក់លាក់ណាមួយ។

[27] មាត្រា ២៦៨

[28] មាត្រា ១២៧

**សិទ្ធអាស្រ័យផលធម្មជាតិ**[29]. គោលគំនិតទូទៅគឺថា នៅពេលបង្កើតផលុបភោគ ផលធម្មជាតិត្រូវបានទៅផលុបភោគី ហើយនឹងត្រូវបានទៅកម្មសិទ្ធិករនៃដីវិញ នៅពេលផលុបភោគរលត់។ តែក្រមរដ្ឋប្បវេណីបានកំណត់គោលការណ៍លើកលែងសំខាន់មួយ គឺថាសិទ្ធិខាងលើមិនអាចអនុវត្តបានឡើយ ក្នុងករណីសេចក្តីចម្រើនដោយឥតហេតុ ចំពោះការងារពលកម្ម ជាអាទិ៍ ដើម្បីបង្កើតផលធម្មជាតិនោះ[30]។ បានសេចក្តីថា ប្រសិនបើផលធម្មជាតិនោះបានកើតមានឡើងដោយការងារពលកម្ម ឬសកម្មភាពរបស់មនុស្ស (ឧទាហរណ៍អ្នកជួលដីមុន) មុនពេលមានផលុបភោគ នោះផលុបភោគីមិនត្រូវមានសិទ្ធិលើផលធម្មជាតិនោះឡើយ។ ឧទាហរណ៍ ដំណាំដែលកសិករបានធ្វើពីការជួលដីពីកម្មសិទ្ធិករមុនពេលបង្កើតផលុបភោគនឹងត្រូវជាដំណាំរបស់កសិករនោះដដែល បើទោះជាដីត្រូវបានដាក់ក្រោមផលុបភោគក្រោយមកក៏ដោយ។ សិទ្ធិផលុបភោគខាងលើក៏មិនអាចអនុវត្តដែរ ក្នុងករណីផលធម្មជាតិរបស់ភតិកៈក្រោមសិទ្ធិជួល (លើដីដែលមានផលុបភោគតាមក្រោយ) ដែលមានអានុភាពតតាំងលើដីផលុបភោគនោះ (ឧទាហរណ៍ សិទ្ធិជួលអចិន្ត្រៃយ៍ដែលបានចុះបញ្ជីមុនផលុបភោគ)[31]។ ម្យ៉ាងវិញទៀត បើទោះជាផលុបភោគរលត់ទៅវិញក៏ដោយ ភតិកៈដែលជួលដីបន្តពីផលុបភោគី (ហើយផលុបភោគីបានថែទាំផលធម្មជាតិរហូតដល់ពេលផលុបភោគរលត់)នឹងបន្តមានសិទ្ធិអាស្រ័យផលធម្មជាតិនោះ[32]។

**សិទ្ធិអាស្រ័យផលស៊ីវិល.** ផលស៊ីវិល គឺជាប្រាក់ថ្លៃឈ្នួល ជាអាទិ៍ ឬវត្ថុផ្សេងទៀត ដែលទទួលជាថ្នូរចំពោះការប្រើប្រាស់វត្ថុណាមួយ[33]។ ផលុបភោគីអាចអាស្រ័យផលលើផលស៊ីវិលតាមសមាមាត្រទៅនឹងអំឡុងពេលដែលផលុបភោគមានអត្ថិភាព[34]។ ក្នុងករណីនេះ ផលុបភោគីចាស់ និងផលុបភោគីថ្មី អាចទទួលបានតាមសមាមាត្រទៅនឹងអំឡុងពេលដែលខ្លួនមានផលុបភោគ[35]។ គេអាចនិយាយបានថា សម្រាប់ផលស៊ីវិល (ឧទាហរណ៍ ប្រាក់ឈ្នួលជួលរយៈពេល

---

[29] មាត្រា ២៦១

[30] មាត្រា ២៦១ កថាខណ្ឌទី ៣

[31] មាត្រា ២៦១ កថាខណ្ឌទី ៤

[32] មាត្រា ២៦១ កថាខណ្ឌទី ៥

[33] មាត្រា ១២៧

[34] មាត្រា ២៦២

[35] សេចក្តីកំណត់ចំពោះមាត្រា ២៦២

៥ឆ្នាំ លើដីមួយផ្នែកនៃដីផលុបភោគ) ផលុបភោគីម្នាក់មានសិទ្ធិទទួលបានផលស៊ីវិលត្រឹម ២ឆ្នាំ នៃប្រាក់ឈ្នួល ប្រសិនបើផលុបភោគីនោះមានសិទ្ធិផលុបភោគត្រឹម ២ ឆ្នាំដែរ។

### ៣.៣ ការបង្កើតផលុបភោគ

**ការបង្កើត**[36]. ផលុបភោគអាចត្រូវបានបង្កើត តាមលិខិតលាយល័ក្ខណ៍អក្សរ ឬមិនលាយល័ក្ខណ៍អក្សរ។ កម្មសិទ្ធិករអាចស្នើសុំឲ្យរំលត់ផលុបភោគដែលមិនបានធ្វើតាមលាយ-លក្ខណ៍អក្សរនៅពេលណាក៏បាន។ តាមរយៈនេះលិខិតលាយលក្ខណ៍អក្សរមិនមែនជាលក្ខ-ខណ្ឌដើម្បីបង្កើតផលុបភោគទេ គ្រាន់តែថា បើមិនបានបង្កើតជាលាយលក្ខណ៍អក្សរ ផលុបភោគអាចត្រូវបានស្នើរំលត់ពេលណាក៏បាន។ ក្នុងករណីដែលការស្នើសុំឲ្យរំលត់មិនបានបញ្ជាក់អំពីពេលរលត់ និងក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឲ្យរំលត់រហូតដល់ពេលរលត់ដែលបានបញ្ជាក់ក្នុងការស្នើសុំរលត់ មានរយៈពេលតិចជាងខាងក្រោម ផលុបភោគត្រូវរលត់ក្នុងរយៈពេលដូចខាងក្រោម រាប់ចាប់ពីពេលស្នើសុំឲ្យរលត់៖

ក. ៣ ខែ ចំពោះអគារ

ខ. ១ ខែ ចំពោះដី។

ចំពោះផលុបភោគដីដែលមានរដូវប្រមូលផល ការស្នើឲ្យរំលត់ត្រូវធ្វើនៅមុនពេលដែលផលុបភោគីចាប់ផ្តើមការងារកសិកម្មសម្រាប់រដូវបន្ទាប់ពីរដូវមុន។ តាមរយៈខាងលើទោះបង្កើតលាយលក្ខណ៍អក្សរ ឬមិនលាយលក្ខណ៍អក្សរ ការរំលត់ហាក់ត្រូវបានកំណត់តឹងរឹងដោយច្បាប់ដែលនេះអាចដោយហេតុថា ផលុបភោគគឺជាសិទ្ធិមួយដែលផលុបភោគីពឹងផ្អែកខ្លាំងលើការប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុផលុបភោគ។

**ទម្រង់.** ផលុបភោគអាចត្រូវបានបង្កើតក្រោមរូបភាពពីរ៖ តាមការព្រមព្រៀងរវាងគូភាគី ឬតាមបញ្ញត្តិច្បាប់ ហើយផលុបភោគតាមបញ្ញត្តិច្បាប់ មានអាទិភាពជាងផលុបភោគតាមការព្រមព្រៀង[37]។ ទោះបីគេពុំឃើញមានបញ្ញត្តិច្បាប់ជាក់លាក់ណាមួយ អំពីផលុបភោគកំណត់ដោយច្បាប់ គេអាចពិនិត្យលើករណីសន្មតមួយចំនួនដែលអាចមាន ឧទាហរណ៍ ផលុបភោគដល់អតីតយុទ្ធជនលើដី ឬចំការ ក្នុងតំបន់ពិសេសណាមួយ ដោយរាជរដ្ឋាភិបាលដែលអាចមានអាទិភាពជាងផលុបភោគតាមការព្រមព្រៀងផ្សេងទៀតលើដីតែមួយ។

---

[36] មាត្រា ២៥៨

[37] មាត្រា ២៥៧

**លក្ខខណ្ឌតតាំង.**[38] ដូចគ្នានឹងសិទ្ធិប្រាតិភោគប្រត្យក្សមួយចំនួនទៀតដែរ ផលុបភោគ (បូករួមទាំងកិច្ចសន្យាពិសេសដែលគូភាគីព្រមព្រៀង ឧទាហរណ៍ចំណុចពិភាក្សាក្នុងផ្នែក**អានុភាពនៃការរលត់ផលុបភោគ**) តម្រូវចុះបញ្ជីដើម្បីលក្ខខណ្ឌតតាំងជាមួយតតិយជន។ ចុះបញ្ជីរួចហើយ គឺអាចតតាំងចំពោះម្ចាស់អចលនវត្ថុថ្មីផងដែរ។ នីតិវិធីនៃការចុះបញ្ជីមានចែងពិស្តារក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ខណៈដែលការអនុវត្តជាក់ស្តែង នៃការចុះបញ្ជីលើផលុបភោគហាក់ពុំសូវមានច្រើន ខុសពីហ៊ីប៉ូតែក។

## ៣.៤ កម្មវត្ថុនៃផលុបភោគ

**បន្ទុកពន្ធអាករ និងសោហ៊ុយធានារ៉ាប់រង.**[39]ក្នុងអំឡុងពេលនៃផលុបភោគ ផលុបភោគីមានករណីយកិច្ចត្រូវទទួលបន្ទុកនូវពន្ធ និងអាករ ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ។ គេអាចនិយាយបានថាពន្ធអាករខាងលើរាប់បញ្ចូលទាំងពន្ធលើអចលនទ្រព្យផងដែរ។ ប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ[40]បានកំណត់ថា អ្នកជាប់ពន្ធមិនមែនទាល់តែជាកម្មសិទ្ធិករទេ គឺអាចជាអ្នកកាន់កាប់[41] ឬអ្នកទទួលប្រយោជន៍ចុងក្រោយ[42] លើអចលនទ្រព្យ ហើយការបង់ពន្ធបែបនេះ មិនមែនជាលក្ខខណ្ឌបញ្ជាក់កម្មសិទ្ធិស្របច្បាប់នៃអចលនទ្រព្យឡើយ[43]។ ជាមួយគ្នាដែរ ផលុបភោគីត្រូវទទួលបន្ទុកសម្រាប់ការធានារ៉ាប់រងអចលនវត្ថុដែលកម្មសិទ្ធិករបានធ្វើកិច្ចសន្យាមុនពេលបង្កើតផលុបភោគ។ ប្រសិនបើកម្មសិទ្ធិករបានធ្វើកិច្ចសន្យាពាក់ព័ន្ធនឹងការធានារ៉ាប់រងលើអចលនវត្ថុ មុនពេលអចលនវត្ថុនោះត្រូវបានបង្កើតផលុបភោគ សោហ៊ុយនៃការធានារ៉ាប់រងបន្តបន្ទាប់លើអចលនវត្ថុក្នុងអំឡុងពេលនៃផលុបភោគ ត្រូវបង់បន្តដោយ

---

[38] មាត្រា ២៥៩

[39] មាត្រា ២៧២

[40] ប្រកាសលេខ៤៩៣ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១០។

[41] ប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យកំណត់និយមន័យ អ្នកកាន់កាប់ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលគ្មានបណ្ណសម្គាល់សិទ្ធិ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដី។

[42] ប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យកំណត់និយមន័យ អ្នកទទួលប្រយោជន៍ចុងក្រោយ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលនូវសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល សិទ្ធិចាត់ចែង និងសិទ្ធិអាស្រ័យនៅចុងក្រោយលើអចលនទ្រព្យ។

[43] ប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ មាត្រា ១២

ផលុបភោគី។ ជាការគួរកត់សម្គាល់ ផលុបភោគីទទួលបន្ទុកបង់ថ្លៃធានារ៉ាប់រង តែមិនមែនមានន័យថា ឋានៈនៃកិច្ចសន្យាធានារ៉ាប់រងត្រូវតែផ្ទេរ ហើយផលុបភោគីត្រូវក្លាយជាភាគីនៃកិច្ចសន្យាធានារ៉ាប់រងឡើយ គឺគ្រាន់តែត្រូវបង់ថ្លៃបន្ត។ ទាំងនេះគឺជាបន្ទុកនិងករណីយកិច្ចសមរម្យតាមច្បាប់ដែលផលុបភោគីត្រូវទទួលខុសត្រូវ ដោយផលុបភោគីបានទទួលសិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុ។

**សោហ៊ុយថែទាំ.**[44] សោហ៊ុយសម្រាប់ការជួសជុលថែទាំអចលនវត្ថុ ត្រូវជាបន្ទុករបស់ផលុបភោគី ចំណែកឯសោហ៊ុយសម្រាប់ការជួសជុលធំៗ ត្រូវជាបន្ទុករបស់កម្មសិទ្ធិករ។ ការជួសជុលធំៗ សំដៅទៅលើការកែប្រែជញ្ជាំងចម្បង ធ្នឹមដំបូល និងគ្រឹះ និងការរៀបចំឡើងវិញនូវដំបូល ចំណែកឯការជួសជុលក្រៅពីនេះ គឺជាការជួសជុលថែទាំ។ ក្រមរដ្ឋប្បវេណីព្យាយាមចែងលម្អិតត្រង់ចំណុចនេះ ប៉ុន្តែថាតើអ្វីជាការជួសជុលធំៗ និងការជួសជុលថែទាំ នៅតែអាចត្រូវបានបកស្រាយផ្សេងៗទៀត អាស្រ័យទៅតាមសភាព និងទម្រង់ជាក់ស្តែងនៃអចលនវត្ថុ (ឧទាហរណ៍ អគារធំៗដែលមានគម្រោងស្មុគស្មាញ មានសកម្មភាពលើផ្នែកជាច្រើននៃអគារនោះដែលគេអាចចាត់ទុកជាការជួសជុលធំៗ)។

ក្នុងករណីដែលភាពចាំបាច់ក្នុងការជួសជុលធំៗ បានកើតឡើង ដោយសារផលុបភោគីមិនបានជួសជុលថែទាំ សោហ៊ុយនោះត្រូវជាបន្ទុករបស់ផលុបភោគី។ ក្នុងករណីខូចខាត ឬអន្តរាយ ដោយករណីប្រធានសក្តិ នោះទាំងកម្មសិទ្ធិករ ទាំងផលុបភោគីគ្មានការទទួលខុសត្រូវក្នុងការសាងសង់វិញ ឬការទទួលខុសត្រូវផ្សេងទៀត ចំពោះការខូចខាត ឬអន្តរាយនោះឡើយ។ ការអន្តរាយអាចថា មិនមែនតែលើអគារប៉ុណ្ណោះទេ គឺរាប់បញ្ចូលទាំងករណីនៃការផ្លាស់ប្តូររូបរាងដី ដោយសារទឹកជំនន់ ឬរលកធំៗផងដែរ[45]។ ក្នុងន័យនេះគេក៏អាចនិយាយម្យ៉ាងបានដែរថា ប្រសិនបើគូភាគីព្រមព្រៀងនឹងសាងសង់ ឬជួសជុលឡើងវិញ បន្ទាប់ពីករណីប្រធានសក្តិ គេនឹងអនុវត្តគោលការណ៍កម្មសិទ្ធិករ ទទួលខុសត្រូវសម្រាប់ការជួសជុលធំផលុបភោគីសម្រាប់ការជួសជុលថែទាំ[46]។

[44] មាត្រា ២៧១

[45] សេចក្តីកំណត់ចំពោះមាត្រា ២៧១

[46] សូមមើលបន្ថែមសេចក្តីកំណត់ចំពោះមាត្រា ២៧១ នៃក្រមរដ្ឋប្បវេណី ដែលផ្តល់នូវការពិភាក្សាគួរចាប់អារម្មណ៍អំពីបញ្ហានៃទំនួលខុសត្រូវក្នុងករណីទាំងនេះ។

**អន្តរាយនៃកម្មវត្ថុផលុបភោគ.**[47]ក្នុងករណីកម្មវត្ថុនៃ ផលុបភោគត្រឹមជាអគារមិនរាប់បញ្ចូលដី ហើយអគារត្រូវអន្តរាយ ផលុបភោគីមិនអាចអនុវត្តផលុបភោគចំពោះដីបានឡើយ។ តែប្រសិនបើ កម្មវត្ថុនៃផលុបភោគជាដីផង និងអគារផង ហើយមានតែអគារប៉ុណ្ណោះដែលត្រូវអន្តរាយ នោះផលុបភោគចំពោះដីនៅតែមានដដែល។

## ៣.៥ តម្លៃថ្នូរ[48]

ជាទូទៅ ផលុបភោគមានចរឹកមិនយកតម្លៃថ្នូរជាប្រាក់កាស ប៉ុន្តែក៏អាចយកតម្លៃថ្នូរបានដែរ ដែលគ្រប់គ្រងដោយបញ្ញត្តិច្បាប់តែមួយជាមួយនឹងបញ្ញត្តិទាក់ទងនឹងថ្លៃឈ្នួល និងការតម្លើង ឬបញ្ចុះថ្លៃឈ្នួល នៃសិទ្ធិជួលអចិន្ត្រៃយ៍[49]។ ក្នុងករណីព្រមព្រៀងឲ្យមានថ្លៃឈ្នួល ផលុបភោគីមានករណីយកិច្ចបង់ថ្លៃឈ្នួលទៅតាមពេលកំណត់។ ប្រសិនបើពុំមានកំណត់ពេលបង់ច្បាស់លាស់ត្រូវបង់នៅរាល់ដំណាច់ឆ្នាំ។ ចំពោះវត្ថុដែលមានរដូវប្រមូលផលត្រូវបង់នៅក្រោយរដូវនោះ ដោយគ្មានការយឺតយ៉ាង។ ប្រសិនបើពិភាក្សាគ្នាមិនត្រូវ ភាគីទាំងសងខាងអាចទាមទារទៅតុលាការឲ្យតម្លើង ឬបញ្ចុះថ្លៃឈ្នួលទៅតម្លៃសមរម្យ ក្នុងករណីថ្លៃឈ្នួលដើមក្លាយជាតម្លៃមិនសមរម្យដោយសារស្ថានភាពផ្សេងៗ។

## ៣.៦ ការអនុវត្តផលុបភោគ

**ការចាត់ចែង.** ដោយហេតុថា ផលុបភោគគឺជាសិទ្ធិប្រត្យក្ស ផលុបភោគីមានសិទ្ធិក្នុងការធ្វើអនុប្បទាន[50] ឬចាត់ចែងផ្សេងទៀតទៅលើផលុបភោគ ឧទាហរណ៍ជួលអចលនវត្ថុផលុបភោគ។ តាមរយៈសិទ្ធិចាត់ចែងលើផលុបភោគខាងលើ ផលុបភោគីអាច[51]យកអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ធ្វើជាកម្មវត្ថុនៃភតិសន្យាបាន។ អំឡុងពេលនៃភតិសន្យានេះមិនត្រូវលើសពី ៣ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន ប៉ុន្តែរយៈពេលបន្តមិនត្រូវលើសពី ៣ឆ្នាំ។ តែគួរកត់សម្គាល់ថា ជាគោលការណ៍ ការធ្វើអនុប្បទាន ឬចាត់ចែងផលុបភោគអាចត្រូវបានធ្វើឡើងត្រឹមអំឡុងពេល និងវិសាលភាពនៃផលុបភោគដើមប៉ុណ្ណោះ (ឧទាហរណ៍ មិនឲ្យលើសពីរយៈ

---

[47] មាត្រា ២៧០

[48] មាត្រា ២៧៣

[49] មាត្រា ២៤៨ និង ២៥៩

[50] មាត្រា ២៦៣

[51] មាត្រា ២៦៤

ពេលនៃផលុបភោគដើម)។ តាមរយៈនេះ បើផលុបភោគរលត់ ភតិសន្យាខាងលើ ក៏ត្រូវរលត់ និងមិនអាចតតាំងចំពោះកម្មសិទ្ធិករ ឬអ្នកមានសិទ្ធិមានអាទិភាពផ្សេងទៀត លើអចលនវត្ថុឡើយ។

**សិទ្ធិទាមទារ**[52]. ដោយហេតុថាផលុបភោគ គឺជាសិទ្ធិប្រត្យក្សដែលជាសិទ្ធិគ្រប់គ្រង និងសិទ្ធដាច់ខាត ដូច្នេះប្រសិនបើមានការរារាំង ឬរំខានលើសិទ្ធិនេះ ផលុបភោគីមានសិទ្ធិស្របច្បាប់ក្នុងការទាមទារ (គេហៅថា សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស) ឲ្យបញ្ឈប់ការរារាំង ឲ្យប្រគល់មកវិញ ឬសិទ្ធិទាមទារឲ្យបង្ការជាមុននូវការរារាំង[53] ក្នុងករណីមានការបារម្ភជាក់ស្តែងថា ការអនុវត្តសិទ្ធិរបស់ខ្លួននឹងទទួលការរារាំង។ ទាំងនេះ គឺជាសិទ្ធិដែលត្រូវបានធានាដោយច្បាប់។ តែទន្ទឹមគ្នានេះដែរ បើមានតតិយជនអះអាងអំពីសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ផលុបភោគីត្រូវជូនដំណឹងអំពីហេតុនេះ ទៅកម្មសិទ្ធិករនៃអចលនវត្ថុដោយគ្មានការយឺតយ៉ាវ លើកលែងក្នុងករណីកម្មសិទ្ធិករបានដឹងរួចហើយ។ ការធ្វេសប្រហែសក្នុងការជូនដំណឹង នឹងតម្រូវឲ្យផលុបភោគីត្រូវទទួលខុសត្រូវចំពោះកម្មសិទ្ធិករ ប្រសិនបើមានការខូចខាតណាមួយកើតឡើង។ ករណីយកិច្ចជូនដំណឹងដោយមានសំណងនៃការខូចខាតនេះ គឺជាករណីយកិច្ចដែលច្បាប់កំណត់លើផលុបភោគី ក្រោមមូលដ្ឋាននៃសិទ្ធិប្រត្យក្សដែលផលុបភោគីទទួលបាន។ នេះខុសពីករណីនៃភតិសន្យាធម្មតា ដែលភតិកៈមានកាតព្វកិច្ចជូនដំណឹង តែមិនត្រូវសងសំណង ក្នុងករណីមានការខូចខាតដោយសារមិនបានជូនដំណឹង[54] ពីព្រោះសិទ្ធិជួលដែលភតិកៈមានគឺជាសិទ្ធិលើបំណុល(ឬកាតព្វកិច្ច) ដែលមិនមានសិទ្ធិអំណាចទូលំទូលាយដូច ផលុបភោគដែលជាសិទ្ធិប្រត្យក្ស។

## ការរលត់នៃផលុបភោគ

**ការរំលត់.** កម្មសិទ្ធិករអាចទាមទារទៅតុលាការឲ្យរំលត់ផលុបភោគបាន ប្រសិនបើផលុបភោគីបានធ្វើអំពីផ្ទុយនឹងខ្លឹមសារនៃផលុបភោគ ដូចជាធ្វើឲ្យមានការខូចខាត ឬថែរក្សាមិនបានត្រឹមត្រូវជាអាទិ៍ ទៅលើអចលនវត្ថុផលុបភោគ[55]។ ច្បាប់មិនបានចែងជាក់លាក់ថាតើ

---

[52] មាត្រា ២៦៥

[53] ក្រមរដ្ឋប្បវេណីមិនបានចែងច្បាស់ ថាតើទាមទារឲ្យបង្ការទៅនរណាអាចថាទៅអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ឬទៅតុលាការ (ដើម្បីចេញដីការក្សាការពារ ឬចាត់ចែងបណ្តោះអាសន្នជាដើម)។

[54] មាត្រា ៦១១

[55] មាត្រា ២៦៧ កថាខណ្ឌទី ១

កម្មសិទ្ធិករអាចទាមទារឲ្យរំលត់ផលុបភោគបានឬទេ ក្នុងករណីផលុបភោគមានថ្លៃថ្នូរ ហើយផលុបភោគីមិនបានបង់ថ្លៃថ្នូរ។ តាមការលើកឡើងមួយចំនួន[56] ការមិនបានបង់ថ្លៃថ្នូរមិនមែនជាហេតុមួយនៃការរំលាយផលុបភោគទេ ដោយហេតុថា គោលបំណងនៃផលុបភោគមិនមែនផ្តោតលើថ្លៃថ្នូរដូចជំនួញ (ខុសពីភតិសន្យា) ដូច្នេះថ្លៃថ្នូរមិនគួរជាមូលហេតុចម្បងមួយក្នុងការរំលាយ។ ទោះយ៉ាងណា ច្បាប់មិនបានចែងជាក់លាក់អំពីចំណុចនេះ បើទោះជាកថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីហាក់ផ្តោតមូលហេតុនៃ ការនាំឲ្យរំលាយតែទៅលើអំពើដែលនាំឲ្យប៉ះពាល់ដល់សភាពនៃអចលនវត្ថុ។ លើសពីនេះ គេក៏អាចទាមទារសំណងការខូចខាត ក្នុងករណីផលុបភោគីបានប្រព្រឹត្តិអំពើអនីត្យានុកូលណាមួយ[57]។

**អានុភាពនៃការរលត់នៃផលុបភោគ[58].** នៅពេលផលុបភោគរលត់ កម្មសិទ្ធិករអចលនវត្ថុមិនអាចទាមទារឲ្យផលុបភោគីធ្វើបដិទាន (ធ្វើអចលនវត្ថុឲ្យទៅសភាពដើមមុនផលុបភោគវិញ)បានឡើយ លើកលែងក្នុងករណីផលុបភោគីបានបំផ្លាញអចលនវត្ថុ ឬបានបំប្លែងជាសារវន្តនូវលក្ខណៈនៃអចលនវត្ថុ។ គេអាចនិយាយបានថា ប្រសិនបើផលុបភោគីបានប្រើប្រាស់អាស្រ័យផលលើអចលនវត្ថុតាមធម្មតា នោះមិនបាច់ធ្វើឲ្យដូចដើមវិញឡើយ លើកលែងការបំផ្លាញ ឬការប្រើប្រាស់ដែលធ្វើឲ្យខុសខ្លាំងធម្មតាពីសភាពដើម ឧទាហរណ៍ ផលុបភោគធ្វើស្រែ តែនៅពេលចប់បែរជាមានសុទ្ធតែអន្លង់ជីករ៉ែ ឬមុនផលុបភោគ ផ្ទះពីរល្វែងមានជញ្ជាំងខ័ណ្ឌ តែដល់ពេលចប់ផ្ទះពីរល្វែងចូលគ្នាបាត់ជញ្ជាំង។ លើសពីនេះ នៅពេលផលុបភោគរលត់ កម្មសិទ្ធិករអចលនវត្ថុអាចទទួលបានកម្មសិទ្ធិលើការ្យដែលបានកែលំអ ឬសំណង់ជាអាទិ៍ដែលផលុបភោគីបានធ្វើ ដោយគ្មានប្រាក់សំណងណាមួយដល់ផលុបភោគី ឬសន្តតិជនរបស់ផលុបភោគី។ ភាគីអាចធ្វើការសន្យាផ្សេងពីបញ្ញត្តិច្បាប់ដែលបានពិភាក្សាក្នុងចំណុចនេះ ប៉ុន្តែការសន្យានោះមិនអាចតតាំងនឹងតតិយជនបានឡើយ បើមិនបានចុះបញ្ជី (ចុះបញ្ជីផលុបភោគដោយចែងអំពីការសន្យាពិសេសនោះ ក្នុងលិខិតចុះបញ្ជីដែរ)។

---

[56] សេចក្តីកំណត់ចំពោះមាត្រា ២៦២

[57] មាត្រា ២៦៧ កថាខណ្ឌទី ២

[58] មាត្រា ២៦៩

## ៤. សេចក្តីសន្និដ្ឋាន

ផលុបភោគ មានចរឹតផ្តល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផល ទៅភាគីម្ខាងទៀត ដូចគ្នានឹងភតិសន្យា ប៉ុន្តែខុសគ្នាត្រង់ថា ភតិសន្យាអាចអនុវត្តបានចំពោះចលនវត្ថុ និងអចលនវត្ថុ រីឯផលុបភោគអនុវត្តចំពោះអចលនវត្ថុប៉ុណ្ណោះ។ លើសពីនេះ ច្បាប់ចែងជាក់លាក់ថា ភតិសន្យាត្រូវយកថ្លៃឈ្នួល។ ភតិសន្យាត្រូវបានប្រើប្រាស់ច្រើនក្នុងគោលបំណងប្រាក់កាស តាមរយៈការយកប្រាក់ឈ្នួល។ គេថែមទាំងអាចធ្វើពាណិជ្ជកម្មតាមរយៈភតិសន្យាជាកម្មវត្ថុ (ឧទាហរណ៍ ក្រុមហ៊ុនម្ចាស់អគារជួលប្រើប្រាស់ជាការិយាល័យ ឬហាងលក់ដូរ)។ ផលុបភោគវិញ មានលក្ខណៈជាសិទ្ធិដែលផ្តល់ទៅ និងជាប់ជាមួយនឹងបុគ្គលជាក់លាក់(servitutes personarum) គឺមានន័យថា ជាសិទ្ធិមានចរឹតផ្តល់ឲ្យដល់បុគ្គលជាក់លាក់ ប្រើប្រាស់ និងអាស្រ័យផល សម្រាប់ជីវិតគេផ្ទាល់ខ្លួន (ត្រង់នេះ គេអាចឃើញចំណុចខុសគ្នាទៅនឹងភតិសន្យាលើអគារដើម្បីអាជីវកម្ម) ដែលដូច្នេះហើយ ច្បាប់កំណត់រយៈពេលអតិបរមានៃផលុបភោគត្រឹមមួយជីវិតនៃផលុបភោគី។ អំឡុងពេលនៃភតិសន្យា មិនគិតអំពីអំឡុងជីវិតនៃអ្នកជួលជាធំទេ គឺអាចមានរយៈពេលដល់ ៥០ឆ្នាំ និងបន្តបានទៀត។ ចំណុចខុសគ្នាសំខាន់មួយទៀត គឺត្រង់ថា ភតិ-សន្យាគិតដល់ថ្លៃជួលជាធំ ហើយការមិនបង់ថ្លៃជួលជាលក្ខខណ្ឌមួយនាំទៅការរំលាយភតិ-សន្យាបាន។ ចំពោះផលុបភោគវិញ ច្បាប់មិនបានហាមមិនឲ្យយកតម្លៃថ្នូរ ប៉ុន្តែច្បាប់ក៏មិនបានចែងជាក់លាក់ថា ការមិនបានបង់តម្លៃថ្នូរអាចនាំឈានដល់ការរំលាយផលុបភោគ។ម្យ៉ាងវិញទៀត ភតិសន្យាផ្តោតឲ្យមានអំឡុងពេលជាក់លាក់ (ឧទាហរណ៍ ជួល ៣ ខែ១ឆ្នាំ) ខណៈផលុបភោគតម្រូវឲ្យមានអំឡុងពេលជាក់លាក់ដែរ ប៉ុន្តែអំឡុងពេលអត្ថិភាពនៃផលុបភោគអាចត្រូវបានកំណត់ឲ្យចប់ ដោយផ្អែកលើការកើតឡើងនៃព្រឹត្តិការណ៍ណាមួយដែលបានព្រមព្រៀងគ្នា (ឧទាហរណ៍ ផលុបភោគលើដីដំណាំមួយ ត្រូវចប់នៅពេលផុតរដូវភ្លៀង)។

ក្នុងការអនុវត្តជាក់ស្តែង គេស្គាល់ និងអនុវត្តភតិសន្យាច្រើន រួមទាំងការអនុវត្តជាមួយរដ្ឋបាលសុរិយោដីតាមរយៈការចុះបញ្ជី(សិទ្ធិជួលអចិន្ត្រៃយ៍)។ គេពុំសូវឃើញការចុះបញ្ជីផលុបភោគ តែតាមជាក់ស្តែង ផលុបភោគក៏ត្រូវបានប្រើប្រាស់ច្រើនដែរ គ្រាន់តែគេអាចមិនបានដឹងថាខ្លួនកំពុងប្រើ។ ឧទាហរណ៍ បុគ្គលម្នាក់អនុញ្ញាតឲ្យបងប្អូនរបស់ខ្លួនរស់នៅ និងប្រើទឹកអូរដែលហូរជាប់ដី និងផ្ទះទំនេររបស់ខ្លួនមួយ ដោយមិនគិតថ្លៃអ្វី។ ជាក់ស្តែង គេអាចយល់ថា ម្ចាស់ផ្ទះក៏មិនបានគិតដល់ការជួលអ្វីឡើយ។ ដូច្នេះចំណងបែបនេះអាចត្រូវបានចាត់ទុកជា

ផលុបភោគ។ ដូចគ្នាដែរម្ចាស់កម្មសិទ្ធិអនុញ្ញាតិឲ្យបងប្អូន ឬអ្នកស្គាល់គ្នាទៅរស់នៅ និងធ្វើចំការលើដីទំនេររបស់ខ្លួន។ ការយល់ច្បាស់អំពីផលុបភោគអាចឲ្យភាគីទាំងសងខាងយល់ច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរៀងៗខ្លួន (ឧទាហរណ៍ ករណីដូចបានពិក្សាខាងលើ៖ សិទ្ធិក្នុងការទាមទារ ឬបង្ការកុំឲ្យមានការរារាំងកាតព្វកិច្ចជូនដំណឹងទៅម្ចាស់អចលនវត្ថុនៅពេលមានការទាមទារអះអាងណាមួយពីតតិយជន ឬការទទួលខុសត្រូវតាមច្បាប់នៅពេលមានការខូចខាត ឬអន្តរាយណាមួយ) និងចៀសវាងផលវិបាកផ្លូវច្បាប់ (ជាពិសេសដោយសារជាសិទ្ធិប្រត្យក្សផង) ដែលអាចកើតមាននៅពេលចំណាងគតិយុត្តមិនត្រូវបានកំណត់ និងយល់ច្បាស់លាស់ ។ ឧទាហរណ៍ រស់នៅលើដីយូរៗទៅ ផលុបភោគី (អ្នកដែលគេឲ្យរស់នៅ និងធ្វើចំការលើដីមួយកន្លែង) មានបំណងអះអាងយកកម្មសិទ្ធិលើដីតែម្តង ដោយមូលហេតុផ្សេងៗ (ដូចជាការកាន់កាប់និងប្រើប្រាស់ជាក់ស្តែងជាសាធារណៈជាដើម)។ ជាគោលការណ៍ បើបានព្រមព្រៀងច្បាស់លាស់ ឬបានចុះបញ្ជីត្រឹមត្រូវ ទោះផលុបភោគីរស់នៅលើដី ២០ ឬ៥០ឆ្នាំ ក៏នោះនៅតែជាសិទ្ធិផលុបភោគទៅតាមការដែលបានកំណត់។

# ច្បាប់អន្តរជាតិ

# តើគ្រប់កិច្ចព្រមព្រៀងទាំងអស់ត្រូវឆ្លងការអនុម័តយល់ព្រមពីសភា ដើម្បីឲ្យកម្ពុជាអាចក្លាយជាភាគីឬ?

ដោយ បណ្ឌិត មាស បូរ៉ា* និង ម៉ៅ គីមប៉ាវ*

## ១. សេចក្តីផ្តើម

នៅក្នុងរចនាសម្ព័ន្ធនៃអំណាចរដ្ឋ រដ្ឋសភា ក្រៅអំពីតួនាទីធ្វើច្បាប់ ក៏ចូលរួមផងដែរក្នុងការផ្តល់ការយល់ព្រម ឲ្យរដ្ឋចូលជាភាគី នៃកិច្ចព្រមព្រៀងអន្តរជាតិណាមួយ។ សំណួរអាចចោទឡើងថា៖ តើការចូលរួមអនុម័តយល់ព្រមរបស់សភា ត្រូវមានសម្រាប់គ្រប់ប្រភេទ នៃកិច្ចព្រមព្រៀងអន្តរជាតិ ឬ សម្រាប់ប្រភេទកិច្ចព្រមព្រៀងជាក់លាក់ណាមួយ?

ការពិនិត្យមើលមាត្រាមួយចំនួន ពាក់ព័ន្ធនឹងសមាសធាតុនៃច្បាប់អន្តរជាតិក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់កម្ពុជា ការចោទជាសំណួរដូចនេះ មានអំណះអំណាងអាចចោទឆ្លើយបាន (Arguable Argument)។ អត្ថបទខ្លីនេះនឹងព្យាយាមបំភ្លឺនូវបញ្ហាដែលបានចោទ។ គំនិតទស្សនៈនេះមិនមែនជាការជ្រៀតជ្រែកសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។ នេះគ្រាន់តែជាការបញ្ចេញគំនិតជាបុគ្គល និងមិនតំណាងឲ្យស្ថាប័នដែលអ្នកនិពន្ធបម្រើការងារ ដើម្បីគោលបំណងតែមួយគត់គឺ ចូលរួមបញ្ជាក់ខ្លឹមសារនៃច្បាប់។

## ២. ខ្លឹមសារ

### ២.១. ការអនុវត្តជាអន្តរជាតិ

តាមខ្លឹមសារសន្ធិសញ្ញា (Treaty) ត្រូវបានផ្តល់ន័យថាគឺជា *កិច្ចព្រមព្រៀងអន្តរជាតិដែលអនុម័តរវាងរដ្ឋជាលាយលក្ខណ៍អក្សរ និងគ្រប់គ្រងដោយច្បាប់អន្តរជាតិ ទោះបីក្នុងឯកសារតែមួយ ឬឯកសារពាក់ព័ន្ធច្រើន និងក្នុងទម្រង់ជាក់លាក់ណាមួយក្តី*។[59] ក្នុងន័យនេះមិនមែន

---

* លោកមេធាវី មាស បូរ៉ា ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈត្តករពាណិជ្ជកម្ម និងសាស្ត្រាចារ្យច្បាប់។ អរគុណ និស្សិត រដ្ឋា ពិសិដ្ឋ ដែលបានជួយពិនិត្យ មើលអក្ខរាវិរុទ្ធ ក្នុងអត្ថបទនេះ។

* លោក ម៉ៅ គីមប៉ាវ ជានិស្សិតឆ្នាំទី ២ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។

[59] (a) "treaty" means an international agreement concluded between States in written form and governed by international law, whether embodied in a single instrument or in two or more related instruments and

លុះត្រាតែឈ្មោះ ឯកសារជាសន្ធិសញ្ញាទើបគេហៅថាសន្ធិសញ្ញាទេ។ វាអាចមានឈ្មោះជាកិច្ចព្រមព្រៀង (Agreement) អនុសញ្ញា (Convention) កតិកាសញ្ញា (Covenant) កិច្ចព្រមព្រៀងបញ្ចប់ជម្លោះ(Pact) អនុស្សារណៈយោគយល់គ្នា(Memorandum of Understanding: MoU) ឬពិធីសារ (Protocol)។[60] អ្វីដែលសំខាន់គឺខ្លឹមសារនៃឯកសារដែលនាំឲ្យគេចាត់ថា ជាសន្ធិសញ្ញា។ សន្ធិសញ្ញា គឺជាពាក្យទូទៅ។ គេអាចកត់សម្គាល់ទៀតថា ជួនកាលការដាក់ឈ្មោះ លើឯកសារណាមួយជាអ្វីធ្វើឡើងតាមការដែលភាគីឯកភាពចង់បាន។

សន្ធិសញ្ញា ឬកិច្ចព្រមព្រៀង ត្រូវបានចាត់ជាទ្វេភាគី[61](Bilateral) ឬពហុភាគី[62] (Multilateral)ដែលខាងក្រោយនេះមានកម្រិតសកល[63](Universal) ឬតំបន់[64](Regional) និងតាមវិស័យជាក់លាក់ណាមួយ ឬទូទៅ[65]។

សម្រាប់ការចូលជាភាគី វាអាស្រ័យទៅតាមខ្លឹមសារដែលឯកភាពនៅក្នុងសន្ធិសញ្ញាដែលភាគីបានចែង និងកំណត់[66]។ កិច្ចព្រមព្រៀងទ្វេភាគី នឹងចូលជាធរមានក្រោយពីចុះហត្ថលេខា និងផ្លាស់ប្តូរឯកសារគ្នា[67] ឬជួនកាលក្រោយពីចុះហត្ថលេខា ហើយភាគីនីមួយៗបានបំពេញតាមលក្ខខណ្ឌក្នុងស្រុកតម្រូវដើម្បីឲ្យកិច្ចព្រមព្រៀងចូលជាធរមាន៖ កិច្ចព្រមព្រៀងគ្នានេះនឹងមានប្រសិទ្ធភាពនៅថ្ងៃខែឆ្នាំ ដែលទទួលបាននូវការបញ្ជាក់ជាលាយលក្ខណ៍អក្សរចុងក្រោយដោយភាគីទាំងពីរបញ្ជាក់គ្នាទៅវិញទៅមកតាមរយៈកំណត់ទូត នៃការបំពេញនីតិវិធីច្បាប់របស់

whatever its particular designation; United Nations, *Vienna Convention on the Law of Treaties*, 23 May 1969, United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld.org/docid/3ae6b3a10.html [accessed 2 July 2019] (VCLT).

[60] Duncan B. Hollis, ed., The Oxford Guide to Treaties, 2012, Defining Treaties, p. 11.

[61] Treaty on Extradition between Pakistan and the United Kingdom, 1935.

[62] UN General Assembly, *Convention on the Rights of the Child*, 20 November 1989, United Nations, Treaty Series, vol. 1577, p. 3, available at: https://www.refworld.org/docid/3ae6b38f0.html [accessed 4 July 2019.

[63] United Nations, *Charter of the United Nations*, 24 October 1945, 1 UNTS XVI, available at: https://www.refworld.org/docid/3ae6b3930.html [accessed 4 July 2019] UN Charter

[64] African Charter on Human and People's Rights (Banjul Charter), Organization of African Unity (OAU), *African Charter on Human and Peoples' Rights ("Banjul Charter")*, 27 June 1981, CAB/LEG/67/3 rev. 5, 21 I.L.M. 58 (1982), available at: https://www.refworld.org/docid/3ae6b3630.html [accessed 4 July 2019].

[65] UN General Assembly, *Convention on the Rights of Persons with Disabilities: resolution / adopted by the General Assembly*, 24 January 2007, A/RES/61/106, available at: ttps://www.refworld.org/docid/45f973632.html [accessed 4 July 2019].

[66] Article 43: The present Convention shall be subject to ratification by signatory States and to formal confirmation by signatory regional integration organizations. It shall be open for accession by any State or regional integration organization which has not signed the Convention, see id.,.

[67] Glossary of terms relating to treaty actions, ratification, https://treaties.un.org/Pages/Overview.aspx?path=overview/glossary/page1_en.xml#ratification

ជាតិរៀងៗខ្លួនដែលតម្រូវសម្រាប់ការចូលជាធរមាន...[68]។ សម្រាប់កិច្ចព្រមព្រៀង ពហុភាគីក៏ដូចគ្នាដែរ។

សន្ធិសញ្ញាខ្លះតម្រូវឲ្យរដ្ឋចុះហត្ថលេខាជាមុនសិន រួចផ្តល់សច្ចាប័ន (Ratification) ឬទទួលយក (Accession) ដើម្បីឲ្យសន្ធិសញ្ញាចូលជាធរមាន។[69] វិធីខាងក្រោយនេះសម្រាប់រដ្ឋមិនបានចុះហត្ថលេខា ដែលសន្ធិសញ្ញាចូលជាធរមានជាអន្តរជាតិរួចទៅហើយ។[70] វាក៏កើតមានផងដែរនូវករណី ដែលរបបមុនបានចុះហត្ថលេខា ហើយរបបក្រោយមិនចង់ទទួលស្គាល់ការចុះហត្ថលេខា និងចង់ចូលជាភាគីដោយប្រើពាក្យ "ទទួលយក" ។ អ្នកជំនាញរបស់អង្គការសហប្រជាជាតិ បានយោងដល់សន្ធិសញ្ញា ហើយអះអាងថា ក្នុងករណីនេះត្រូវបើពាក្យ "សច្ចាប័ន" ។ នេះមានន័យថា បើសន្ធិសញ្ញាចែងថាយ៉ាងម៉េច រដ្ឋត្រូវតែគោរពតាម។ ករណីរដ្ឋមិនចង់ប្រើពាក្យ "សច្ចាប័ន" រដ្ឋអាចបដិសេធ នូវហត្ថលេខា ដោយរបបមុន ហើយអាចទទួលយកសន្ធិសញ្ញា។ ទោះបីជាយ៉ាងនេះក្តី កត្តាផ្លូវច្បាប់អាចមានភាពស្មុគ្រស្មាញហួសពីការរំពឹងទុក។

ទោះបីជាសន្ធិសញ្ញាប្រើពាក្យ "សច្ចាប័ន" ជាវិធីសាស្ត្រឲ្យរដ្ឋក្លាយជាភាគីក្តី វាជារឿងផ្ទៃក្នុងរបស់រដ្ឋ។ រដ្ឋអាចសម្រេចអនុម័តយល់ព្រមត្រឹមកម្រិតរដ្ឋាភិបាល ឬសភា។[71] ច្បាប់អន្តរជាតិ មិនបានតម្រូវថា "សច្ចាប័ន" *ជាការអនុម័តយល់ព្រមពីសភាទេ* បើទោះបី មានការយល់ឃើញជាទូទៅថា "ការផ្តល់សច្ចាប័ន" ជាការអនុម័យយល់ព្រមដោយសភា។ អ្វីដែលសំខាន់ គឺអាស្រ័យទៅតាមការឯកភាពគ្នារបស់រដ្ឋភាគី។ រដ្ឋអាចកំណត់ ថាកិច្ចព្រមព្រៀងនេះ ត្រូវផ្តល់*សច្ចាប័នដោយសភា*។ ស្រដៀងគ្នានេះ វាមិនតម្រូវថា បើរដ្ឋមួយអនុម័តយល់ព្រមពីសភា រដ្ឋមួយទៀតត្រូវឆ្លងសភាដែរ ដើម្បីមានភាពស្មើគ្នានោះទេ។ រដ្ឋអាចធ្វើយ៉ាងនេះ ក៏ប៉ុន្តែមិនមានមូលដ្ឋានច្បាប់ណាបង្ខំដូចនេះទេ។ ប្រទេសមួយចំនួនបានចែកប្រភេទសន្ធិសញ្ញា និងវិធីសាស្ត្រដែលឯកសារក្លាយជាធរមានសម្រាប់រដ្ឋ។ វាអាចជាកិច្ចព្រមព្រៀងប្រតិបត្តិ (Executive Agreement)[72] ឬ កិច្ចព្រមព្រៀងផ្សេងពីនេះដែលអាចជាសន្ធិសញ្ញា។ កិច្ចព្រមព្រៀងប្រភេទ

---

[68] អនុស្សារណៈនៃការយោគយល់រវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋតួកគី ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម, ឆ្នាំ ២០១៩, មាត្រា ៨។

[69] The Treaty Section of the Office of Legal Affairs, Treaty Handbook, 2012, p.10.

[70] Glossary of terms relating to treaty actions, accession, https://treaties.un.org/Pages/Overview.aspx?path=overview/glossary/page1_en.xml#ratification.

[71] (b) "ratification", "acceptance", "approval" and "accession" mean in each case the international act so named whereby a State establishes on the international plane its consent to be bound by a treaty, see https://www2.ohchr.org/english/bodies/treaty/glossary.htm

[72] Daniel Bodansky and Peter Spiro, Executive Agreement, 49 (4) Vanderbilt Journal of Transnational Law, 2016, p. 928.

ទីមួយនេះ ចែងអំពីកិច្ចសហប្រតិបត្តិការ ឬអនុវត្តកិច្ចព្រមព្រៀងដទៃទៀត។[73] វានឹងចូលជាធរមាន ដោយក្រឹត្យរបស់ប្រមុខរដ្ឋ ឬប្រធានាធិបតី។[74] ប្រភេទទីពីរ ចែងអំពីកាតព្វកិច្ចរបស់រដ្ឋ ដែលទាមទារឲ្យមានការអនុម័តពីសភា(ប្រទេសកម្ពុជា) ជាមុន ឬក្រោយ (ប្រទេសអង់គ្លេស)[75] ដើម្បីឲ្យសន្ធិសញ្ញាចូលជាធរមាន (ប្រទេសបារាំង)[76] ឬអាចអនុវត្តក្នុងស្រុកបាន (ប្រទេសអង់គ្លេស)។[77]

ច្បាប់ ឬការអនុវត្តរបស់រដ្ឋ បង្ហាញពីមូលដ្ឋានផ្សេងគ្នា នូវប្រភេទសន្ធិសញ្ញាដែលតម្រូវឲ្យមានការអនុម័តយល់ព្រមពីសភា ដូចជាសន្ធិសញ្ញាពាក់ព័ន្ធអធិបតេយ្យភាព(ព្រំដែន)[78] បញ្ចប់សង្គ្រាម[79] បង្កើនបន្ទុកថវិកាជាតិ[80]ប៉ះដល់សិទ្ធិសេរីភាពបុគ្គល[81] ទាមទារការធ្វើវិសោធនកម្មច្បាប់ ឬធ្វើច្បាប់ថ្មី។[82] ទាំងនេះទំនងជាចូលក្នុងសមត្ថកិច្ចរបស់សភា ឧទាហរណ៍មូលដ្ឋានចុងក្រោយគេ។ ក្រៅពីមូលហេតុដទៃទៀត ការតម្រូវនេះទំនងជាបំពេញនូវគោលការណ៍បែងចែកអំណាច (Separation of Powers) រារាំងកុំឲ្យមានការបំពានការងារសភា ដែលមានតួនាទីធ្វើច្បាប់ (នីតិប្បញ្ញត្តិ) ដោយអំណាចប្រតិបត្តិ។[83]

ចុងក្រោយ តាមទ្រឹស្តី កាតព្វកិច្ចក្នុងអនុស្សារណៈ ឬកិច្ចព្រមព្រៀងប្រតិបត្តិ ចងដល់ស្ថាប័ន នៃអំណាចទាំងបីរបស់រដ្ឋ អាស្រ័យហេតុនេះ ប្រសិនបើស្ថាប័ន (ក្រសួង) បានបំពាន ឬខកខានមិនបានបំពេញកាតព្វកិច្ច ទោះបីចែងក្នុងអនុស្សារណៈក្តី ជាទ្រឹស្តីសុទ្ធតែនាំឲ្យរដ្ឋទាំងមូលទទួលខុសត្រូវ។[84]

---

[73] Robert E. Dalton, United States in Duncan B. Hollis, National Treaty Law and Practice, 2005, p. 780.

[74] Ukraine's presidential decree on ending friendship treaty with Russia takes effect, http://www.xinhuanet.com/english/2018-09/19/c_137479777.htm

[75] Transformation Act, Sir Ian Sinclair, United Kingdom in Duncan B. Hollis, National Treaty Law and Practice, 2005P. 733.

[76] Pierre Michael Eisemann, France, in Duncan B. Hollis, National Treaty Law and Practice, 2005, p. 254.

[77] Transformation Act, Sir Ian Sinclair, United Kingdom in Duncan B. Hollis, National Treaty Law and Practice, 2005P. 733.

[78] ច្បាប់រដ្ឋធម្មនុញ្ញប្រទេសបារាំងឆ្នាំ ១៩៥៨, មាត្រា ៥៣។

[79] បទប្បញ្ញត្តិប្រធានាធិបតី ឆ្នាំ២០០៩ ស្តីពី ការចុះហត្ថលេខា ការទទួលយក និងអនុវត្តសន្ធិសញ្ញាអន្តរជាតិ, មាត្រា ២៩។

[80] ដូចលេខយោងទី ២១

[81] ដូចលេខយោងទី២១

[82] រដ្ឋច្បាប់ឆ្នាំ ២០០៥ របស់ វៀត ណាម ស្តីពី ការអនុម័ត ការទទួលយក និងការអនុវត្តសន្ធិសញ្ញា, មាត្រា ៣១។ រដ្ឋធម្មនុញ្ញប្រទេសថៃ ឆ្នាំ ២០១៧, ផ្នែក ១៧៨

[83] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ៥១

[84] យោបល់ទូទៅលេខ ៣១ ស្តីពីប្រភេទ និងកាតព្វកិច្ចទូទៅរបស់រដ្ឋ , CCPR/C/21/Rev.1/Add. 13, 2004, para. 4.

## ២.២. ករណីកម្ពុជា

ក្នុងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានមាត្រាមួយចំនួនពាក់ព័ន្ធដូចជា មាត្រា៨(២), មាត្រា២៦ថ្មី, មាត្រា៣១, មាត្រា៥៥ និងមាត្រា៩០ថ្មី (ពីរ), មាត្រា១៧ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ឆ្នាំ២០០៧ ដែលត្រូវបានចាត់ថាជាសេចក្តីសម្រេចឈានមុខ (Landmark) ពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងក្នុងព្រះរាជាណាចក្រកម្ពុជា។ មាត្រាទាំងអស់នេះបានប្រើប្រាស់ ឬយោងដល់ធម្មនុញ្ញអង្គការសហប្រជាជាតិ, សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨, កតិកាសញ្ញា និងអនុសញ្ញា (មាត្រា៣១), សន្ធិសញ្ញា, កិច្ចព្រមព្រៀង (មាត្រា៥៥ និង មាត្រា១៧) តែមិនមានប្រើពាក្យ “អនុស្សារណៈ" ទេ។

អ្វីជាសន្ធិសញ្ញា ត្រូវបានផ្តល់និយមន័យដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ និងមានក្នុងសន្ទានុក្រមភ្ជាប់នឹងក្រមរដ្ឋប្បវេណី។ គេអាចអះអាងថា និយមន័យនេះទទួលយកដោយរដ្ឋសភា។ អត្ថន័យនៃពាក្យ **សន្ធិសញ្ញា** ស្រដៀងនឹងមាត្រា២ នៃសន្ធិសញ្ញា ស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ១៩៦៩ របស់អង្គការសហប្រជាជាតិ។ **សន្ធិសញ្ញា** ជាកិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងជាលាយលក្ខណ៍អក្សររវាងរដ្ឋ និងរដ្ឋ រវាងរដ្ឋនិងអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិ ហើយស្ថិតនៅក្រោមការគ្រប់គ្រងនៃនីតិអន្តរជាតិសាធារណៈ ទោះបីជាកិច្ចព្រមព្រៀងនោះមានឈ្មោះជាអ្វីក៏ដោយ (ធម្មនុញ្ញ សន្ធិសញ្ញា អនុសញ្ញា កតិកាសញ្ញា...) ដើម្បីបង្កើតអានុភាពគតិយុត្ត។[85]

ក្នុងចំណោមមាត្រាទាំងអស់ មានមាត្រាចំនួនពីរដែលពាក់ព័ន្ធ៖ មាត្រា២៦ និងមាត្រា៩០។ *ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើ<u>សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ</u> ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភា។ មាត្រា៩០៖ <u>រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។</u>*[86]

តាមទ្រឹស្តីនៃការបកស្រាយសន្ធិសញ្ញា ក្រោយពីពិនិត្យមើលខ្លឹមសារ តាមអត្ថន័យនៃពាក្យ នៅតែមិនមានចម្លើយគេអាចពិនិត្យមើលនូវកំណត់ត្រា នៃកិច្ចពិភាក្សាធ្វើច្បាប់ (travaux preparatoire) ក្នុងន័យផ្តល់ការគាំទ្រដល់ខ្លឹមសារ នៃការបកស្រាយពាក្យក្នុងមាត្រា។[87]

[85] សន្ទានុក្រមភ្ជាប់នឹង ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧។

[86] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ៩០។

[87] VCLT, *supra* note 1, Article 31.

លទ្ធផលនៃការពិនិត្យកំណត់ត្រា បង្ហាញន័យខុសពី បំណងនៃឯកសារច្បាប់ ឬន័យមិនសមស្របនឹងមិនត្រូវប្រកាន់យកឡើយ។[88] យុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ (International Court of Justice) អះអាងថា ការពិនិត្យលើកំណត់ត្រា មិនបានបំភ្លឺខ្លឹមសារ និងមិនខ្វាស់នឹងខ្លឹមសារ ទាញចេញពីការបកស្រាយខ្លឹមសារមាត្រាពាក់ព័ន្ធទេ ដូចនេះត្រូវរក្សាលទ្ធផលនៃការបកស្រាយ។[89] តាមទ្រឹស្តីនៃការបកស្រាយសន្ធិសញ្ញា គេអាចអះអាងថា ប្រសិនបើសភាមានចេតនាបញ្ចូលអនុស្សារណៈ ក្នុងមាត្រា៩០ សភានឹងសរសេរបញ្ចូលហើយ។

មានទំនាស់គ្នារវាងអ្នកស្រាវជ្រាវថា គ្រប់កិច្ចព្រមព្រៀងទាំងអស់ត្រូវឆ្លងការអនុម័តយល់ព្រមពីសភាឬយ៉ាងណា? ក្រុមម្ខាងផ្អែកលើមាត្រា២៦ និងមាត្រា៩០ ហើយបានអះអាងថាប្រសិនបើឯកសារមានឈ្មោះថាជា អនុស្សារណៈមិនចាំបាច់ឆ្លងសភាទេ តែប្រសិនបើជាសន្ធិសញ្ញា ឬអនុសញ្ញាត្រូវឆ្លងសភាដើម្បីកុំឲ្យខុសរដ្ឋធម្មនុញ្ញ។ ក្រុមម្ខាងទៀតអះអាងថា មាត្រាទាំងពីរមិនបាននិយាយដល់កិច្ចព្រមព្រៀង ឬអនុស្សារណៈយោគយល់គ្នាទេ ដូចនេះមិនចាំបាច់ដាក់ឯកសារទាំងពីរប្រភេទនេះ ឆ្លងសភាទេ។

ប្រសិនបើគេឯកភាពលើ និយមន័យនៃសន្ធិសញ្ញា ដកស្រង់ខាងលើ សន្ធិសញ្ញា ឬអនុសញ្ញា គឺសុទ្ធតែជាកិច្ចព្រមព្រៀង ហើយច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក៏បានប្រើពាក្យ **កិច្ច-ព្រមព្រៀង** ផងដែរ។ ដូចនេះ កិច្ចព្រមព្រៀងទាំងអស់ត្រូវឆ្លងសភា។ ការពិនិត្យមើលប្រវត្តិនៃកិច្ចពិភាក្សាមាត្រា២៦ និងមាត្រា៩០ មិនបានផ្តល់ចម្លើយអ្វីទេ។ មាត្រាទាំងពីរត្រូវបានលើកយកមកអាន តែមិនទទួលបានការពិភាក្សា។[90] ដូចនេះ លទ្ធផលបានពីការបកស្រាយតាមខ្លឹមសារនៃមាត្រា២៦ និង មាត្រា៩០ ត្រូវរក្សាទុក។

ក្រុមទាំងពីរអះអាងថា កិច្ចព្រមព្រៀងខ្លះមានខ្លឹមសារដូចជា អនុស្សារណៈ។[91]ឯកសារខ្លះមានចំណងជើងជាអនុស្សារណៈ តែខ្លឹមសារខាងក្នុងជាកិច្ចព្រមព្រៀង។ កិច្ចព្រមព្រៀងសុទ្ធ

---

[88] VCLT, *supra* note 1, Article 32.

[89] មាស បូរ៉ា, ការបកស្រាយច្បាប់, ទំ. ៣ និង៤, http://www.measboralaws.com/detail/721 (accessed on 15 July 2019).

[90] រដ្ឋសភា, កំណត់ហេតុពិស្តារ សម័យប្រជុំពេញអង្គ លើកទី ២ នៃសភាធម្មនុញ្ញ, ១៩៩៣។

[91] The agreement is a document in which two or more parties agreed upon to work together for a common objective, whereas the Memorandum of Understanding (MoU) is a written document which describes the terms of an agreement. The elements of an agreement are Offer, Acceptance while the elements of a MoU are Offer, Acceptance, Intention, and Consideration. The significant difference between An Agreement and a MoU is that an Agreement can be made enforceable in the court of law, but a MoU cannot be made enforceable, but however parties are bind by estoppel. An Agreement is of binding nature, whereas a MoU is binding upon the parties if the memorandum is signed in exchange for monetary consideration. The parties to the agreement have collateral rights, but the parties to MoU do not have collateral rights. An Agreement can be implied, but a MoU can never be implied. (google).

តែចងជាកាតព្វកិច្ច ក៏ប៉ុន្តែខ្លះគ្រាន់តែបង្កើតជាកាតព្វកម្រិតស្ថាប័នរដ្ឋាភិបាល ឬកាតព្វកិច្ចមិនធំដុំ(Cooperative Agreement) ដែលមិនចាំបាច់ឆ្លងសភាទេ។ វាអាស្រ័យទៅលើខ្លឹមសារ នៃឯកសារពាក់ព័ន្ធដើម្បីសម្រេចថាគួរឆ្លងសភា ឬមិនឆ្លង។ វាអាចត្រឹមត្រូវប្រសិនបើ វាពិតជាអនុស្សារណៈ យើងមិនចាំបាច់រំខានសភាទេ។ ដូចគ្នានេះដែរ សម្រាប់ប្រភេទនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការ។[92]

ជានិយាមកន្លងមក អ្នកជំនាញបានពិនិត្យមើលខ្លឹមសារនៃឯកសារជាជាងឈ្មោះ។ ឯកសារដែលបង្កើតត្រឹមតែកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន ឬស្ថាប័នកម្ពុជា និងរដ្ឋបរទេស និងមិនដាក់បន្ទុកថវិកានឹងមិនចាំបាច់ឆ្លងសភាទេ។[93] ប្រភេទឯកសារដទៃទៀតដែលឆ្លងសភាមាន កិច្ចព្រមព្រៀង ស្តីពី បត្យាប័ន[94] កិច្ចព្រមព្រៀងទ្វេភាគី ស្តីពីវិនិយោគជាដើម[95]។

ទាំងនេះស្រដៀងប្រទេសផ្សេងទៀត ដូចជាសហរដ្ឋអាមេរិក ឬប្រទេសក្នុងអាស៊ានមានថៃ និងវៀតណាម ដែលកំណត់ថា កិច្ចព្រមព្រៀងប្រភេទណាសម្រេចចូលជាធរមាន ត្រឹមកម្រិតរដ្ឋាភិបាល។[96]

## ៣. សង្ខេប

ទោះបីជាមានទស្សនៈស្រាយបំភ្លឺដូចខាងលើពិតមែន ដោយបង្ហាញថា គ្រប់កិច្ចព្រមព្រៀង ដែលចុះហត្ថលេខាដោយនីតិប្រតិបត្តិ មិនចាំបាច់ឆ្លងសភានោះទេ វាក៏នៅតែមានបញ្ហាមិនឯកភាព រវាងក្រុមមនុស្សដែលសង្កត់ធ្ងន់លើខ្លឹមសារ និងក្រុមដែលផ្តោតលើឈ្មោះនៃកិច្ចព្រមព្រៀងអន្តរជាតិ ដើម្បីកំណត់ថា តើមានការតម្រូវឲ្យឆ្លងសភាឬទេ។

ដើម្បីជម្រះមន្ទិល អនុក្រឹត្យ ស្តីពី បែបបទ និងនីតិវិធីនៃការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដែលបានកំណត់ក្នុងមាត្រា១៧ នៃច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃ

---

92 កិច្ចព្រមព្រៀង ស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៃធនាគារជាតិនៃកម្ពុជា និងអង្គភាពត្រួតពិនិត្យសេវាហិរញ្ញវត្ថុសហព័ន្ធរុស្ស៊ី ស្តីពីការផ្លាស់ប្តូរព័ត៌មានហិរញ្ញវត្ថុពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម,ឆ្នាំ ២០១៦។

93 ដូចលេខយោងទី៣៤។

94 សន្ធិសញ្ញា ស្តីពី បត្យាប័នរវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម,ឆ្នាំ ២០១៣។

95 កិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ, ឆ្នាំ ២០១៤។

96 Robert E. Dalton, *supra* note 15, p. 780.

គណៈរដ្ឋមន្ត្រី គួរត្រូវបានរៀបចំឡើង ទោះបីវាមិនមែនជាច្បាប់ ដូចប្រទេសវៀតណាមក្តី។ បន្ថែមពីលើនេះ លទ្ធភាពនៃការជម្រះមន្ទិល អាចត្រូវធ្វើឡើងតាមរយៈសំណើមួយ ដោយស្ថាប័ន ឬមន្ត្រីមានសមត្ថកិច្ច អនុលោមតាមច្បាប់ ស្នើដល់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ដើម្បីបំភ្លឺថា ពាក្យ **សន្ធិសញ្ញា** ក្នុងមាត្រា៩០ថ្មី រាប់បញ្ចូលកិច្ចព្រមព្រៀងដែរឬទេ។ ប្រសិនបើដូចនេះមែន តើគ្រប់កិច្ចព្រមព្រៀងទាំងអស់ត្រូវតែឆ្លងសភា ឬយ៉ាងណា?

# ការជំនុំជម្រះក្តីដោយយុត្តិធម៌

# សិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌នៅកម្ពុជា

ដោយលោក សយ គឹមសាន*

**អាពអយុត្តិធម៌នៅកន្លែងមួយ គឺជាការគំរាមកំហែងយុត្តិធម៌នៅគ្រប់កន្លែង**

លោក Martin Luther King

## ១. សេចក្តីផ្តើម

ដោយយោងតាមតុលាការនៃទីក្រុងស្ត្រាសប៊ួរ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជា "គោលការណ៍មូលដ្ឋាននៃនីតិរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យ និងសំដៅធានាដល់សិទ្ធិទទួលបានការគ្រប់គ្រងត្រឹមត្រូវលើយុត្តិធម៌"។[97] ការគ្រប់គ្រងត្រឹមត្រូវលើយុត្តិធម៌អាចសំដៅលើនីតិវិធីរដ្ឋបាល ឬនីតិវិធីតុលាការ។[98] ការគ្រប់គ្រងនេះសំដៅការពារបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌពីការបន្ថយ ឬដកហូតសិទ្ធិ និងសេរីភាពមូលដ្ឋានតាមអំពើចិត្ត។[99] ហេតុដូច្នេះ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ការភាពអយុត្តិធម៌ តាមរយៈការការពារអ្នកគ្មានកំហុសពីការផ្តន្ទាទោសខុស និងការធានាថាភាពជាប់ពិរុទ្ធត្រូវទទួលទោសតាមបទល្មើសដែលបានប្រព្រឹត្ត។

---

*លោក សយ គឹមសាន ជាអ្នកស្រាវជ្រាវ នៃមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនីតិមនុស្សធម៌ (Center for the Study of Humanitarian Law) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

97 Leanza, P & Pridal, O 2014, *សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស* កថាខណ្ឌ 1.01(ខ)

98 Doebbler, CFJ 2006, *សេចក្តីផ្តើមនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ* ទីក្រុងវ៉ាស៊ីងតោន ការបោះពុម្ពផ្សាយរបស់ CD កថាខណ្ឌ 108

99 មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន (ECHR) អនុម័តនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ ចូលជាធរមាននៅថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៥៣។ មាត្រា ១៤ នៃកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ស្របតាមសេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិលេខ 2200A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៦។

លើសពីនេះ ការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទជាខ្សែម៉ែត្រសំខាន់មួយសម្រាប់វាយតម្លៃពីភាពគួរជឿបាន និងសេចក្តីថ្លៃថ្នូរនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។[100] ប្រសិនបើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវបានគោរព និងការពារ សាធារណជននឹងបាត់បង់ជំនឿទៅលើប្រព័ន្ធយុត្តិធម៌ ហើយអំណាចគ្រប់គ្រងដោយបុគ្គលនឹងមានប្រៀបទៅលើអំណាចនីតិរដ្ឋ។ អាស្រ័យហេតុនេះ យើងអាចនិយាយបានថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គឺជាគោលការណ៍មូលដ្ឋាននៃសង្គមដ៏ត្រឹមត្រូវមួយ។

ទស្សនៈស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" ភ្ជាប់គ្នាដោយមិនអាចកាត់ផ្តាច់បានទៅនឹងទស្សនៈស្តីពី "យុត្តិធម៌"។ ការយល់ដឹងពីទស្សនៈស្តីពី "យុត្តិធម៌" ក៏ដូចជា "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" គឺមានលក្ខណៈងាយស្រួល និងស្មុគស្មាញខ្លាំងដោយសារតែវាមានអត្ថន័យច្រើន និងខុសៗគ្នាទៅតាមទស្សនៈផ្សេងៗគ្នានៃច្បាប់ ក្រមសីលធម៌ នយោបាយ សេដ្ឋកិច្ច និងសង្គមវិទ្យា។[101] ក៏ប៉ុន្តែ ដើម្បីធានាភាពស្មើភាពនៅក្នុងនីតិវិធីព្រហ្មទណ្ឌ វាជាការសំខាន់ណាស់ដែលចៅក្រមត្រូវសម្រេចចិត្តដោយមិនលំអៀង ផ្អែកលើគោលការណ៍ច្បាប់ និងស្តង់ដារជំនុំជម្រះដោយយុត្តិធម៌ជាជាងការយល់ឃើញដោយមិនមានការពិចារណា។ ជំពូកនេះព្យាយាមផ្តល់នូវការបកស្រាយ និងការវិភាគដោយសង្ខេបពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ដោយមានការប្រៀបធៀបជាមួយនឹងស្តង់ដារអន្តរជាតិ។

ផ្នែកនេះនឹងពន្យល់បន្ថែមពីការអនុវត្តនៅកម្ពុជា និងច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាពិសេសរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌ)។ សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ និងអត្ថបទវិចារណកថានៃសន្ធិសញ្ញាទាំងនេះ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាឯកសារយោងសម្រាប់ការវាយតម្លៃច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងការអនុវត្តនៅកម្ពុជា។ ការអនុវត្តកើតចេញពីយុត្តាធិការផ្សេងៗ ដូចជារបាយការណ៍ពាក់ព័ន្ធក៏ត្រូវបានយកមកសំអាង និងប្រើប្រាស់ជាសូចនាករសំខាន់ដើម្បីស្វែងយល់ពីស្ថានភាពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា។ វិសាលភាពនៃជំពូកនេះត្រូវបានកម្រិតត្រឹមអភិក្រមផ្លូវច្បាប់ និងប្រធានបទមួយចំនួនដោយផ្អែកលើទស្សនៈរបស់អ្នកនិពន្ធស្តីពី បញ្ហាសិទ្ធិ

---

[100] Cassesse, A 1997, "អង្គជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គូស្លាវី និងសិទ្ធិមនុស្ស" *ការត្រួតពិនិត្យច្បាប់សិទ្ធិមនុស្សអឺរ៉ុប* បោះពុម្ពលើកទី ៤ កថាខណ្ឌ 333

[101] Leanza, P & Pridal, O 2014, សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស កថាខណ្ឌ 3

ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានចាត់ទុកថាពាក់ព័ន្ធបំផុតនៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន។

## ២.សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធ នឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងកាតព្វកិច្ចរបស់កម្ពុជា

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានទទួលស្គាល់ជាសកលថា ជាបទដ្ឋានជាមូលដ្ឋានបំផុតនៃនីតិសិទ្ធិមនុស្សអន្តរជាតិ និងត្រូវបានធានាក្រោមលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗជាច្រើន។[102] សិទ្ធិនេះមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៩(៣) និង ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលចែងថា "បុគ្គលណាដែលបានចាប់ខ្លួន .... នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម" និង "ជនគ្រប់រូប ត្រូវមានសិទ្ធិជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ"។[103] មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងពីស្តង់ដារអប្បបរមានៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលសិទ្ធិនេះជាសិទ្ធិទូលំទូលាយប្រមូលផ្តុំនូវសិទ្ធិមូលដ្ឋានដូចជា សិទ្ធិទៅតុលាការ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិស្មើភាពសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង សិទ្ធិទទួលបានការជំនុំជម្រះរហ័ស សិទ្ធិមានមេធាវី និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់។ សិទ្ធិទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក ហេតុដូចនេះការរំលោភបំពានលើសិទ្ធិណាមួយក៏អាចរំលោភបំពានសិទ្ធិផ្សេងទៀតដែរ។ ក៏ប៉ុន្តែ ទោះបីជាការជំនុំជម្រះប្រព្រឹត្តទៅយុត្តិធម៌ឬអត់ វាមិនតម្រូវឱ្យមានការគោរពសិទ្ធិ

[102] មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ; មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន; មាត្រា ១០ និងមាត្រា១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ217A (III) ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨; មាត្រា ៨ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ACHR) ដែលអនុម័តនៅសន្និសីទជំនាញអន្តរអាមេរិក ស្តីពីសិទ្ធិមនុស្ស ទីក្រុង San Jose ប្រទេសកូស្តារីកា ចូលជាធរមាននៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ១៩៧៨, មាត្រា ៧ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស (ACHPR) អនុម័តនៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ១៩៨១ OAU Doc. CAB/LEG/67/3 rev. 5, 21 I.L.M. 58 (១៩៨២) ចូលជាធរមាននៅថ្ងៃទី ២១ ខែតុលា ឆ្នាំ១៩៨៦, គោលការណ៍ទី ២០ នៃសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស អនុម័តដោយប្រមុខរដ្ឋ/រដ្ឋាភិបាលនៃរដ្ឋសមាជិកអា ស៊ាននៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១២។

[103] មាត្រា ៩(៣) និង ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ទទួលបានការជំនុំជម្រះគ្រប់ទិដ្ឋភាពនោះទេ អ្វីដែលចាំបាច់នោះគឺជនជាប់ចោទមានឱកាសស្មើគ្នាក្នុងការការពារខ្លួនផ្ទាល់។[104]

កម្ពុជាក្លាយជាសមាជិកនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២ ដោយសារមកពីលទ្ធផលនៃសន្និសញ្ញាសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១[105] ដែលបានបញ្ចប់ជម្លោះដ៏យូរអង្វែងជាផ្លូវការនៅកម្ពុជា និងសំដៅបង្កើតសន្តិភាព និងស្ថេរភាពជារៀងរហូត ដោយផ្អែកលើបទដ្ឋានសិទ្ធិមនុស្ស។ តាមការផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កម្ពុជាមានកាតព្វកិច្ចគោរព ការពារ និងលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

មាត្រា២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងជាទូទៅពីវិសាលភាពនៃកាតព្វកិច្ចផ្លូវច្បាប់របស់រដ្ឋជាសមាជិក។ ស្របតាមមាត្រានេះ កាតព្វកិច្ចផ្លូវច្បាប់របស់កម្ពុជាគឺ រួមបញ្ចូលស្តង់ដារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទៅក្នុងច្បាប់ និងគោលនយោបាយជាតិរបស់ខ្លួនដោយអនុម័តលើវិធានផ្លូវច្បាប់ តុលាការ រដ្ឋបាល អប់រំ និងវិធានសមស្របផ្សេងទៀតដើម្បីបំពេញតាមកាតព្វកិច្ចរបស់ខ្លួន។[106] កម្ពុជាត្រូវតែលើកកម្ពស់ការយល់ដឹងពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដល់មន្ត្រីរាជការ និងប្រជាជនទូទៅ។[107]

ក្នុងករណីមានវិវាទជាមួយនឹងច្បាប់ជាតិ មាត្រា២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតម្រូវឱ្យកម្ពុជាធ្វើវិសោធនកម្មលើច្បាប់ជាតិ ឬការអនុវត្តក្នុងស្រុក

---

[104] ចៅក្រម Shahabuddeen នៃអង្គជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសិទ្ធិមនុស្សបានលើកឡើងនៅក្នុងរឿងក្តី *The Prosecutor v Slobodan Milosevic* ថា «ភាពយុត្តិធម៌នៃអង្គជំនុំជម្រះមិនតម្រូវឲ្យភាពល្អតតខ្ចោះនោះទេ។ សំណួរចម្បងគឺថាតើជនជាប់ចោទទទួលបានឱកាសគ្រប់គ្រាន់ក្នុងការដេញដោលលើការចោទប្រកាន់មកលើរូបខ្លួនឬក៏អត់»។

[105] សម្រង់នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយប្រៀបធៀប សម្រាប់ជម្លោះនៅកម្ពុជា ចុះហត្ថលេខាដោយប្រទេសហត្ថលេខីនៃសន្និសីទទីក្រុងប៉ារីសស្តីពីកម្ពុជា ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងទទួលបានការគាំទ្រតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ S/RES/718 (1991) ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩១ និងស្របតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 46/18 ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩១

[106] អត្ថាធិប្បាយទូទៅលេខ31 [80] របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *លក្ខណៈនៃកាតព្វកិច្ចច្បាប់ទូទៅមានចំពោះប្រទេសដែលជាភាគីក្នុងកតិកាសញ្ញា* ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ លេខ CCPR/C/21/Rev.1/Add.13 [អត្ថាធិប្បាយទូទៅលេខ៣១] កថាខណ្ឌទី៧។

[107] អត្ថាធិប្បាយទូទៅលេខ៣១ កថាខណ្ឌទី៧

ដើម្បីបំពេញតាមស្តង់ដារអន្តរជាតិដែលដាក់ដោយការធានា នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[108] ក្នុងនាមជារដ្ឋហត្ថលេខីនៃសន្ធិសញ្ញាទីក្រុងវៀនស្តីពីច្បាប់សន្ធិសញ្ញា”[109] កម្ពុជាត្រូវតែគោរពតាមមាត្រា២៧ នៃសន្ធិសញ្ញានេះ ដោយមិនត្រូវសំអាងលើបទបញ្ញត្តិ នៃច្បាប់ជាតិដើម្បីអះអាងពីការខកខានមិនបំពេញកាតព្វកិច្ចតាមសន្ធិ-សញ្ញានោះទេ។ លើសពីនេះ កាតព្វកិច្ចរបស់កម្ពុជាមានវិសាលភាពដល់ស្ថាប័នចំណុះរាជរដ្ឋាភិបាលទាំងអស់ ដូចជាស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការ ក៏ដូចជាអាជ្ញាធរសាធារណៈពាក់ព័ន្ធផ្សេងទៀតនៅគ្រប់ជាន់ថ្នាក់។[110]

បន្ថែមពីនេះ ក្នុងនាមជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយកម្ពុជាមានកាតព្វកិច្ចធ្វើរបាយការណ៍ជាប្រចាំពីការចាត់វិធានការ ឬវឌ្ឍនភាពស្តីពីការអនុវត្តបទបញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរួមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ កម្ពុជាត្រូវធ្វើរបាយការណ៍ជារៀងរាល់ ៤ឆ្នាំម្តងទៅគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ស្ថាប័នចំណុះសន្ធិសញ្ញាដែលបង្កើតឡើងដើម្បីដើរតួតាមដានកិច្ចការទាំងនេះ។ យន្តការតាមដាននេះមិនមែនសំដៅរិះគន់រដ្ឋភាគីណាមួយទេ ពោលគឺសំដៅដោះស្រាយបញ្ហា និងផ្តល់អនុសាសន៍ដ៏មានអត្ថន័យ ហៅថា “ការអង្កេតឱ្យជាយោបល់” ទៅឱ្យរដ្ឋភាគីដើម្បីធានាថាមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់បុគ្គលដែលត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌ។ ដើម្បីធានាភាពត្រឹមត្រូវនៃស្ថានភាពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ក៏ទទួលបានរបាយការណ៍ជាប្រចាំពីភាគីពាក់ព័ន្ធ រួមមានអង្គការមិនមែនរដ្ឋា-ភិបាលជាតិ និងអន្តរជាតិ និងភ្នាក់ងារផ្សេងទៀតរបស់អង្គការសហប្រជាជាតិ។ ក៏ប៉ុន្តែចាប់តាំងពីការផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាំងពីឆ្នាំ១៩៩២មក កម្ពុជាបានធ្វើរបាយការណ៍ចំនួន២លើកប៉ុណ្ណោះ ទៅឱ្យគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ គឺនៅឆ្នាំ១៩៩៨ និង ឆ្នាំ ២០១៣។[111]

---

108 អត្ថាធិប្បាយទូទៅលេខ៣១ កថាខណ្ឌទី១៣

109 ប្រទេសកម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩។

110 អត្ថាធិប្បាយទូទៅលេខ៣១ ដូចកំណត់សម្គាល់ខាងលើលេខ១០ កថាខណ្ឌទី៤

111 សូមមើលស្ថានភាពនៃរបាយការណ៍ស្តីពីកម្ពុជាអនុវត្តកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ តាមរយៈតំណភ្ជាប់ http://cambodia.ohchr.org/EN/PagesFiles/TreatyReportingIndex.htm#ICCPR

ក្រៅពីកាតព្វកិច្ចតាមសន្ធិសញ្ញាទាំងនេះ រដ្ឋធម្មនុញ្ញរបស់កម្ពុជាអះអាងជាថ្មីយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយមានរួមបញ្ចូលស្តង់ដារសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់ជាតិ ដោយបានចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស"។[112] ដើម្បីដោះស្រាយការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនៅក្នុងតុលាការក្នុងស្រុកក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០៧ ថា ចៅក្រមខ្មែរត្រូវតែបានរំលឹកពីកាតព្វកិច្ចរបស់ខ្លួននៅពេលសម្រេចសេចក្តី ដោយគិតពិចារណាទៅលើគ្រប់ច្បាប់នៃព្រះរាជា-ណាចក្រកម្ពុជា "នៅក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញរបស់ប្រទេស និងសន្ធិសញ្ញាសិទ្ធិមនុស្សដែលធានាដោយរដ្ឋធម្មនុញ្ញ"។[113] ហេតុដូចនេះ អាចនិយាយបានថា ដោយរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេស សេចក្តីសម្រេចនេះចង្អុលបង្ហាញថាច្បាប់ជាតិទាំងអស់ត្រូវបានបកស្រាយ និងអនុវត្តក្នុងលក្ខខណ្ឌដែលមិនត្រូវផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។

## ៣. ការអនុវត្តស្តង់ដារជំនុំជម្រះដោយយុត្តិធម៌នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ

ដោយហេតុថាសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌ត្រូវតែតាមដាននៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌចាប់តាំងពីការចាប់ខ្លួនរហូតដល់ ការចេញសាលក្រមចុងក្រោយ ការវិភាគគ្រប់ទិដ្ឋភាពនីមួយៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយ យុត្តិធម៌ក្នុងឯកសារនេះត្រូវបានបែងចែកជា៣ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ៖ សិទ្ធិបុរេជំនុំជម្រះ សិទ្ធិនៅពេលជំនុំជម្រះ និងសិទ្ធិក្រោយការជំនុំជម្រះ។ ក៏ប៉ុន្តែអ្នកនិពន្ធទទួលស្គាល់ថាការបែងចែកនេះមានលក្ខណៈដូចជាសិប្បនិម្មិត ដោយមូលហេតុថា ទិដ្ឋភាពនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អាចអនុវត្តបានគ្រប់ដំណាក់កាលទាំងអស់ ហើយការរំលោភបំពានសិទ្ធិនេះនៅដំណាក់

---

[112] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តដោយសភាធម្មនុញ្ញ នៅក្នុងសម័យប្រជុំលើកទី២ កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ [រដ្ឋធម្មនុញ្ញ]

[113] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញលេខ 092/003/2007 ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ អាននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ តាមរយៈតំណភ្ជាប់
http://cambodia.ohchr.org/WebDOCs/DocProgrammes/CC_decision.pdf

កាលមួយអាចប៉ះពាល់ដល់ដំណាក់កាលមួយទៀត។[114] ជាការសំខាន់ផងដែរ ក្នុងការចងចាំថា មានគោលការណ៍ផ្សេងទៀត នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនត្រូវបានបញ្ចូលឱ្យបានច្បាស់នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនេះទេ ពោលគឺកតិកាសញ្ញានេះផ្តល់ត្រឹមស្តង់ដារអប្បបរមាតែប៉ុណ្ណោះ។

## ៣.១ សិទ្ធិបុរេជំនុំជម្រះ

### ក. សិទ្ធិពាក់ព័ន្ធនឹងការចាប់ខ្លួន និងការឃុំខ្លួន

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ចាប់ផ្តើមនៅពេលចាប់ខ្លួន។ មាត្រា៩(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏ដូចជាមាត្រា៣២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "ជនគ្រប់រូប មានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។"[115] នៅក្នុងទស្សនៈចង្អៀតនៃមាត្រានេះ សេរីភាពបុគ្គលសំដៅលើសេរីភាពរូបរាងកាយ ឬការបំលាស់ទីរបស់បុគ្គលដោយគ្មានការឃុំឃាំងឱ្យនៅមួយកន្លែង ដូចជាកន្លែងឃុំឃាំងឬពន្ធនាគារ។[116] សន្តិសុខផ្ទាល់ខ្លួនសំដៅលើសិទ្ធិរួចផុតពីការជ្រៀតជ្រែកសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន សន្តិសុខផ្ទាល់ខ្លួនការពារបុគ្គលពីការដាក់ទោសលើរូបរាងកាយ ឬការរងរបួសផ្លូវចិត្តដោយចេតនា។[117]

មាត្រា ៩(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏បានចែងបន្ថែមទៀតថា "គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ" និង "គ្មានជនណាម្នាក់ ត្រូវបានដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។"[118] ដូចគ្នានេះដែរ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញការពារបុគ្គលពីការចាប់ខ្លួន ឬឃុំខ្លួន លើកលែងតែមានការអនុលោមតាមច្បាប់។ បទបញ្ញត្តិដែលចែងពីការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលត្រូវតែមានសមាមាត្រត្រឹមត្រូវអាចសន្មតបាន និងមិនរើសអើង។[119]

---

[114] គណៈកម្មាធិការមេធាវីសិទ្ធិមនុស្ស, 2000, តើអ្វីជាការជំនុំជម្រះដោយយុត្តិធម៌? សេចក្តីណែនាំជាមូលដ្ឋានសម្រាប់ស្តង់ដារ និងការអនុវត្តច្បាប់ ទំព័រ៤

[115] មាត្រា ៩(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ; មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ

[116] Nowak, M (ការបោះពុម្ពផ្សាយលើកទី២) 2005, អត្ថាធិប្បាយរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយស្តីពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របស់អង្គការសហប្រជាជាតិ បោះពុម្ពផ្សាយដោយ N.P. Engel, Publisher [អត្ថាធិប្បាយ Nowak] ទំព័រ២១២

[117] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ៣៥៖ មាត្រា៩ (សេរីភាព និងសុវត្ថិភាពរបស់មនុស្ស) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ លេខ CCPR/C/GC/35 [អត្ថាធិប្បាយទូទៅលេខ៣៥] កថាខណ្ឌទី៣ និង៩

[118] មាត្រា ៩(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[119] អត្ថាធិប្បាយ Nowak ទំព័រ២២៥ និងដូចកំណត់សម្គាល់ខាងលើលេខ២០

សិទ្ធិរួចផុតពីការចាប់ខ្លួនតាមអំពើចិត្ត ត្រូវការអាជ្ញាធរពាក់ព័ន្ធ ជាពិសេសនគរបាលត្រូវមានមូលហេតុសមហេតុផលក្នុងការសង្ស័យថាបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើស។[120] នៅពេលចាប់ខ្លួន មាត្រា៩(២) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថា ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឱ្យគេប្រាប់ឱ្យដឹង អំពីមូលហេតុនៃការចាប់ខ្លួន និងពីបទចោទប្រកាន់ នៅពេលចាប់ខ្លួន។[121] សិទ្ធិទាំងនេះ ក៏ដូចជាសិទ្ធិពាក់ព័ន្ធផ្សេងទៀត ដូចជាសិទ្ធិទទួលបានជំនួយពីអ្នកប្រឹក្សាផ្នែកច្បាប់ត្រូវបានពន្យល់ទៅឱ្យបុគ្គលក្នុងភាសាដែលអាចងាយយល់បាន។[122] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានលើកជាសំណើឡើងថា រយៈពេលឃុំខ្លួនមុនការជំនុំជម្រះ មិនត្រូវលើសពី "ពីរ ឬបីថ្ងៃ" នោះទេ។[123]

សិទ្ធិពាក់ព័ន្ធនឹងការចាប់ខ្លួន និងការឃុំខ្លួនត្រូវបានចែងយ៉ាងល្អនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[124] មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ឃាត់ខ្លួនបុគ្គលបានដល់ ៤៨ម៉ោង។ រយៈពេលនេះរាប់ចាប់ពីពេលទៅដល់ប៉ុស្តិ៍នគរបាល។ រយៈពេលនេះអាចពន្យារពេលបាន ២៤ម៉ោងទៀត ដោយមានសំអាងហេតុផ្លូវច្បាប់។ នៅពេលដល់កាលកំណត់ ជនជាប់ឃុំឃាំងត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬដោះលែងឱ្យមានសេរីភាព។[125] ចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនបានឡើយ។[126]

នៅពេលសាកសួរ ជាពិសេសនៅពេលឃាត់ខ្លួន ជនសង្ស័យមិនអាចត្រូវបានបង្ខិតបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឡើយ។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ថា "ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្ត

---

[120] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អនុម័តដោយរដ្ឋសភា នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០៧

[121] មាត្រា ១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[122] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ១៣៖ មាត្រា១៤ (ការផ្តល់យុត្តិធម៌) សមភាពនៅមុខតុលាការ និងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ និងដោយយុត្តិធម៌ តាមរយៈតុលាការឯករាជ្យ បង្កើតឡើងស្របតាមច្បាប់ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៨៤ [អត្ថាធិប្បាយទូទៅលេខ១៣] កថាខណ្ឌទី៨

[123] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ៨៖ មាត្រា៩ (សិទ្ធិទទួលបានសេរីភាព និងសុវត្ថិភាព) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៨២ [អត្ថាធិប្បាយទូទៅលេខ៨] កថាខណ្ឌទី២

[124] មាត្រា ៩៦ ១៩៧ ២០៣ ២០៥ ២០៦ ២១១ និង២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[125] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[126] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ”។[127] ការសារភាពដោយសារមកពីការបង្ខំរូបរាងកាយ ឬចិត្ត មិនត្រូវបានអនុញ្ញាតទុកជាភស្តុតាងការប្រព្រឹត្តល្មើសនោះទេ។[128] ជនសង្ស័យក៏មានសិទ្ធិនៅស្ងៀម ពួកគេត្រូវទទួលដំណឹងពីសិទ្ធិរបស់គេក្នុងការប្រកែកមិនឆ្លើយនឹងសំណួរណាមួយឡើយ។[129]

ជាចុងក្រោយ ជាការសំខាន់ដែលជនសង្ស័យត្រូវដឹងពីសិទ្ធិទទួលបានជំនួយពីមេធាវីនៅក្នុងដំណាក់កាលដំបូងបំផុតនៃនីតិវិធីផ្លូវច្បាប់។ មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ផ្តល់សិទ្ធិដល់ជនសង្ស័យឱ្យទទួលបានជំនួយ ពីមេធាវីនៅពេលពួកគេស្ថិតក្រោមការចាប់ខ្លួនរយៈពេល២៤ម៉ោង។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែជូនដំណឹងភ្លាមៗទៅជនសង្ស័យពីសិទ្ធិទាំងនេះរបស់ពួកគេ។[130]

នៅកម្ពុជា អង្គការឃ្លាំមើលសិទ្ធិមនុស្សបានកត់សម្គាល់ថា មន្ត្រីនគរបាលតែងតែធ្វើទារុណកម្មរូបរាងកាយលើជនត្រូវចោទដើម្បីទទួលបានចម្លើយសារភាព។ បន្ទាប់មកចម្លើយសារភាពទាំងនេះត្រូវបានប្រើប្រាស់ជាភស្តុតាងនៅក្នុងរបាយការណ៍នគរបាល។ ជាលទ្ធផលតុលាការតែងតែពឹងផ្អែកលើភស្តុតាងចាប់បង្ខំនេះដើម្បីផ្តន្ទាទោសជនសង្ស័យ ដែលធ្វើឱ្យអន្ត-រាយធ្ងន់ធ្ងរដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ជនត្រូវចោទ។[131] ក៏ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានលើកឡើងថា ការសារភាពដោយបង្ខំអាចត្រូវបានប្រើប្រាស់សម្រាប់ជាមាតិកាតែប៉ុណ្ណោះ មានន័យថាការសារភាពនេះអាចប្រើជាតម្រុយស៊ើបមួយដើម្បីឈានទៅរកប្រភពព័ត៌មានផ្សេងទៀត ប៉ុន្តែវាមិនមែនជាភស្តុតាងការពិតនៃចម្លើយសារភាពនោះទេ។[132]

បន្ថែមពីលើនេះ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានទាញចំណាប់អារម្មណ៍ទៅលើស្ថានភាពក្រីក្ររបស់ទណ្ឌិតជាច្រើន។ ករណីនេះត្រូវបានលើកឡើងថាធ្វើឱ្យអ្នកជាប់ឃុំស្ថិតក្នុងសភាពដែលធ្វើឱ្យពួកគេក្លាយជាជនងាយរងគ្រោះចំពោះទង្វើឃោរឃៅ អមនុស្សធម៌ ឬប្រព្រឹត្ត

[127] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ

[128] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ; មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[129] មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[130] មាត្រា ៩៨ និង១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[131] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឯកសារនៃការពិនិត្យជាសកល - កម្ពុជា ចេញផ្សាយនៅខែមិថុនា ឆ្នាំ២០១៣ [ឯកសារអង្គការឃ្លាំមើលសិទ្ធិមនុស្ស] ទំព័រ២

[132] រឿងក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច រឿងក្តីលេខ 001/18-07-2007-ECCC/TC សេចក្តីសម្រេចលើសំណូមពររបស់ភាគីក្នុងការដាក់ភស្តុតាងនៅមុខអង្គជំនុំជម្រះ អនុលោមតាមមាត្រា៨៧(២) នៃបទបញ្ជាផ្ទៃក្នុង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌទី៨

កម្មបន្ទាបបន្ថោក។[133] អង្គការឃ្លាំមើលសិទ្ធិមនុស្សបានជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាធានាថា ស្ថានភាពពន្ធនាគារអនុលោមតាមវិធានអប្បបរមាស្តង់ដាររបស់អង្គការសហប្រជាជាតិសម្រាប់ប្រព្រឹត្តកម្មលើទណ្ឌិត ដែលកម្ពុជាជារដ្ឋភាគីនៃវិធាននេះ។[134]

ក្តីបារម្ភសំខាន់មួយផ្សេងទៀត ដែលបន្ថែមទៅលើកំណើនអ្នកជាប់ឃុំឃាំងមុនការជំនុំជម្រះ គឺកង្វះចៅក្រម មេធាវី និងបន្ទប់សវនាការនៅក្នុងប្រទេសកម្ពុជា។[135] កង្វះភាពចាំបាច់ជាមូលដ្ឋានក្នុងការធ្វើការឱ្យបានសមរម្យ រួមជាមួយនឹងជំនួយផ្នែកច្បាប់មិនគ្រប់គ្រាន់ ក៏បណ្តាលឱ្យមានសំណុំរឿងជាច្រើនកកស្ទះនៅត្រឹមសាលាដំបូងរាជធានី/ខេត្តភាគច្រើន។ បញ្ហាទាំងនេះនៅតែបណ្តាលឱ្យមានការពន្យាពេលមិនចាំបាច់នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលជាលទ្ធផលមនុស្សជាច្រើនជាប់ឃុំដោយគ្មានការជំនុំជម្រះ។[136]

### ខ. សិទ្ធិត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស

មាត្រា ១៤(២)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងថាជនដែលត្រូវចោទពីបទឧក្រិដ្ឋ មានសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលយូរហួស។ លើសពីនេះ មាត្រា ៩(៣) ចែងថាជនជាប់ចោទមានសិទ្ធិ "ត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង"។ ខណៈដែលសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យាពេលយូរហួស តម្រូវឱ្យមន្ត្រីតុលាការចាត់នីតិវិធីដែលធានាថាការជំនុំជម្រះមានប្រសិទ្ធភាព និងឆាប់រហ័ស កិច្ចការនេះត្រូវតែដើរទន្ទឹមនឹងតម្រូវការគោរពសិទ្ធិផ្សេងទៀតរបស់ជនត្រូវចោទ។

នៅពេលវាយតម្លៃពីពេលវេលាសម្រាប់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះ ពេលវេលារាប់គិតចាប់ពីនៅពេលជនសង្ស័យទទួលដំណឹងថា អាជ្ញាធរកំពុងចាត់នីតិវិធីជាក់លាក់ដើម្បីចោទប្រកាន់ និងបញ្ចប់នៅពេលមានសាលក្រមចុងក្រោយនៃនីតិវិធីទាំងមូល។[137] សម្រាប់នីតិវិធីបង្ហាញខ្លួនភ្លាមៗ តុលាការត្រូវតែប្រកាសសាលក្រមទៅតាមអង្គសេចក្តីនៃសំណុំរឿងក្នុងរយៈពេល២សប្តាហ៍ ទៅឱ្យជនជាប់ចោទ ដែលមានវត្តមាននៅតុលាការ។[138]

---

[133] ឯកសារអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដូចកំណត់សម្គាល់ខាងលើលេខ៣៥ ទំព័រ២

[134] ឯកសារអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដូចកំណត់សម្គាល់ខាងលើលេខ៣៥ ទំព័រ៥

[135] ក្រសួងការបរទេសអាមេរិក, 2012, របាយការណ៍សិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១១ របាយការណ៍សង្ខេប ទំព័រ៨-៩ អាននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ តាមរយៈតំណភ្ជាប់ http://www.state.gov/j/drl/rls/hrrpt/2011/eap/186266.htm

[136] Certo, BD 2013, «កម្ពុជា៖ យុត្តិធម៌ក្នុងភាពជាប់គាំង» ទស្សនាវដ្តី Southeast Asia Globe (Phnom Penh)

[137] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៣៥

[138] មាត្រា ៣០៣ និង៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សម្រាប់សំណុំរឿងដែលព្រះរាជអាជ្ញាបង្គាប់បញ្ជាឱ្យមានការស៊ើបអង្កេត ពេលវេលាកំណត់ពីការចេញសាលក្រមផ្ដន្ទាទោសមិនត្រូវបានកំណត់នោះទេ ក៏ប៉ុន្តែវាត្រូវធ្វើឡើងក្នុងរយៈពេលសមស្រប។[139]

អ្វីដែលបង្កើតជាពេលវេលាសមស្របអាស្រ័យទៅតាមកាលៈទេសៈទាំងមូលនៃរឿងក្ដី ដូចជា ភាពស្មុគស្មាញ ប្រភេទបទល្មើស និងការផ្ទៀងផ្ទាត់ការស៊ើបអង្កេត និងអាជ្ញាធរព្រះរាជអាជ្ញា។[140]

នៅពេលដែលពិបាកនឹងកំណត់រករយៈពេលណាមួយ ទៅតាមចំណាត់ថ្នាក់នៃដំណើរការជំនុំជម្រះបទល្មើសព្រហ្មទណ្ឌទាំងមូល និងនៅពេលដែលសកម្មភាពរបស់រដ្ឋត្រូវការពេលវេលាច្រើន ហេតុនេះអាចជាការបំពាននឹងតម្រូវការឱ្យបញ្ចប់នីតិវិធីឱ្យបានក្នុងរយៈពេលមួយសមស្រប។[141] ភាគច្រើនគឺអាស្រ័យទៅតាមកាលៈទេសៈនៃរឿងក្ដី។ ហេតុដូចនេះការជំនុំ-ជម្រះដែលមានរយៈពេលច្រើនជាង១០ឆ្នាំ អាចត្រូវគ្នានឹងការយល់ថារយៈពេលសមស្រប ហើយកិច្ចការនេះដែលអាចបញ្ចប់បានក្នុងរយៈពេល១២ខែ អាចបំពាននឹងគោលការណ៍ទៅវិញ។[142]

ក្រមនីតិវិធីព្រហ្មទណ្ឌមានចែងពីការឃុំខ្លួនបណ្ដោះអាសន្ន។ មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌរៀបរាប់ពីហេតុផលផ្លូវច្បាប់[143] ដើម្បីឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន

[139] មាត្រា ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[140] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៣៥ (រៀបរាប់ពីសេចក្ដីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប)

[141] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៣៧ (រៀបរាប់ពីសេចក្ដីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប)

[142] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៣៤

[143] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា «ការឃុំខ្លួនបណ្ដោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះជាការចាំបាច់៖

១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី។

២. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសម គំនិត។

៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

៤. ដើម្បីធានារក្សាជនត្រូវចោត ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ។

៦. ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។»

រយៈពេល ៦ ខែ ចំពោះបទឧក្រិដ្ឋ[144] និង ៤ ខែចំពោះបទមជ្ឈឹម[145] និងអាចពន្យាពេលបានពី ៦ ខែ បន្ថែមទៀតចំពោះបទឧក្រិដ្ឋ និង ២ ខែបន្ថែមចំពោះបទមជ្ឈឹម។

ក្នុងការអនុវត្តជាក់ស្ដែង ការពន្យារពេលឃុំខ្លួនត្រូវបានអនុញ្ញាតដោយក្រមនីតិវិធីព្រហ្មទណ្ឌ[146] គឺងាយនឹងបំពានដោយព្រះរាជអាជ្ញា និងតុលាការ។ ជាលទ្ធផល អ្នកជាប់ឃុំមុនការជំនុំជម្រះត្រូវបានដាក់ឱ្យជាប់ឃុំលើសពីដែនកំណត់របស់ច្បាប់។[147] ផ្អែកលើឯកសាររបស់មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាពីពន្ធនាគារ ចុះខែកញ្ញា ឆ្នាំ២០១៤ អ្នកជាប់ឃុំរងចាំការជំនុំជម្រះមានចំនួន ៦៣.៦% នៃទណ្ឌិតទាំងអស់នៅក្នុងពន្ធនាគារកម្ពុជា គឺជាចំនួនមួយដែលខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍។[148] ទន្ទឹមនឹងនេះ អង្គការលីកាដូបានអង្កេតឃើញថាពន្ធនាគារទាំង១៨កន្លែង នៅកម្ពុជាមានសភាពណែនណាន់តាន់តាប់ ដែលផ្ទុកមនុស្សប្រហែល ១៥២% ស្មើនឹង ១២,៧១៩ នាក់កាលពីខែមីនា ឆ្នាំ២០១៤។[149] ផ្អែកទៅតាមអង្គការឃ្លាំមើលសិទ្ធិមនុស្ស អតីតអ្នកជាប់ឃុំបានរាយការណ៍ពីការប្រើអំពើហឹង្សាលើផ្លូវកាយ និងផ្លូវភេទ រួមទាំងការប្រើដំបងឆក់ ការវាយដោយប្រើខ្សែភ្លើង ការងារដោយបង្ខំ និងការហ្វឹកហាត់តាមបែបទាហានយោធាធ្ងន់ៗ។[150]

---

144 មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

145 មាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

146 មាត្រា ២១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

147 ឯកសារអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដូចកំណត់សម្គាល់ខាងលើលេខ៣៥ ទំព័រ២

148 មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការសិក្សាពីពន្ធនាគារ, ព័ត៌មានសង្ខេបស្ដីពីពន្ធនាគារពិភពលោក - កម្ពុជា, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ អាននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ តាមរយៈតំណភ្ជាប់ http://www.prisonstudies.org/country/cambodia

149 សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ, 2014, របាយការណ៍ស្ដីពីអំពើទារុណកម្ម និងការធ្វើបាបៈ ការផ្ដល់ចម្លើយពីខាងក្នុងពន្ធនាគារ និងប៉ុស្តិ៍នគរបាលរបស់កម្ពុជា [របាយការណ៍លីកាដូឆ្នាំ២០១៤] ទំព័រ១៧

150 របាយការណ៍លីកាដូឆ្នាំ២០១៤ ទំព័រ១៧ និងឯកសារអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដូចកំណត់សម្គាល់ខាងលើលេខ៣៥ ទំព័រ២

## ៣.២ សិទ្ធិនៅពេលជំនុំជម្រះ

### ក. សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង

សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង មានចែងនៅក្នុងមាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[151] នេះជាទស្សនៈមូលដ្ឋានបំផុតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានចែងថា ករណីនេះគ្មានករណីលើកលែងនោះទេ។[152]

ពាក្យថាតុលាការឯករាជ្យ គឺសំដៅលើតុលាការដែលត្រូវតែរួចផុតពីការជ្រៀតជ្រែកទាំងប្រភពខាងក្រៅ ដូចជាអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ និងប្រភពខាងក្នុង ដូចជាចៅក្រមថ្នាក់លើ។[153] លើសពីនេះ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីតុលាការ (គោលការណ៍មូលដ្ឋាន) ដាក់ចេញនូវតម្រូវការ និងយន្តការជាមូលដ្ឋានខ្លះដែលចាំបាច់សម្រាប់ធានាឯករាជ្យភាពរបស់តុលាការ។[154] គោលការណ៍មូលដ្ឋានទាំងនេះតម្រូវឱ្យតុលាការមានអំណាចក្នុងការចាត់ចែងសំណុំរឿង ឬចៅក្រម។[155] គោលការណ៍នេះក៏តម្រូវឱ្យមានគុណវឌ្ឍក្នុងការចាត់តាំងតុលាការឱ្យមានភាពជាក់លាក់ច្បាស់លាស់។[156] បន្ថែមពីនេះទៀត អាណត្តិនៃការតែងតាំងមន្ត្រីតុលាការ និងមុខតំណែងរបស់ពួកគាត់ត្រូវតែធានាឱ្យបាន

---

[151] មាត្រា ៦(២) នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (ECHR); មាត្រា ៨(១) និង២៧(២) នៃអនុសញ្ញាអាមេរិកាំងស្តីពីសិទ្ធិមនុស្ស; មាត្រា ៧(១) និង២៦ នៃរដ្ឋធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស; គោលការណ៍ទី២០ នៃសេចក្តីប្រកាសអាស៊ាន

[152] គណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សស្តីកថាខណ្ឌទី៤ នៃមាត្រា៥ នៃពិធីសារជ្រើសរើស ដកស្រង់ចេញពីកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឯកសារទំនាក់ទំនងលេខ 263/1987 ឯកសារអង្គការសហប្រជាជាតិលេខ CCPR/C/46/D/263/1987 (1992) កថាខណ្ឌទី៥.១

[153] Larkins, CM 1996, «ភាពឯករាជ្យក្នុងប្រព័ន្ធតុលាការ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យ៖ ការវិភាគលើទ្រឹស្តី និងគំនិត» *American Journal of Comparative Law* បោះពុម្ពផ្សាយលើកទី៤៤ ទំព័រ៤៤

[154] គោលការណ៍ជាមូលដ្ឋានស្តីពីភាពឯករាជ្យក្នុងប្រព័ន្ធតុលាការ អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ស្តីពីការបង្ការបទល្មើស និងការប្រព្រឹត្តទៅលើជនល្មើស និងគាំទ្រដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 40/32 ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងលេខ 40//146 ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៨៥ [គោលការណ៍ជាមូលដ្ឋាន]

[155] គោលការណ៍ទី២ នៃគោលការណ៍ជាមូលដ្ឋាន

[156] គោលការណ៍ទី១០ នៃគោលការណ៍ជាមូលដ្ឋាន

គ្រប់គ្រាន់។[157] វិធានការដាក់ទោសលើចៅក្រមត្រូវតែស្មើភាព ប្រសិទ្ធភាព និងឯករាជ្យ។[158] ជាចុងក្រោយ គោលការណ៍មូលដ្ឋានតម្រូវឱ្យតុលាការមានធនធានគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។[159] នេះរួមមានប្រាក់ខែ និងការបណ្តុះបណ្តាលគ្រប់គ្រាន់។ តម្រូវការភាគច្រើនសំដៅលើច្បាប់តុលាការទាំងបី (សូមមើលបន្ថែមដូចមានលម្អិតខាងក្រោម)។ រដ្ឋធម្មនុញ្ញការពារឯករាជ្យភាពនៃអំណាចតុលាការយ៉ាងខ្លាំងក្លា។ មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញធានាពីឯករាជ្យភាពនៃអំណាចតុលាការ ខណៈដែលមាត្រា១២៩ នៃរដ្ឋធម្មនុញ្ញបានដាក់ចេញថាអំណាចតុលាការមានអំណាចផ្តាច់មុខក្នុងការផ្តល់យុត្តិធម៌ តាមច្បាប់ និងនីតិវិធីជាធរមាន។ មាត្រា១៣០ ចែងពីគោលការណ៍បែងចែកអំណាច ក្នុងលក្ខខណ្ឌដែលអំណាចតុលាការមានឯករាជ្យភាពទាំងស្រុងដាច់ចេញពីអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ។ ជាចុងក្រោយ រដ្ឋធម្មនុញ្ញតម្រូវឱ្យមានច្បាប់ដាច់ដោយឡែកដែលចែងពីមុខងាររបស់តុលាការ។[160]

នៅឆ្នាំ២០០៧ ដើម្បីដោះស្រាយបញ្ហាឯករាជ្យភាពរបស់អំណាចតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានអនុម័តក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា។[161] ក្រោយមកនៅខែតុលា ឆ្នាំ២០១៣ ដោយមានការអំពាវនាវបន្ថែមពីអង្គការសហប្រជាជាតិ និងអង្គការសិទ្ធិមនុស្សនានា[162] រដ្ឋសភាបានអនុម័តលើច្បាប់ពាក់ព័ន្ធនឹងតុលាការចំនួនបី៖ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃតុលាការ[163] និងច្បាប់ស្តីពី

---

[157] គោលការណ៍ទី១០ នៃគោលការណ៍ជាមូលដ្ឋាន; សម្រាប់ដំណើរការនៃការតែងតាំងចៅក្រម សូមមើល ផ្នែក៦ និង៧ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា អនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ពិនិត្យដោយព្រឹទ្ធសភា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ និងអនុម័តដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញតាមរយៈសេចក្តីសម្រេចលេខ 149/003/2014 KBTH.Ch កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៤

[158] គោលការណ៍ទី១៧-២០ នៃគោលការណ៍ជាមូលដ្ឋាន ដូចកំណត់សម្គាល់ខាងលើលេខ៥៨

[159] គោលការណ៍ទី៧ នៃគោលការណ៍ជាមូលដ្ឋាន ដូចកំណត់សម្គាល់ខាងលើលេខ៥៨

[160] មាត្រា ១៣៥ នៃរដ្ឋធម្មនុញ្ញ

[161] Vidjia, P & Jenifer, H 2011, «កម្ពុជា» នៅក្នុងនីតិរដ្ឋសម្រាប់សិទ្ធិនៅក្នុងតំបន់អាស៊ាន៖ ការសិក្សាដោយផ្អែកលើទិន្នន័យដើម មជ្ឈមណ្ឌលធនធានសិទ្ធិមនុស្ស

[162] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លេខ U.N. A/HRC/24/36 ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៣ [របាយការណ៍សិទ្ធិមនុស្សពិសេសឆ្នាំ២០១៣] កថាខណ្ឌទី១៧

[163] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ អនុម័តដោយរដ្ឋភា កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ ពិនិត្យដោយព្រឹទ្ធសភា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ និងអនុម័តដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញតាមរយៈសេចក្តីសម្រេចលេខ 149/003/2014 KBTH.Ch កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៤។ អត្ថបទនេះវិភាគលើច្បាប់ស្តីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលចូលជាធរមាន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៣ ចូលមើលនៅថ្ងៃទី១៥ខែឧសភាឆ្នាំ២០១៥ តាមរយៈតំណភ្ជាប់

ការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។[164] ខណៈដែលក្រុមសិទ្ធិមនុស្សរិះគន់ថា ច្បាប់ទាំងនេះជាមូលដ្ឋានដែលមិនអាចធានាពីឯករាជ្យភាពពិតប្រាកដ របស់តុលាការ វាជាជំហានសំខាន់មួយក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងឯករាជ្យភាពនៃអំណាចតុលាការ និងដោះស្រាយតម្រូវការភាគច្រើនដែលមាននៅក្នុងគោលការណ៍មូលដ្ឋាន។

ក្រៅពីជំហានវឌ្ឍនភាពតូចៗទាំងនេះ ត្រូវមានការទទួលស្គាល់ថា ទោះបីជាមានជំនួយឥតសំណងអស់រយៈពេល២ទសវត្សនៅក្នុងកំណែទម្រង់ប្រព័ន្ធតុលាការ សិទ្ធិទទួលបានការជំនុំជម្រះនៅកម្ពុជា នៅតែបន្តមិនទទួលបានការគោរពឱ្យបានគ្រប់គ្រាន់នៅក្នុងការអនុវត្តជាក់ស្តែង។ អំពើពុករលួយនៅក្នុងដំណើរការតែងតាំង ការចាត់តាំង និងការតម្លើងឋានៈចៅក្រម នៅតែជាបញ្ហាដែលគួរបារម្ភខ្លាំងបំផុត។[165] លើសពីនេះ បើគ្មានចៅក្រមមានសមត្ថកិច្ចផ្តល់យុត្តិធម៌ដល់សំណុំរឿង សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានសាលក្រមសមហេតុផលនៅអន់ថយនៅឡើយ។ អំពើពុករលួយក៏ធ្វើឱ្យអន្តរាយដល់ឯករាជ្យភាពរបស់តុលាការផងដែរ ដោយសារតែវាធ្វើឱ្យចៅក្រមបំពេញតួនាទីរបស់ខ្លួន ក្នុងលក្ខខណ្ឌដែលបម្រើប្រយោជន៍អាជ្ញាធរដែលតែងតាំងខ្លួន។

ភាពមិនលំអៀងតម្រូវឱ្យចៅក្រមផ្តល់នូវយុត្តិធម៌ នៅពេលចេញសាលក្រម ដោយធ្វើការវាយតម្លៃជាសត្យានុម័តលើភស្តុតាង និងអង្គសេចក្តីនៃសំណុំរឿង ដោយមិនលំអៀងទៅរកភាគីណាមួយដោយសារតែការទំនាក់ទំនង ឬមនោសញ្ចេតនាផ្ទាល់ខ្លួននោះទេ។[166] នៅក្នុងបរិបទខ្មែរ មាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងពីជម្លោះផលប្រយោជន៍ដែលអាចប្តឹង

---

http://cambodia.ohchr.org/klc_pages/KLC_files/section_002/section02_001_1993.pdf

[164] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ពិនិត្យដោយព្រឹទ្ធសភា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ និងអនុម័តដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញតាមរយៈសេចក្តីសម្រេចលេខ 148/002/2014 KBTH.Ch កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៤។ អត្ថបទនេះវិភាគលើការអនុម័តច្បាប់របស់រដ្ឋសភា កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ អាននៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥តាមរយៈតំណភ្ជាប់

http://cambodia.ohchr.org/klc_pages/KLC_files/section_002/section02_008_1994.pdf

[165] Un, K & So, S 2012, «ប្រព័ន្ធយុត្តិធម៌កម្ពុជា៖ ដំណើរឆ្ពោះទៅរកយុត្តិធម៌នយោបាយ? នៅក្នុង សៀវភៅរបស់ Dressel, B (ed.) 2012 ប្រព័ន្ធយុត្តិធម៌នយោបាយនៅអាស៊ី អាមេរិក និងកាណាដា បោះពុម្ពផ្សាយដោយ Routledge ក្នុងឆ្នាំ២០១២ ទំព័រ១៩៦

[166] Larkins ដូចកំណត់សម្គាល់ខាងលើលេខ៥៧ ទំព័រ៨៤; មាត្រា១០ នៃក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញាកម្ពុជា ឆ្នាំ២០០៧

ជិតចិត្តចៅក្រមអាសនៈបាន។[167] ក៏ប៉ុន្តែ ខណៈមាត្រា ៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា អនុញ្ញាតឱ្យចៅក្រមប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុវត្តច្បាប់ វាគ្មានបទបញ្ញត្តិណាមួយដែលឱ្យចៅក្រមទទួលខុសត្រូវចំពោះសាលក្រមដែលមានភាពលំអៀង ឬមិនល្អ ដែលអាចបណ្តាលមកពីការកំណត់លទ្ធផលសំណុំរឿងជាមុន។[168]

### ខ. សិទ្ធិទទួលបានសវនាការជាសាធារណៈ

មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយធានាសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ។ នេះជាធាតុផ្សំស្នូលមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងនីតិវិធីត្រឹមត្រូវ។[169] ខណៈដែលសិទ្ធិទទួលបានសវនាការជាសាធារណៈ គឺជារឿងផ្ទាល់ខ្លួនរបស់ភាគីនៃនីតិវិធី នៅក្នុងរបបប្រជាធិបតេយ្យ សាធារណៈជនក៏មានសិទ្ធិទាមទារឱ្យនីតិវិធីធ្វើឡើងជាសាធារណៈ[170] កម្មវត្ថុចុងក្រោយនៃសិទ្ធិនេះគឺ ធានាថា យុត្តធម៌មិនត្រូវធ្វើឡើងដោយសម្ងាត់នោះទេ[171] ដើម្បីធានាតម្លាភាពនៅក្នុងការគ្រប់គ្រងយុត្តិធម៌ និងទំនុកចិត្តរបស់សាធារណជន នៅក្នុងប្រព័ន្ធតុលាការ ខណៈដែលព្យាយាមការពារការសម្របសម្រួល ឬឥទ្ធិពលនាពេលអនាគតណាមួយ។

នៅក្នុងច្បាប់អន្តរជាតិ សិទ្ធិទទួលបានសវនាការជាសាធារណៈទាមទារឲ្យមានការផ្សព្វផ្សាយពីសេចក្តីសម្រេចព្រហ្មទណ្ឌទាំងអស់ជាសាធារណៈ លើកលែងតែនៅក្នុងករណីមួយចំនួនទាក់ទងនឹងជម្លោះគ្រួសារ ដែលមានជាប់ពាក់ព័ន្ធជាមួយនឹងកូន។[172] លើសពីនេះ តុលាការត្រូវធានាថា សាធារណជនអាចមើលសាលក្រមរបស់ខ្លួនបាន។[173] ច្បាប់អន្តរជាតិក៏តម្រូវឲ្យតុលាការផ្សព្វផ្សាយជាសាធារណៈនូវពេលវេលា និងទីកន្លែងសម្រាប់សវនាការផងដែរ[174] ហើយក៏តម្រូវឲ្យតុលាការផ្តល់កន្លែងគ្រប់គ្រាន់ឲ្យអ្នកមានផលប្រយោជន៍ចូលរួមសវនាការ

---

[167] មាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[168] អង្គការតម្លាភាពកម្ពុជា, 2014, អំពើពុករលួយ និងប្រព័ន្ធអភិបាលកិច្ចកម្ពុជា៖ ភាពចាំបាច់នៃកំណែទម្រង់ [របាយការណ៍អង្គការតម្លាភាពកម្ពុជាឆ្នាំ២០១៤] ទំព័រ៦០ អាននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ តាមរយៈតំណភ្ជាប់ http://ticambodia.org/index.php/whatwedo/publication/nisa-report-2014

[169] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣១៤

[170] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣២៥

[171] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣២៣

[172] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣២៦

[173] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣១៤

[174] រឿងក្តី *Van Meurs v. The Netherlands* គណៈកម្មាការសិទ្ធិមនុស្ស លិខិតទំនាក់ទំនងលេខ២១៥/១៩៨៦ កថាខណ្ឌទី២

អាស្រ័យទៅតាមធនធានរបស់តុលាការ និងចំនួនសមរម្យណាមួយតាមការយល់ឃើញរបស់តុលាការ។[175]

ទោះជាយ៉ាងណាក៏ដោយ សិទ្ធិក្នុងការទទួលបានសវនាការជាសាធារណៈអាចនឹងត្រូវរិតត្បិត ក្នុងស្ថានភាពចាំបាច់មួយចំនួន។ ដូច្នេះហើយ មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ លើកឡើងថា សាធារណជន និងសារព័ត៌មានអាចនឹងមិនអនុញ្ញាតឲ្យចូលរួមក្នុងផ្នែកណាមួយ ឬទាំងស្រុងនៃសវនាការ ដោយសារហេតុផលសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងការពារជីវិតឯកជនរបស់ភាគី ឬដើម្បីចៀសវាងបុរេវិនិច្ឆ័យណាមួយកើតមានឡើង។ ផ្ទុយទៅវិញ មាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានលើកឡើងតែពីហេតុផលសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ ជាមូលហេតុមិនអនុញ្ញាតឲ្យសាធារណជន និងសារព័ត៌មានចូលរួមក្នុងផ្នែកណាមួយ ឬទាំងស្រុងនៃសវនាការ។

ក្រមនីតិវិធីព្រហ្មទណ្ឌការពារសិទ្ធិក្នុងការទទួលបានសវនាការជាសាធារណៈ ដោយមាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានតម្រូវឲ្យមានសវនាការជម្រះក្តីធ្វើឡើងជាសាធារណៈ។ ចំពោះការរិតត្បិតការចូលរួម ក្រមនីតិវិធីព្រហ្មទណ្ឌមិនអនុញ្ញាតឲ្យសាធារណជន ឬសារព័ត៌មានចូលរួមក្នុងសវនាការ ដោយសារមូលហេតុសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌។ គួរឲ្យកត់សម្គាល់ដែរថា សេចក្តីសម្រេចនេះមិនអាចប្តឹងជំទាស់បានទេ។[176]

នៅក្នុងការអនុវត្តជាក់ស្តែង សាធារណជននៅកម្ពុជាអាចចូលរួមក្នុងសវនាការជាសាធារណៈតិចតួច ជាពិសេសសាលាឧទ្ធរណ៍មិនថារឿងក្តីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌនោះទេ។[177] លើសពីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ទាំងបី ពាក់ព័ន្ធនឹងវិស័យតុលាការ មិនបានតម្រូវឲ្យតុលាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈពីកាលវិភាគសវនាការ ការអត្ថាធិប្បាយ ឬសារណាការពារ នៅលើព្រឹត្តិបត្រយុត្តិធម៌នោះទេ។[178] ទោះបីជាព័ត៌មានពីរឿងក្តីនីមួយៗមានបិទនៅលើក្តារព័ត៌មាននៅក្នុងតុលាការនីមួយៗក៏ដោយ មិនមានប្រភពអ៊ីនធឺណិតណាមួយអាចផ្តល់ព័ត៌មានទាំងនេះបានទេ។[179] ជាងនេះទៅទៀត មិនមានគេហទំព័រណាមានព័ត៌មានគ្រប់ជ្រុងជ្រោយពីវិស័យតុលាការនោះទេ។ ជាឧទាហរណ៍ មិនមានគេហទំព័រដែលដំណើរការល្អ

[175] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣២៤

[176] មាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[177] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ២០១៤ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍ [របាយការណ៍ម.ស.ម.ក ឆ្នាំ២០១៤] ទំព័រ៧-៨

[178] របាយការណ៍អង្គការតម្លាភាពកម្ពុជា ឆ្នាំ២០១៤ ដូចកំណត់សម្គាល់ខាងលើលេខ៧២ ទំព័រ៥៧

[179] របាយការណ៍អង្គការតម្លាភាពកម្ពុជា ឆ្នាំ២០១៤ ដូចកំណត់សម្គាល់ខាងលើលេខ៧២ ទំព័រ៥៧

សម្រាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះទេ ហើយក៏មិនមានគេហទំព័រសម្រាប់តុលាការកំពូលដែរ។[180] ដូច្នេះហើយ កង្វះខាតនៃការទទួលបានព័ត៌មានរៀបរាប់ខាងលើប៉ះពាល់ដល់សមត្ថភាពរបស់សាធារណជនក្នុងការចូលរួមក្នុងសវនាការជាសាធារណៈ។

### គ. សិទ្ធិទទួលការសន្មតទុកជាមុនថាគ្មានទោស

សិទ្ធិទទួលការសន្មតទុកជាមុនថាគ្មានទោស មានសារៈសំខាន់ណាស់នៅក្នុងការការពារសិទ្ធិមនុស្ស។[181] នេះជាបទដ្ឋាននៃច្បាប់អន្តរជាតិ និងត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើន។[182] ជាឧទាហរណ៍ មាត្រា១៤ (២) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងថា «ជនដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌត្រូវបានសន្មតជាមុនថាគ្មានទោស រហូតពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់»។[183] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា "ជនជាប់ចោទណាក៏ដោយត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ នេះមានន័យថា ជនដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌមិនត្រូវកំណត់ថាមានទោស ដោយមិនមានការជំនុំជម្រះក្ដីនោះទេ។ គោលបំណងចម្បងនៃគោលការណ៍នេះគឺការពារជនស្លូតត្រង់ពីការកាត់ទោស ទោះបីវាមានន័យថា ជនទុច្ចរិតមួយចំនួនមិនត្រូវបានកាត់ទោសក៏ដោយ។[184]

សិទ្ធិទទួលការសន្មតទុកជាមុនថាគ្មានទោសមិនអាចត្រូវបាត់បង់នោះទេ ទោះក្នុងទម្រង់អ្វីក៏ដោយ សូម្បីតែក្នុងពេលមានសង្គ្រាម ឬគ្រាមានអាសន្នបន្ទាន់ជាសាធារណៈក៏ដោយ។[185]

---

[180] របាយការណ៍អង្គការតម្លាភាពកម្ពុជា ឆ្នាំ២០១៤ ដូចកំណត់សម្គាល់ខាងលើលេខ៧២ ទំព័រ៥៨

[181] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ៣២៖ មាត្រា១៤៖ សិទ្ធិសមភាពនៅចំពោះមុខតុលាការ និងអង្គជំនុំជម្រះក្ដី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ចុះថ្ងៃទី២៣ ខែសីហា ២០០៧ លេខ CCPR/C/GC/32, [អត្ថាធិប្បាយទូទៅលេខ៣២] កថាខណ្ឌទី៣០។

[182] មាត្រា៦(២) នៃអនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន; មាត្រា៨(២) នៃអនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស; មាត្រា៧(១)(ខ) នៃរដ្ឋធម្មនុញ្ញអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស; គោលការណ៍ទី២០(១) នៃសេចក្ដីប្រកាសអាស៊ាន

[183] មាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[184] Naughton, M ឆ្នាំ២០១១ «វិធីដែលគោលការណ៍សន្មតជាមុនថាគ្មានទោសធ្វើឲ្យជនស្លូតត្រង់ងាយគ្រោះដោយសារការកាត់ទោសខុស» Irish Journal of Legal Studies ព្រឹត្តិបត្រទី២ លេខ១ ទំព័រ៤១

[185] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៦

សិទ្ធិត្រូវអនុវត្តនៅក្នុងគ្រប់នីតិវិធីព្រហ្មទណ្ឌ រាប់ចាប់ពីនីតិវិធីមុនការជំនុំជម្រះ ឬសូម្បីតែមុនមានបណ្តឹងអាជ្ញា រហូតដល់សាលដីកាចុងក្រោយចូលជាស្ថាពរ។[186]

ជាការអនុវត្ត មានលក្ខខណ្ឌមួយចំនួនត្រូវបំពេញដើម្បីទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ ទី១ វាជាបន្ទុករបស់ព្រះរាជអាជ្ញាក្នុងការបង្ហាញថា ជនជាប់ចោទមានពិរុទ្ធភាពដោយគ្មានវិមតិសង្ស័យ។ ជនជាប់ចោទមិនមានបន្ទុកក្នុងការបង្ហាញថា ខ្លួនគ្មានពិរុទ្ធភាពនោះទេ។[187] ប្រសិនបើមានវិមតិសង្ស័យ ការសេចក្តីសម្រេចជាផលប្រយោជន៍របស់ជនជាប់ចោទ ទោះជាលទ្ធភាពត្រូវឲ្យមានការដោះលែង ឬបន្ត នីតិវិធីក៏ដោយ។[188]

ជាទ្រឹស្តី ការបដិសេធមិនឲ្យមានការនៅក្រៅឃុំមុនមានការជំនុំជម្រះ មិនប៉ះពាល់ដល់សិទ្ធិទទួលការសន្មតទុកជាមុនថាគ្មានទោសនោះទេ។[189] ទោះជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចបដិសេធនេះត្រូវតែមានមូលដ្ឋានច្បាប់គ្រប់គ្រាន់ដោយ ស្របតាមគោលការណ៍ទទួលការសន្មតទុកជាមុនថាគ្មានទោស។[190] ការឃុំខ្លួនយូរហួសហេតុ និងស្ថានភាពអាក្រក់នៅក្នុងពន្ធនាគារ អាចនឹងរំលោភបំពានដល់គោលការណ៍ទទួលការសន្មតទុកជាមុនថាគ្មានទោស ប្រសិនបើមិនមានហេតុផលគ្រាប់គ្រាន់។[191]

គោលការណ៍ទទួលការសន្មតទុកជាមុនថាគ្មានទោសទាមទារឲ្យចៅក្រមមិនត្រូវសន្មតពីពិរុទ្ធភាពរបស់ជនជាប់ចោទនោះទេ។[192] ចៅក្រមក៏មិនត្រូវធ្វើបុរេវិនិច្ឆ័យលើរឿងក្តីដែរ៖ "មិនត្រឹមតែត្រូវស្វែងរកយុត្តិធម៌នោះទេ ប៉ុន្តែក៏ត្រូវបង្ហាញឲ្យឃើញថា មានយុត្តិធម៌ផងដែរ"។[193] ការហាមឃាត់មិនឲ្យមានបុរេវិនិច្ឆ័យក៏តម្រូវឲ្យនគរបាល មន្ត្រីតុលាការ រដ្ឋាភិបាល និងសារព័ត៌មានមិនអាចធ្វើអត្ថាធិប្បាយជាសាធារណៈ ដែលអាចបង្កប់អត្ថន័យថា ជនជាប់ចោទមាន

---

[186] Nowak Commentary ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៣០

[187] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣០

[188] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[189] Nowak Commentary ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៣០

[190] Amnesty International, (ការបោះពុម្ពលើកទី២) ឆ្នាំ២០១៤ សៀវភៅស្តីការជំនុំជម្រះដោយយុត្តិធម៌ ទំព័រ ១២៧

[191] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣០

[192] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣០

[193] សូមមើលរឿងក្តី R v Sussex Justices, Ex parte McCarthy លេខ [1924 1 KB 256, [1923] All ER Rep 233

ពិរុទ្ធភាពមុនតុលាការចេញសាលដីកា ឬនៅក្រោយការដោះលែងជនជាប់ចោទ។[194] ប្រសិនបើមានការអត្ថាធិប្បាយធ្វើឡើង រដ្ឋត្រូវចាត់វិធានការចំពោះបញ្ហានេះ។[195]

គោលការណ៍ទទួលការសន្មតទុកជាមុនថាគ្មានទោសអាចនឹងប៉ះពាល់ ប្រសិនបើជនជាប់ចោទស្ថិតនៅក្នុងសវនាការ ដោយសភាពនៅក្នុងទ្រុង ជាប់ខ្នោះដៃ ច្រវ៉ាក់ជើង ឬពាក់ឯកសណ្ឋានពន្ធនាគារ។[196] ស្ថានភាពរបស់ជនជាប់ចោទ នៅក្នុងបន្ទប់សវនាការក៏អាចធ្វើឲ្យប៉ះពាល់ដល់គោលការណ៍ទទួលការសន្មតទុកជាមុនថាគ្មានទោសផងដែរ ប្រសិនបើតុលាការមិនបានគ្រប់គ្រងឥរិយាបថក្អេងក្អាងរបស់ព្រះរាជអាជ្ញា ឬសាធារណជនដែលចូលរួម។[197]

នៅក្នុងការអនុវត្តជាក់ស្តែង សិទ្ធិទទួលការសន្មតទុកជាមុនថាគ្មានទោសត្រូវបានគេបំពានជារឿយៗនៅក្នុងប្រទេសកម្ពុជា។ ទោះណាមានលក្ខខណ្ឌច្រើនសម្រាប់ការកាត់ទោសក៏ដោយ អត្រានៃការកាត់ទោសមានច្រើនគួរឲ្យបារម្ភ។[198] ចៅក្រមភាគច្រើនពឹងផ្អែកលើការផ្តល់សក្ខីកម្មរបស់សាក្សី និងជាពិសេសលើរបាយការណ៍នគរបាល ដែលជារឿយៗមានការសារភាពរបស់ជនជាប់ចោទ ធ្វើឡើងតាមរយៈការធ្វើទារុណកម្ម និងគំរាមកំហែង។[199] ជាលទ្ធផល នៅពេលមានតែភស្តុតាងដាក់បន្ទុក ចៅក្រមអាចនឹងធ្វើបុរេវិនិច្ឆ័យលើសេចក្តីសម្រេចដោយមិនដឹងខ្លួន។ ម្យ៉ាងទៀត កង្វះចៅក្រមគ្រប់គ្រាន់[200] អាចនឹងដាក់សម្ពាធបន្ថែមទៅលើចៅក្រមឲ្យកាត់ក្តីឲ្យបានលឿន និងមិនបានវិភាគលើភស្តុតាងឲ្យបានគ្រប់ជ្រុងជ្រោយ។ លើសពីនេះទៅទៀត ចៅក្រមអាចរួចខ្លួនពីការស៊ើបអង្កេត ឬការដាក់ពិន័យ នៅពេលដែលខ្លួនមិនមានហេតុផលគ្រប់គ្រាន់សម្រាប់សេចក្តីសម្រេចរបស់ខ្លួន។ ដូច្នេះ វាបានធ្វើឲ្យការអនុវត្តមួយដែលទំនងនឹងប៉ះពាល់ដល់សិទ្ធិទទួលការសន្មតទុកជាមុនថា គ្មានទោសរបស់ជនជាប់ចោទ។[201]

សិទ្ធិទទួលការសន្មតទុកជាមុនថា គ្មានទោសរបស់ជនជាប់ចោទ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានប៉ះពាល់យ៉ាងខ្លាំង ដោយសារតែការនិយាយតៗគ្នាអំពី

---

[194] អត្ថាធិប្បាយទូទៅលេខ១៣ ដូចកំណត់សម្គាល់ខាងលើលេខ២៦ កថាខណ្ឌទី៧

[195] Nowak Commentary ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៣០

[196] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣០

[197] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី២៥

[198] Freedom House ឆ្នាំ២០១២ ប្រទេសដល់ផ្លូវបត់ ឆ្នាំ២០១២៖ កម្ពុជា ផ្នែកស្តីពីនីតិរដ្ឋ បោះពុម្ពនៅរដ្ឋធានីវ៉ាស៊ីនតោន ទំព័រ៨

[199] Freedom House ឆ្នាំ២០១២ ប្រទេសដល់ផ្លូវបត់ ឆ្នាំ២០១២៖ កម្ពុជា ផ្នែកស្តីពីនីតិរដ្ឋ បោះពុម្ពនៅរដ្ឋធានីវ៉ាស៊ីនតោន ទំព័រ៨

[200] ក្រសួងការបរទេសអាមេរិក ដូចកំណត់សម្គាល់ខាងលើលេខ៣៩ ទំព័រ៨-៩

[201] របាយការណ៍អង្គការតម្លាភាពកម្ពុជា ឆ្នាំ២០១៤ ដូចកំណត់សម្គាល់ខាងលើលេខ៧២ ទំព័រ៦០

ប្រវត្តិសាស្ត្រពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ សារព័ត៌មានក្នុងស្រុកបានដើរតួដ៏សំខាន់ក្នុងការបណ្តុះគំនិតរបស់សាធារណជន ឲ្យសន្មតពីពិរុទ្ធភាពរបស់ជនជាប់ចោទ។[202]

### ឃ. សមភាពនៃការតទល់គ្នាតាមផ្លូវតុលាការ

គោលការណ៍សមភាពនៃការតទល់គ្នាតាមផ្លូវតុលាការគឺជាធាតុ «កើតឡើងដោយខ្លួនឯង» និង «អរូបិយ៍» នៃការជំនុំជម្រះដោយយុត្តិធម៌។[203] គោលការណ៍មានឥទ្ធិពលលើភាពជឿទុកចិត្តនៃដំណើរការតុលាការទាំងមូល។ គោលការណ៍នេះកើតចេញពីគោលគំនិត "សមភាព" នៅចំពោះមុខតុលាការ ដែលមានបំណងការពារនីតិរដ្ឋ។[204] និយាយឲ្យខ្លីទៅវាសំដៅដល់សមភាពរវាងគូភាគីនៅក្នុងនីតិវិធីព្រហ្មទណ្ឌ និងមិនអនុញ្ញាតឲ្យភាគីណាមួយមានឱកាសច្រើនជាងភាគីម្ខាងទៀតនោះទេ។[205] គោលការណ៍នេះមានចែងនៅក្នុងមាត្រា១៤(១) និងមាត្រា១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទោះបីជាគោលការណ៍នេះទំនងពាក់ព័ន្ធច្រើនជាងនៅក្នុងប្រព័ន្ធច្បាប់ ដែលមានគូភាគីតទល់គ្នាក៏ដោយ[206] គោលការណ៍នេះ ក៏ត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ផ្សេងៗដែរ«ដោយមិនថាតើនីតិវិធីធ្វើឡើងដោយរបៀបណានោះទេ»[207] រួមទាំងប្រព័ន្ធច្បាប់ដែលមានការចោទសួរពីចៅក្រមផងដែរ។[208]

គោលការណ៍សមភាពនៃការតទល់គ្នាតាមផ្លូវតុលាការ បង្ហាញពីសិទ្ធិជាច្រើននៅក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅក្នុងលិខិតូបករណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សអន្តរជាតិ។[209] ទោះជាយ៉ាងណាក៏ដោយ

---

[202] Barton, C ឆ្នាំ២០០៧ «ការសន្មតពីពិរុទ្ធភាពជាមុនអាចប៉ះពាល់ដល់សាលាក្តីខ្មែរក្រហម» កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី២៧ ខែកក្កដា អាននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ នៅលើគេហទំព័រ http://www.phnompenhpost.com/national/presumed-guilt-could-taint-krt

[203] Summers, SJ ឆ្នាំ២០០៧ ការជំនុំជម្រះដោយយុត្តិធម៌៖ ទម្លាប់នៃនីតិវិធីព្រហ្មទណ្ឌនៅអឺរ៉ុប និងតុលាការសិទ្ធិមនុស្សអឺរ៉ុប បោះពុម្ពដោយ Hart Publishing នៅក្រុង Oxford ទំព័រ១០៤

[204] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី២

[205] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៧-១៤; Summers ដូចកំណត់សម្គាល់ខាងលើលេខ១០៨ ទំព័រ១០៥

[206] Tuinstra, JPWT ឆ្នាំ២០០៩ Defence Counsel in International Criminal Law, The Hague: T.M.C. បោះពុម្ពដោយ Asser Press ទំព័រ៣

[207] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣

[208] Summers ដូចកំណត់សម្គាល់ខាងលើលេខ១០៨ ទំព័រ១០៤

[209] មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ; មាត្រា៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

គោលការណ៍មិនមានន័យថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាមួយត្រូវបានគោរពនោះទេ។ ផ្ទុយទៅវិញវាធានាឲ្យបានថា សិទ្ធិទាំងនេះត្រូវបានអនុវត្តត្រឹមត្រូវ ជាមួយនឹងសិទ្ធិដទៃទៀត។[210] និយាយឲ្យខ្លី គោលការណ៍សមភាពនៃការតទល់គ្នាតាមផ្លូវតុលាការមានន័យថា ជនជាប់ចោទមានសិទ្ធិទទួលបានព័ត៌មានភ្លាមៗពីបទចោទមកលើខ្លួន មានពេលវេលា និងធនធានគ្រប់គ្រាន់ដើម្បីធ្វើការការពារខ្លួន[211] ដឹងពីភស្តុតាងដាក់បន្ទុកលើខ្លួន និងអាចនិយាយតទល់ពីភស្តុតាងទាំងនោះ រួមទាំងការសាកសួរសាក្សីរបស់ភាគីបដិបក្ខ និងទទួលបានការចូលរួមរបស់សាក្សីខ្លួន។[212]

តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសន្និដ្ឋានថា គោលការណ៍នឹងត្រូវបំពាន ដោយមិនចាំបាច់មាន "អសមភាពកើតចេញពីនីតិវិធីច្រើនដង" នោះទេ។[213] ការបំពានសិទ្ធិនេះនឹងកើតឡើង នៅពេលដែលមានអសមភាព ឬការមិនគោរពសិទ្ធិណាមួយដែលរារាំងការទទួលបានយុត្តិធម៌របស់ជនជាប់ចោទ។ វាមិនចាំបាច់ថា ទាល់តែនីតិវិធីទាំងមូលមិនមានយុត្តិធម៌នោះទេ ដោយសារតែលក្ខខណ្ឌនីតិវិធីជាក់លាក់មួយត្រូវបានគេមើលរំលងរួចទៅហើយ។[214]

ក្នុងរឿងក្តី០០១ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បញ្ហាទាក់ទងនឹងគោលការណ៍សមភាពនៃការតទល់គ្នាតាមផ្លូវតុលាការបានកើតឡើង នៅពេលដែលមេធាវីការពារជនជាប់ចោទអះអាងថា របៀប និងកម្រិតដែលមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើ (ការគាំទ្រលើការកាត់ទោស) បានធ្វើឲ្យមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្លាយជា "ព្រះរាជអាជ្ញាទីពីរ"។[215] នៅក្នុងដីកាសម្រេចពាក់ព័ន្ធការអះអាងនេះ ក្រុមជំនុំជម្រះបានបរាជ័យក្នុងការ

---

[210] Summers ដូចកំណត់សម្គាល់ខាងលើលេខ១០៨ ទំព័រ១០៤

[211] មាត្រា៦៧(១)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារអង្គការសហប្រជាជាតិ លេខ A Conf. 183/9, 1998 ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ [លក្ខន្តិកៈទីក្រុងរ៉ូម]

[212] មាត្រា៦៧(១)(ង) នៃលក្ខន្តិកៈទីក្រុងរ៉ូម

[213] រឿងក្តី Lanz v Austria សាលដីការបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ឯកសារលេខ Appl. No. 24430/94 ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០២ §៥៨

[214] រឿងក្តី Öcalan v Turkey សាលដីការបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ឯកសារលេខ App. no. 46221/99 ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០០៥ §១៤៦

[215] Asian International Justice Initiative's Khmer Rouge Tribunal Trial Monitoring Group (AIJI) ឆ្នាំ២០០៩ Lessons Learned from the 'Duch' Trial: A Comprehensive Review of the First Case before the Extraordinary Chambers in the Courts of Cambodia, [របាយការណ៍ AIJI ឆ្នាំ២០០៩] ទំព័រ២២ អាននៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ នៅលើគេហទំព័រ

បញ្ជាក់ឲ្យច្បាស់ពីតួនាទី របស់មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធីតុលាការ និងមិនមានបញ្ជាក់ឡើងវិញពីសិទ្ធិរបស់ជនជាប់ចោទក្នុងការ "ប្រឈមមុខនឹងព្រះរាជអាជ្ញាតែមួយប៉ុណ្ណោះ"។[216]

### ង. សិទ្ធិត្រៀមខ្លួនគ្រប់គ្រាន់

គោលការណ៍សមភាពនៃការតទល់គ្នាតាមផ្លូវតុលាការទាមទារឲ្យគូភាគីចូលរួមក្នុងនីតិវិធី ដើម្បីមានពេល និងធនធានគ្រប់គ្រាន់ដើម្បីត្រៀមការពាររឿងក្តីរបស់ខ្លួន។ នេះជាធាតុផ្សំដ៏សំខាន់ ដើម្បីការពារឲ្យមានការជំនុំជម្រះដោយយុត្តិធម៌ និងការអនុវត្តសិទ្ធិផ្សេងទៀត។[217] សិទ្ធិទទួលបានពេលវេលា និងធនធានគ្រប់គ្រាន់ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទ «ក្នុងការទទួលបានព័ត៌មានលម្អិតភ្លាមៗ និងទទួលបានព័ត៌មានក្នុងភាសាដែលជនជាប់ចោទយល់ពីមូលហេតុនៃការចោទប្រកាន់»។[218] ដូច្នេះបើជនជាប់ចោទដឹងពីការចោទប្រកាន់មកលើខ្លួនកាន់តែឆាប់ ជនជាប់ចោទនឹងមានពេលវេលាកាន់តែច្រើន ក្នុងការត្រៀមការពារខ្លួន។ សិទ្ធិនេះក៏ទាមទារឲ្យអាជ្ញាធរមានសមត្ថកិច្ចដែលធ្វើការពាក់ព័ន្ធការបទល្មើសព្រហ្មទណ្ឌ ធ្វើសេចក្តីជូនដំណឹងផ្លូវការពីបទចោទ ឬឈ្មោះរបស់ជនជាប់ចោទ ឬជនសង្ស័យឲ្យបានលឿនតាមតែអាចធ្វើទៅបាន»។[219]

ចំពោះសិទ្ធិទទួលបានធនធានគ្រប់គ្រាន់ ជនជាប់ចោទមានសិទ្ធិទទួលបានឯកសារ និងភស្តុតាង និងជំនួយផ្នែកច្បាប់ ដើម្បីឲ្យពួកគេអាចត្រៀមការពារខ្លួននៅក្នុងរឿងក្តី។[220] លើសពីនេះទៅទៀត ឯកសារ និងភស្តុតាងទាំងអស់ មិនថាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកនោះទេ ត្រូវតែបង្ហាញឲ្យគ្រប់ភាគីបានឃើញ ជាពិសេសគឺជនជាប់ចោទ។[221] ទាំងនេះរួមមានភស្តុតាងដែលមានផលប្រយោជន៍ដល់ជនជាប់ចោទ និងភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ឬការសារភាពដោយបង្ខំ។[222] នៅក្នុងរឿងក្តីរវាង *Van Marcke* ទល់នឹង

---

https://www.ocf.berkeley.edu/~changmin/documents/Lessons%20Learned%20from%20the%20Duch%20Trial_MRSK_FINAL.pdf

216 របាយការណ៍ AIJI ឆ្នាំ២០០៩ ទំព័រ២២

217 អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣២

218 មាត្រា១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ; មាត្រា៣២២ ៣២៥ ៣៣០ និង៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

219 អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣១

220 អត្ថាធិប្បាយទូទៅលេខ១៣ ដូចកំណត់សម្គាល់ខាងលើលេខ២៦ កថាខណ្ឌទី៩

221 អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣៣

222 អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣៣

ប្រទេសបែលហ្សិក[223] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិយល់ឃើញថា រដ្ឋអាជ្ញាមិនបានតម្រូវឲ្យដាក់ឯកសារ និងភស្តុតាងទាំងអស់នៅចំពោះមុខតុលាការនោះទេ លើកលែងតែការខកខានមិនបានបង្ហាញព័ត៌មានមួយចំនួនមិនបានប៉ះពាល់នឹងការការពារខ្លួនរបស់ជនជាប់ចោទនោះ។

សិទ្ធិក្នុងការត្រៀមការពារគ្រប់គ្រាន់ ក៏ទាមទារឲ្យជនជាប់ចោទទទួលបានជំនួយផ្នែកច្បាប់ នៅក្នុងគ្រប់នីតិវិធីព្រហ្មទណ្ឌទាំងអស់។ មាត្រា១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងថា ជនជាប់ចោទអាចរើសយកការការពារខ្លួន ឬមានការតំណាងដើម្បីការពារខ្លួន។ សិទ្ធិនេះក៏ទាមទារឲ្យជនជាប់ចោទជួបជាមួយនឹងមេធាវីរបស់ខ្លួនភ្លាមៗ[224] ហើយទំនាក់ទំនងជាឯកជនរវាងជនជាប់ចោទ និងមេធាវីត្រូវបានរក្សាការសម្ងាត់។[225]

ទោះជាគោលការណ៍សមភាពនៃការតទល់គ្នា តាមផ្លូវតុលាការទាមទារឲ្យជនជាប់ចោទមានសិទ្ធិទទួលបានធនធានគ្រប់គ្រាន់ក៏ដោយ គោលការណ៍នេះមិនតម្រូវឲ្យមានធនធានគ្រប់គ្រាន់ដូចគ្នាទៅនឹងព្រះរាជអាជ្ញានោះទេ។ នៅក្នុងរឿងក្តីរវាង*រដ្ឋអាជ្ញា*ទល់នឹង *Kayishema* មេធាវីការពារជនជាប់ចោទបានអះអាងថា គោលការណ៍សមភាពនៃការតទល់គ្នាតាមផ្លូវតុលាការទាមទារឲ្យអង្គជំនុំជម្រះផ្តល់ចំនួនមេធាវី អ្នកស៊ើបអង្កេត និងជំនួយការផ្នែកច្បាប់ប្រហាក់ប្រហែលគ្នាទៅឲ្យមេធាវីការពារជនជាប់ចោទ ឲ្យដូចនឹងចំនួនដែលរដ្ឋអាជ្ញាទទួលបាន ដើម្បី "ផ្តល់ភាពយុត្តិធម៌"។[226] នៅពេលច្រានចោលការអះអាងបែបនេះ អង្គជំនុំជម្រះបានអះអាងថា គោលការណ៍សមភាពនៃការតទល់គ្នា តាមផ្លូវតុលាការមិនតម្រូវឲ្យមេធាវីជនជាប់ចោទមាន "មធ្យោបាយ និងធនធានដូចគ្នានឹងរដ្ឋអាជ្ញានោះទេ"។[227] អង្គជំនុំជម្រះនៅសាលាឧទ្ធរណ៍ការពារសេចក្តីសម្រេចនេះ ដោយកត់សម្គាល់ថា គួរយល់ថា គោលការណ៍សមភាពនៃការ

---

[223] រឿងក្តីរវាង Van Marcke ទល់នឹងប្រទេសបែលហ្សិក លិខិតទំនាក់ទំនងរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ 904/2000 ឯកសារអង្គការសហប្រជាជាតិលេខ CCPR/C/81/D/904/2000 (២០០៤) កថាខណ្ឌទី៨.៣

[224] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣៤

[225] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី៣៤

[226] រឿងក្តីរវាងរដ្ឋអាជ្ញា ទល់នឹង Kayishema រឿងក្តីលេខ ICTR-95-I-T, សាលដីការបស់ក្រុមជំនុំជម្រះក្តី កថាខណ្ឌ២០ និង៥៥-៦០ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩

[227] រឿងក្តីរវាងរដ្ឋអាជ្ញា ទល់នឹង Kayishema រឿងក្តីលេខ ICTR-95-I-T, សាលដីការបស់ក្រុមជំនុំជម្រះក្តី កថាខណ្ឌ៦០

តទល់គ្នាតាមផ្លូវតុលាការ ជាសមភាពនៃសិទ្ធិ ប៉ុន្តែមិនមែនសមភាពនៃធនធាន និងមធ្យោបាយនោះទេ។[228]

នៅក្នុងប្រទេសកម្ពុជា សាលាឧទ្ធរណ៍ទំនងដូចជាមានការអនុវត្តល្អ ដោយគោរពដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការយល់ដឹងពីមូលហេតុនៃបទចោទ។ នៅក្នុងរឿងក្តីភាគច្រើន ជនជាប់ចោទ ដែលបានចូលរួមនៅក្នុងការជំនុំជម្រះ ទទួលបានព័ត៌មានម្តងទៀតពីបទចោទ អង្គហេតុ កាលបរិច្ឆេទ និងព័ត៌មានផ្សេងទៀតទាក់ទងនឹងការចោទប្រកាន់។[229]

### ច. សិទ្ធិមានមេធាវី

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមានចែងពីភាពយុត្តិធម៌ និងសមភាព នៅចំពោះមុខតុលាការឯករាជ្យ និងមិនលម្អៀង រួមទាំងសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ក្នុងការធានាថា ជនជាប់ចោទទទួលបានយុត្តិធម៌ទៅតាមនីតិវិធីច្បាប់។[230] សិទ្ធិនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំសំខាន់ៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[231] វាមានភាពចាំបាច់ណាស់ក្នុងការទទួលបានសមភាពសម្រាប់គូភាគីដែលទាមទារ «[...] ភាគីនីមួយៗមានឱកាសដើម្បីដេញដោលអំណះអំណាង និងភស្តុតាង លើកឡើងដោយភាគីម្ខាងទៀត»។[232] សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ក៏ជាមធ្យោបាយដ៏សំខាន់ក្នុងការទម្លុះរបាំងទទួលបានយុត្តិធម៌ ជាពិសេសសម្រាប់ជនជាប់ចោទក្រីក្រ។[233]

សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ជាទូទៅ ត្រូវសន្មតថា បានអនុវត្តនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីព្រហ្មទណ្ឌ រួមទាំងដំណាក់កាលស៊ើបសួរ។ ដូច្នេះហើយ នៅក្នុងរឿងក្តីរវាង *Aliev នឹងប្រទេសអ៊ុយក្រែន* ជនជាប់ចោទប្រឈមមុខនឹងទោសប្រហារជីវិត ប្រសិនបើរកឃើញថាមានពិរុទ្ធភាព។ ប៉ុន្តែលោកមិនទទួលបានមេធាវី អស់រយៈពេល ៥ខែ នៅពេល

[228] រឿងក្តីរវាងរដ្ឋអាជ្ញា ទល់នឹង Kayishema រឿងក្តីលេខ ICTR-95-I-T, សាលដីការបស់ក្រុមជំនុំជម្រះក្តី កថាខណ្ឌ៥៨-៦០

[229] របាយការណ៍ម.ស.ម.ក ឆ្នាំ២០១៤ ដូចកំណត់សម្គាល់ខាងលើលេខ៨១ ទំព័រ៩-១០

[230] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី១០

[231] Tuinstra ដូចកំណត់សម្គាល់ខាងលើលេខ១១១ ទំព័រ៤៦៣

[232] អត្ថាធិប្បាយទូទៅលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌទី១៣

[233] Inter-American Commission on Human Rights, Access to Justice as a Guarantee of Economic, Social and Cultural Rights: A Review of the Standards Adopted by the Inter-American System of Human Rights, OEA/Ser.L/V/II.129, doc. 4 ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌទី៧

លោកត្រូវបានឃុំខ្លួន រងចាំការជំនុំជម្រះ។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិយល់ឃើញថា សិទ្ធិក្នុងការទទួលបានមេធាវីរបស់លោក Aliev ត្រូវបានបំពាន។[234]

យោងតាមគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ មេធាវីមានតួនាទីជួយតុលាការ ដូចជា"ភ្នាក់ងារដ៏សំខាន់នៃយុត្តិធម៌"។[235] មេធាវីការពារជនជាប់ចោទមានសមត្ថភាព ឯករាជ្យ និងអង់អាចម្នាក់ មានសារៈសំខាន់ណាស់ក្នុងការជួយតុលាការព្រហ្មទណ្ឌ ដើម្បីធានាថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានគោរព ភស្តុតាងដាក់បន្ទុក ត្រូវបានវិនិច្ឆ័យពេញលេញ និងគោលការណ៍ច្បាប់ត្រូវបានអនុវត្តត្រឹមត្រូវ។ នៅក្នុងប្រព័ន្ធច្បាប់ដែលមានគូភាគីតទល់គ្នា គោលការណ៍នៃបុរេវិនិច្ឆ័យតម្រូវឲ្យមេធាវីតំណាងឲ្យកូនក្តីខ្លួនឲ្យអស់ពីលទ្ធភាព។[236] គោលការណ៍នេះក៏ទាមទារឲ្យមេធាវីធ្វើការដោយប្រុងប្រយ័ត្ន ពិនិត្យមើលគ្រប់មធ្យោបាយច្បាប់ ដើម្បីធានាថាសិទ្ធិរបស់កូនក្តីក្នុងការទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌ត្រូវបានការពារ នៅចំពោះមុខគូបដិបក្ខ ដែលមានការគាំទ្រពីធនធានរបស់រដ្ឋ។[237] ទោះណាសិទ្ធិបុគ្គល និងសេរីភាពរបស់ជនជាប់ចោទជារឿយៗត្រូវបាត់បង់ក៏ដោយ វាចាំបាច់ណាស់សម្រាប់ជនជាប់ចោទក្នុងការមានមេធាវីតំណាងដែលមានសមត្ថភាព និងអាចផ្តល់យោបល់ត្រឹមត្រូវចំពោះវិធីក្នុងការការពារបទចោទដោយជោគជ័យ។

ស្របតាមច្បាប់កម្ពុជា ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិក្នុងការជ្រើសរើសយកជំនួយផ្នែកច្បាប់។[238] រដ្ឋធម្មនុញ្ញកម្ពុជាបានទទួលស្គាល់យ៉ាងច្បាស់ពីសិទ្ធិក្នុងការទទួលបានជំនួយផ្នែកច្បាប់ ដោយបានចែងថា "ជនគ្រប់រូបមានសិទ្ធការពារខ្លួនតាមផ្លូវតុលាការ"។[239] រដ្ឋធម្មនុញ្ញក៏មានបញ្ចូលសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗផងដែរ[240] ដែលកម្ពុជាជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាទាំងនោះ។ គោលការណ៍ទាំងនេះផ្តល់ឲ្យជន

---

[234] រឿងក្តីរវាង Aliev ទល់នឹងប្រទេសអ៊ុយក្រែន គណៈកម្មាធិការសិទ្ធិមនុស្ស ឯកសារលេខ CCPR/C/78/D/781/1997 ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ ៧.២ ៧.៣ & ៨

[235] គោលការណ៍ជាមូលដ្ឋាន ដូចកំណត់សម្គាល់ខាងលើលេខ៥៨ គោលការណ៍ទី១២

[236] Dare, T ឆ្នា២០០៩ The Counsel of Rogues? A Defense of the Standard Conception of the Lawyer's Role, Burlington, TV: Ashgate ទំព័រ៥

[237] See Kerr, K ឆ្នាំ២០០៥ «Fair Trials at International Criminal Tribunals: Examining the Parameters of the International Right to Counsel» Georgetown Journal of International Law ព្រឹត្តបត្រទី៣៦ លេខ៤ ទំព័រ១២២៩

[238] មាត្រា៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[239] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[240] មាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា

ជាប់ចោទមានសិទ្ធិទទួលបានមេធាវី តាមការជ្រើសរើសរបស់ខ្លួន និងជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ សម្រាប់ជនជាប់ចោទក្រីក្រ ដែលចាំបាច់ត្រូវការយុត្តិធម៌។[241] ច្បាប់ជាតិក៏ទាមទារឲ្យជនជាប់ចោទពីបទល្មើសឧក្រិដ្ឋ ឬជនជាប់ចោទជាអនីតិជនទទួលបានជំនួយផ្នែកច្បាប់ផងដែរ។[242]

ប្រសិនបើជនជាប់ចោទមិនមានលទ្ធភាពដើម្បីពឹងពាក់មេធាវីនោះទេ ពួកគេអាច "ស្នើសុំឲ្យមានមេធាវីចាត់តាំងសម្រាប់តំណាងពួកគេ ដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី"។[243] នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទទួលខុសត្រូវធានាថា សិទ្ធិក្នុងការទទួលបានជំនួយផ្នែកច្បាប់ របស់ជនជាប់ចោទក្រីក្រត្រូវបានគោរព។[244] លើសពីនេះទៅទៀត មេធាវីចាត់តាំងឲ្យការពារជនជាប់ចោទត្រូវតំណាងកូនក្តីខ្លួនដូចទៅនឹងពេលតំណាងឲ្យកូនក្តីមានលទ្ធភាពបង់ថ្លៃមេធាវីដែរ។[245] បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីក៏បានចែងថា គណៈមេធាវីទទួលខុសត្រូវផ្តល់ថវិកា និងចាត់តាំងបុគ្គលិកផ្នែកច្បាប់ឲ្យផ្តល់សេវាកម្មច្បាប់ដល់ជនក្រីក្រ។[246]

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង សិទ្ធិទទួលជំនួយផ្នែកច្បាប់មិនត្រូវបានអនុវត្តគ្រប់គ្រាន់នោះទេ មួយផ្នែកធំដោយសារតែ មិនមានការគាំទ្រគ្រប់គ្រាន់ពីប្រព័ន្ធតុលាការ សម្រាប់ជំនួយផ្នែកច្បាប់ ដែលពឹងផ្អែកយ៉ាងខ្លាំងលើជំនួយពីខាងក្រៅ។[247] ជាលទ្ធ-ផលនៃការមិនមានមូលនិធិឧបត្ថម្ភបន្តទៀត ការិយាល័យឧត្តមស្នងការសិទ្ធិអង្គការសហប្រជាជាតិបានរកឃើញថា ចំនួនមេធាវីផ្តល់ជំនួយផ្នែកច្បាប់បានកាត់បន្ថយយ៉ាងខ្លាំងនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានមេធាវី១៩៩រូបនៅក្នុងឆ្នាំ២០១០ ធ្លាក់ចុះដល់៧៦រូប នៅក្នុងឆ្នាំ២០១៣។[248] ជាលទ្ធផល ជនជាប់ចោទត្រូវបានកាត់ទោស ដោយមិនមានជំនួយផ្នែកច្បាប់ ដោយមិនបានឲ្យពួកគេទទួលបានយុត្តិធម៌នោះទេ។[249]

---

241 មាត្រា១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

242 មាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

243 មាត្រា៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

244 មាត្រា៣០ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ [លក្ខន្តិកៈមេធាវី]

245 មាត្រា៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

246 មាត្រា៣០ នៃលក្ខន្តិកៈមេធាវី

247 របាយការណ៍របស់អ្នករាយការណ៍សិទ្ធិមនុស្សពិសេស ឆ្នាំ២០១៣ ដូចកំណត់សម្គាល់ខាងលើលេខ៦៦ កថាខណ្ឌទី២៥

248 Crothers, L ឆ្នាំ២០០៣ «Lack of Legal Aid in Cambodia Puts Children, Poor at Risk» កាសែត The Cambodia Daily ចុះថ្ងៃទី៣០ ខែវិច្ឆិកា អាននៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ នៅលើគេហទំព័រ

សំខាន់ជាងនេះទៅទៀត ចំនួនមេធាវីអនុវត្តច្បាប់មានចំនួនតិចតួចនៅឡើយ។[250] នេះរួមចំណែកដល់ប្រព័ន្ធយុត្តិធម៌មិនមានប្រសិទ្ធភាពយូរអង្វែង និងការមិនទទួលបានយុត្តិធម៌។ ទោះជាមានកង្វះខាតមេធាវីដោយសារតែរបបខ្មែរក្រហម ហើយចំនួននេះបានកើនឡើងជាលំដាប់ក្នុងរយៈពេល២០ឆ្នាំនេះក៏ដោយ ចំនួនមេធាវីនៅតែមានតិច បើប្រៀបធៀបនឹងចំនួនប្រជាជនសរុប និងតម្រូវការផ្នែកច្បាប់របស់ពួកគេ។[251]

## ៣.៣ សិទ្ធិក្រោយការជំនុំជម្រះ

### ក. សិទ្ធិស្នើសុំឱ្យពិនិត្យពិរុទ្ធភាព

មាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធានាថា "ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់។"[252] នីតិវិធីប្តឹងឧទ្ធរណ៍ដែលកម្រិតត្រឹមតែការពិនិត្យលើអង្គច្បាប់វិញ អាចមិនគ្រប់គ្រាន់ទេ។[253] នេះមិនមានន័យថានីតិវិធីប្តឹងឧទ្ធរណ៍កម្រិតត្រឹមការជំនុំជម្រះឡើងវិញលើអង្គហេតុប៉ុណ្ណោះនោះទេ។ វាតម្រូវឱ្យមានការវាយតម្លៃពេញលេញពីអង្គហេតុ និងអង្គច្បាប់ ដូចជាដំណើរការជំនុំជម្រះដែរ។[254] គ្រប់ជនជាប់ចោទទាំងអស់ត្រូវតែមានសិទ្ធិប្តឹងឧទ្ធរណ៍ ដោយមិនគិតពីស្ថានទម្ងន់ទោសនៃបទល្មើសនោះទេ។[255]

https://www.cambodiadaily.com/archives/lack-of-legal-aid-incambodia-puts-children-poor-at-risk-48219/

[249] Global Integrity Report ឆ្នាំ២០១២ ពិន្ទុសុចរិតភាពសកលៈ កម្ពុជា បោះពុម្ពឆ្នាំ២០១២ នៅរដ្ឋធានីវ៉ាស៊ីនតោន ដោយអង្គការ Global Integrity [របាយការណ៍អង្គការ Global Integrity ឆ្នាំ២០១២] សូចនាករណ៍លេខ៨២យ

[250] របាយការណ៍របស់អ្នករាយការណ៍សិទ្ធិមនុស្សពិសេស ឆ្នាំ២០១៣ ដូចកំណត់សម្គាល់ខាងលើលេខ៦៦ កថាខណ្ឌទី២៤

[251] របាយការណ៍អង្គការ Global Integrity ឆ្នាំ២០១២ ដូចកំណត់សម្គាល់ខាងលើលេខ១៥៤ សូចនាករណ៍លេខ៨០ខ

[252] មាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[253] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៤៨-៣៤៩

[254] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៤៩; អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ៨៥ កថាខណ្ឌ ៤៨

[255] *អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ១៣* កថាខណ្ឌ ៤៨

ក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ពីសិទ្ធិស្នើសុំឱ្យពិនិត្យពិរុទ្ធភាពបាន។[256] ខណៈដែលសាលាឧទ្ធរណ៍អាចពិនិត្យមើលលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើទាំងអង្គហេតុ និងអង្គច្បាប់[257] មាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងយ៉ាងច្បាស់ថាតុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់។ ទោះបីជាការអនុវត្តបែបនេះមានសង្គតភាពជាមួយនឹងការអនុវត្តនៅក្នុងប្រទេសមួយចំនួន គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានសង្កេតនៅក្នុងរឿងក្តី *Perra ទល់នឹងប្រទេសអូស្ត្រាលី*[258] និងរឿងក្តី *Gómez Vázquez ទល់នឹងប្រទេសអេស្ប៉ាញ*[259] ថាការត្រួតពិនិត្យលើការផ្តន្ទាទោសឡើងវិញកម្រិតតែត្រឹមបញ្ហាផ្នែកច្បាប់ធ្លាក់លើតម្រូវការនៃមាត្រា១៤(៥) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ហេតុដូចនេះ ក្រមនីតិវិធីព្រហ្មទណ្ឌហាក់ដូចជាខកខានបំពេញតាមស្តង់ដារដែលកំណត់ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

ដោយយោងតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នីតិវិធីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសត្រូវអាចធ្វើបាន។[260] ជាគោលការណ៍ សាលាឧទ្ធរណ៍មិនត្រូវសម្រេចលើភាពធ្ងន់ធ្ងរឡើងនៃការផ្តន្ទាទោស លើកលែងតែរដ្ឋ

[256] មាត្រា ៣៧៥ មាត្រា៤១៥ មាត្រា៤១៨ និងមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌៈ មាត្រា៤១៩ ចែងពីមូលហេតុនៃបណ្តឹងសាទុក្ខៈ តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចក្នុងករណីដូចតទៅៈ
- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថកិច្ចនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពាន ឬភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្តឹងសុំនេះ ធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- គ្មានសំអាងហេតុ
- ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច។

[257] Kong, P 2012 "ព័ត៌មានទូទៅពីប្រព័ន្ធច្បាប់ និងតុលាការកម្ពុជា" Hor, P, Kong, P & Menzel J (Eds.) 2012 *សេចក្តីផ្តើមច្បាប់កម្ពុជា* ភ្នំពេញ Konrad-Adenauer-Stiftung ទំព័រ ១១

[258] រឿងក្តីរវាង Perra ទល់នឹងប្រទេសអូស្ត្រាលី លេខ 536/1993 កថាខណ្ឌ 6.4

[259] រឿងក្តីរវាង Gómez Vázquez ទល់នឹងប្រទេសអេស្ប៉ាញ លេខ 701/1996 កថាខណ្ឌ 11.1

[260] រឿងក្តីរវាង Bandajevsky ទល់នឹង Belarus គណៈកម្មាធិការសិទ្ធិមនុស្ស ការទំនាក់ទំនង 1100/2002 UN Doc CCPR/C/86/D/1100/2002 (2006) កថាខណ្ឌ 10.13

ដាក់ការអនុវត្តបែបនោះជាខដាក់លក្ខខណ្ឌនៃមាត្រា ១៤(៥) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[261] ដោយអនុលោមតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៣៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនអនុញ្ញាតឱ្យសាលាឧទ្ធរណ៍ដាក់បន្ទុកបន្ថែមទៅលើការផ្តន្ទាទោស ដែលសាលក្រមគឺគ្រាន់តែលំអៀងទៅលើជនជាប់ចោទប៉ុណ្ណោះ។ ការរឹតត្បិតនេះក៏មានវិសាលភាពដល់សំណងហិរញ្ញវត្ថុសម្រាប់ភាគីរដ្ឋប្បវេណីផងដែរ ដែលសាលាឧទ្ធរណ៍មិនអាចតម្រូវឱ្យជនជាប់ចោទបង់ប្រាក់សំណងជម្ងឺចិត្តបន្ថែមទៀតនោះទេ។[262]

បន្ថែមពីលើនេះ គោលការណ៍ជាមូលដ្ឋាននៃសិទ្ធិប្តឹងឧទ្ធរណ៍គឺថាការធានានីតិវិធីទាំងអស់ត្រូវតែអនុវត្តនីតិវិធីប្តឹងឧទ្ធរណ៍សម្រាប់ឱ្យសិទ្ធិប្តឹងឧទ្ធរណ៍មានន័យ និងប្រសិទ្ធភាព។[263] ហេតុនេះ យើងអាចលើកឡើងបានថា ក្រមនីតិវិធីព្រហ្មទណ្ឌមានចែងនូវបទបញ្ញត្តិមួយចំនួនដែលធានាសិទ្ធិនីតិវិធីយ៉ាងស្មើភាពនៅសវនាការសាលាឧទ្ធរណ៍ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះតាមពេលវេលាកំណត់[264] (រួមទាំងសេចក្តីសម្រេចទៀងពេល[265]និងមានហេតុផល[266]) សិទ្ធិតំណាងដោយមេធាវី[267] សិទ្ធិទទួលបានសំណុំរឿង[268] មានពេលគ្រប់គ្រាន់ដើម្បីរៀបចំសារណាជាលាយលក្ខអក្សរ[269] និងសិទ្ធិទទួលបានសវនាការជាសាធារណៈ។[270] នៅពេលជនជាប់ចោទប្តឹងឧទ្ធរណ៍នឹងសាលក្រមទាំងអស់របស់សាលាដំបូង ឬពិរុទ្ធភាពតែប៉ុណ្ណោះ មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឱ្យពន្យារពេលការអនុវត្តសាលក្រមរហូតដល់មានសេចក្តីសម្រេចចុងក្រោយនៃនីតិវិធីប្តឹងឧទ្ធរណ៍។[271] សាលាឧទ្ធរណ៍មានឆន្ទានុសិទ្ធិសម្រេចថា ត្រូវដោះលែងជនជាប់ចោទឬអត់។[272] ជាចុងក្រោយ សិទ្ធិទទួលបានការត្រួតពិនិត្យឡើងវិញលើ

---

[261] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៥១

[262] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[263] អត្ថាធិប្បាយ Nowak ដូចកំណត់សម្គាល់ខាងលើលេខ២០ ទំព័រ៣៤៩-៣៥០

[264] មាត្រា ៣៨១ ៣៨២ ៣៨៣ ៣៨៤ ៣៨៦ ៣៨៧ ៤០៧ ៤២០ និង ៤៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[265] មាត្រា ៤៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[266] មាត្រា ៤០៣ និង ៤៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[267] មាត្រា ៣៧៦ ៤២២ និង ៤២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[268] មាត្រា ៣៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[269] មាត្រា ៤២៧ និង ៤២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[270] មាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[271] មាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[272] មាត្រា ៤១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សេចក្តីសម្រេចរបស់តុលាការកំពូលក៏ត្រូវបានធានាផងដែរ ក្នុងលក្ខខណ្ឌដែលរកឃើញថាមានភស្តុតាងថ្មីបង្ហាញពីភាពគ្មានកំហុសរបស់ជនជាប់ចោទ។[273]

ជាក់ស្តែង សិទ្ធិរបស់ទណ្ឌិតក្នុងការប្តឹងឧទ្ធរណ៍នៅកម្ពុជាត្រូវបានកាត់បន្ថយយ៉ាងច្រើន។ សមត្ថភាពមានកម្រិតនៃសាលាឧទ្ធរណ៍គឺជាបញ្ហាដែលគួរឲ្យកត់សម្គាល់។ សាលាឧទ្ធរណ៍មានតែមួយគត់ ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ សម្រាប់បម្រើឱ្យប្រទេសទាំងមូល។ ហេតុនេះ ជនជាប់ចោទដែលជាប់ពន្ធនាគារនៅតាមពន្ធនាគារខេត្ត ឬកន្លែងឃុំខ្លួន ត្រូវបញ្ជូនមករាជធានីភ្នំពេញ និងត្រូវរងចាំជាច្រើនថ្ងៃដើម្បីចូលសវនាការសាលាឧទ្ធរណ៍។[274]

នៅត្រង់ចំណុចនេះ របាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបង្ហាញពីក្តីបារម្ភខ្លាំងខ្លះៗដែរ ពីបញ្ហាទំនាក់ទំនងក្នុងដំណើរការបញ្ជូនដែលបន្ថយសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននីតិវិធីប្តឹងឧទ្ធរណ៍ឱ្យបានទាន់ពេលវេលា។ ខណៈដែលជនជាប់ចោទត្រូវបានបញ្ជូនមករាជធានីភ្នំពេញដើម្បីចូលសវនាការសាលាឧទ្ធរណ៍ ជារឿយៗមិនកើតមានឡើងនោះទេ ដោយសារតែការផ្តល់ព័ត៌មានខុសទៅឱ្យមណ្ឌលកែប្រែផ្សេង។[275] ជាលទ្ធផល ការពន្យារពេលនីតិវិធីប្តឹងឧទ្ធរណ៍តែងតែកើតមាន ដោយសារតែអវត្តមានជនជាប់ចោទ។[276] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាលើកជាសំណើថា កង្វះខាតផ្នែកទំនាក់ទំនងនេះអាចបន្ធូរបន្ថយបានតាមរយៈការរក្សាទុក និងការធ្វើបច្ចុប្បន្នភាពកំណត់ត្រាប្រសើរជាងនេះ រវាងតុលាការ និងមណ្ឌលកែប្រែនានា។

បន្ថែមពីលើនេះ អង្គការលីកាដូបានរាយការណ៍ថា អវត្តមានក្នុងសវនាការសាលាឧទ្ធរណ៍មានកាន់តែច្រើនឡើង។[277] ការដឹកជញ្ជូនជនជាប់ចោទទៅចូលរួមនីតិវិធីឧទ្ធរណ៍នៅរាជធានីភ្នំពេញមានភាពរអាក់រអួលដោយសារកង្វះថវិកាសម្រាប់យានជំនិះ និងប្រេងសាំង។ នៅក្នុងកាលៈទេសៈទាំងនេះ អ្នកជាប់ចោទដែលធ្វើដំណើរពីពន្ធនាគារដែលនៅឆ្ងាយៗត្រូវចំណាយថវិកាផ្ទាល់ខ្លួនដើម្បីបង្ហាញខ្លួននៅសវនាការសាលាឧទ្ធរណ៍ បើមិនដូច្នេះទេសវនាការនៅសាលាឧទ្ធរណ៍នឹងត្រូវបញ្ចប់ដោយបញ្ជាក់ថាអវត្តមានជនជាប់ចោទ។

---

[273] មាត្រា ៤៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[274] មាត្រា ៣៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[275] របាយការណ៍ម.ស.ម.ក ឆ្នាំ២០១៤ ដូចនឹងកំណត់សម្គាល់ខាងលើលេខ ៨១ ទំព័រ១២

[276] របាយការណ៍ម.ស.ម.ក ឆ្នាំ២០១៤ ដូចនឹងកំណត់សម្គាល់ខាងលើលេខ ៨១ ទំព័រ១២-១៣

[277] អង្គការលីកាដូ 2013 *អវត្តមាន ២០១៣៖ បច្ចុប្បន្នភាពស្តីពីវិបត្តិបញ្ជូនអ្នកទោសនៅកម្ពុជា និងសិទ្ធិប្តឹងឧទ្ធរណ៍* [របាយការណ៍អង្គការលីកាដូ ឆ្នាំ២០១៣] ចូលមើលថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៥ តាមរយៈតំណភ្ជាប់ https://www.licadho-cambodia.org/reports/files/179LICADHOBriefInAbsentia2013-English.pdf

នៅក្នុងរបាយការណ៍ឆ្នាំ២០១៣ របស់អង្គការលីកាដូ រកឃើញថា ជាទូទៅអ្នកជាប់ចោទមិនពេញចិត្តនឹងសំអាងលើសិទ្ធិមូលដ្ឋានរបស់ខ្លួន នៅក្នុងបណ្តឹងឧទ្ធរណ៍ព្រហ្មទណ្ឌ ដោយសារតែលក្ខខណ្ឌមិនល្អក្នុងពន្ធនាគារ។[278] ការរស់នៅរបស់ទណ្ឌិតក្នុងពន្ធនាគារពឹកផ្អែកយ៉ាងខ្លាំងទៅលើការផ្គត់ផ្គង់ពីខាងក្រៅ គឺពីក្រុមគ្រួសារ និងមិត្តភក្តិ ដោយសារតែកង្វះចំណីអាហារមានជីវជាតិ ទឹកស្អាត និងជាពិសេសការថែទាំសុខភាពនៅក្នុងពន្ធនាគារ។ ក្តីបារម្ភមួយទៀត ដែលទណ្ឌិតបានលើកឡើងគឺ ពន្ធនាគារមានសភាពណែនណាន់តាន់តាប់នៅរាជធានីភ្នំពេញ ហើយពួកគេខ្លាចត្រូវបញ្ជូនត្រលប់ទៅពន្ធនាគារដើមបន្ទាប់ពីសវនាការនៅសាលាឧទ្ធរណ៍រួច។ ដូច្នេះ ជាការសមហេតុផលដែលទណ្ឌិតចង់រស់នៅជិតក្រុមគ្រួសារ និងមិត្តភក្តិរបស់ខ្លួន ជាជាងធ្វើដំណើរមកភ្នំពេញដើម្បីចូលរួមក្នុងសវនាការសាលាឧទ្ធរណ៍។

នៅក្នុងរបាយការណ៍របស់អង្គការលីកាដូ ក៏បានកត់សម្គាល់ផងដែរថាជាការគួរឱ្យកោតសរសើរដែលរាជរដ្ឋាភិបាលទទួលស្គាល់ចំពោះកង្វះខាតខាងលើ និងការខំប្រឹងប្រែងកែប្រែបន្ថែម។[279] យើងមើលឃើញថាមានវឌ្ឍនភាពខ្លះដែរពីការបញ្ជូនទណ្ឌិតពីពន្ធនាគារតាមខេត្តដោយមិនយកកម្រៃ។ ក៏មានការកាត់បន្ថយបន្តិចបន្តួចនៃចំនួនសំណុំរឿងមិនទាន់ចាត់ការនៅក្នុងសវនាការសាលាឧទ្ធរណ៍ពី ១៧.១% នៅឆ្នាំ ២០១២ មកត្រឹម ១៥% នៅឆ្នាំ២០១៣។ ការណ៍ដែលរាជរដ្ឋាភិបាលបើកចំហចំពោះកិច្ចសហប្រតិបត្តិការជាមួយនឹងភាគីពាក់ព័ន្ធផ្សេងៗ ដូចជាការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការលីកាដូ ដើម្បីលើកកម្ពស់ស្ថានភាពសវនាការនៅសាលាឧទ្ធរណ៍ គឺពិតជាជំហានវិជ្ជមានមួយ។

ដើម្បីឆ្លើយតបទៅនឹងកង្វះខាតនៃសាលាឧទ្ធរណ៍ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃតុលាការដែលទើបនឹងអនុម័តឡើង នឹងបង្កើតឱ្យមានសាលាឧទ្ធរណ៍ នៅតាមខេត្តមួយចំនួន។[280]

### ខ. សិទ្ធិទទួលបានសំណងមានប្រសិទ្ធភាព

មាត្រា ២(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតម្រូវជាទូទៅឱ្យរដ្ឋភាគីផ្តល់សំណងមានប្រសិទ្ធភាពចំពោះការបំពាននឹងបទបញ្ញត្តិ។ សំណងជម្ងឺចិត្តចំពោះការរំលោភបំពានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលបណ្តាលមកពីការឆ្លោះឆ្លោយផ្នែកយុត្តិធម៌ ត្រូវបានធានា។ ការលើកឡើងនេះត្រូវបានគាំទ្រដោយមាត្រា ១៤(៦)

---

[278] របាយការណ៍អង្គការលីកាដូ ឆ្នាំ ២០១៣ កថាខណ្ឌ ១ និង ៦

[279] របាយការណ៍អង្គការលីកាដូ ឆ្នាំ ២០១៣ កថាខណ្ឌ ៧

[280] មាត្រា ៣៥ នៃច្បាប់រៀបចំតុលាការ

ដែលផ្តល់ជាសំណងជាក់លាក់ដល់បុគ្គលដែលទទួលរងពីការផ្តន្ទាទោសខុស។ ដោយអាស្រ័យតាមបទបញ្ញត្តិទាំងនេះ រដ្ឋភាគីមានកាតព្វកិច្ចអនុម័តច្បាប់ និងយន្តការរដ្ឋបាលតាមរយៈស្ថាប័នឯករាជ្យ និងមិនលំអៀងដើម្បីធានាការទទួលបានសំណងមានប្រសិទ្ធភាពសម្រាប់ការឆ្លោះឆ្លោយផ្នែកយុត្តិធម៌។[281] បន្ថែមពីលើដំណោះស្រាយជាក់លាក់ដែលតម្រូវឱ្យមាននៅក្នុងវិចារណកថាទូទៅលេខ៣១ របស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិចែងពីទម្រង់ជាក់លាក់នៃសំណងជម្ងឺចិត្តសមស្របស្តីពី "ការសងមកវិញ ការស្តារយុវនីតិសម្បទា និងវិធានការបំពេញចិត្ត ដូចជាការសុំទោសជាសាធារណៈ ការរំលឹកជាសាធារណៈ ការធានាពីការមិនប្រព្រឹត្តម្តងទៀត និងការផ្លាស់ប្តូរច្បាប់ និងការអនុវត្តដែលពាក់ព័ន្ធ ដូចជាផ្តល់យុត្តិធម៌ដល់ចារីនៃបទរំលោភសិទ្ធិមនុស្ស"។[282]

នៅកម្ពុជា សំណងពីការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាការបារម្ភបំផុត។ គ្មានបទបញ្ញត្តិច្បាប់ច្បាស់លាស់ណាមួយដែលដាក់ទោសដល់ការមិនបានធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ មាត្រា៣៩នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងយ៉ាងទូលាយថា ជនរងគ្រោះមានសិទ្ធិប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើបំពានច្បាប់របស់អង្គការរដ្ឋ និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ក្រោមក្រមនីតិវិធីព្រហ្មទណ្ឌមានបទបញ្ញត្តិមួយចំនួនចែងពីសំណង ក៏ប៉ុន្តែសម្រាប់តែការខូចខាតរដ្ឋប្បវេណី ឬជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ។ នេះហាក់ដូចថាក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់ទម្រង់សំណងតែមួយប៉ុណ្ណោះ ដែលនេះជាការរួចខ្លួនជនជាប់ចោទ ប្រសិនបើសាលាឧទ្ធរណ៍រកឃើញថាជនជាប់ចោទគ្មានទោស។[283] ហេតុនេះការទទួលបានសំណងមានប្រសិទ្ធភាពសម្រាប់ការបំពានសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌គឺស្ទើរតែមិនអាចធ្វើទៅរួចក្នុងលក្ខខណ្ឌដែលមានបទបញ្ញត្តិ និងយន្តការដែលមិនច្បាស់លាស់ក្នុងការធានាការទទួលស្គាល់ពេញលេញនៃសិទ្ធិជាមូលដ្ឋានទាំងនោះ។

សំណុំរឿងរបស់លោក ប៊ិន សំណាង ទល់នឹងលោកសុខ សំអឿន គឺជាឧទាហរណ៍យ៉ាងជាក់ច្បាស់នៃបញ្ហាទាំងនេះ។ បុរសទាំងពីរនេះត្រូវបានចោទប្រកាន់ពីបទសម្លាប់លោក ជា វិជ្ជា ដែលជាប្រធានសហជីពកម្មករ កាលពីមួយទសវត្សរកន្លងទៅ។ បុរសទាំងពីររូបនេះត្រូវ

[281] អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ៣២ ដូចកំណត់សម្គាល់ខាងលើលេខ ៨៥ កថាខណ្ឌ ៥២

[282] អត្ថាធិប្បាយទូទៅរបស់មជ្ឈមណ្ឌលសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលេខ៣១ ដូចកំណត់សម្គាល់ខាងលើលេខ ១០ កថាខណ្ឌ ១៦

[283] មាត្រា ៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បានរកឃើញថាមានទោស និងផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចំនួន ២០ ឆ្នាំ។ ពួកគេទាំងពីរបានជាប់ពន្ធនាគារអស់រយៈពេល៦ឆ្នាំមុន ត្រូវបានតុលាការកំពូលលើកលែងទោសនៅឆ្នាំ២០១៣។ ក៏ប៉ុន្តែ បុរសទាំងពីរគ្មាននរណាម្នាក់ទទួលបានសំណងជម្ងឺចិត្ត ហើយក្រុមសិទ្ធិមនុស្សទាមទារថាប្រព័ន្ធយុត្តិធម៌ត្រូវ "ទទួលខុសត្រូវសីលធម៌" សម្រាប់ការឆ្លោះឆ្លាយផ្នែកយុត្តិធម៌នេះ។[284]

បន្ថែមពីលើនេះ នៅក្នុងសំណុំរឿងរវាង រដ្ឋអាជ្ញា ទល់នឹងលោក តាំង ហ្គិចអៀវ ឬ ស្គាល់ថា ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សាលាជំនុំជម្រះទទួលស្គាល់ថា ឌុច ត្រូវបានឃុំខ្លួនដោយខុសច្បាប់ដោយគ្មានការជំនុំជម្រះអស់រយៈពេល ៨ឆ្នាំ លើសពីអាជ្ញា-យុកាលកំណត់ មុននឹងត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។[285] ដូច្នេះ នៅពេលផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិតទៅលើ ឌុច សាលាជំនុំជម្រះបានបន្ថយទោសរយៈពេល៥ឆ្នាំជាសំណងដល់ការឃុំខ្លួន ឌុច ដោយខុសច្បាប់ និងការឃុំខ្លួនបណ្តោះអាសន្ន។ ប៉ុន្តែតុលាការកំពូលបានបដិសេធសេចក្តីសម្រេចនេះ ដោយមិនរាប់បញ្ចូលក្នុងការផ្តន្ទាទោសទេ។ ករណីដែលសាលាជំនុំជម្រះសម្រេចថាការឃុំខ្លួន ឌុច ខុសច្បាប់មិនត្រូវបានស្វាគមន៍ដោយចៅក្រមខ្មែរ និងមិនត្រូវបានប្រើប្រាស់ជាឧទាហរណ៍សម្រាប់មេធាវីក្នុងការតវ៉ាក្តីឱ្យមានការផ្តន្ទាទោស និងសំណងសមរម្យនោះទេ។

## ៤. សេចក្តីបញ្ចប់

ជំពូកនេះផ្តល់ជាសេចក្តីអធិប្បាយសង្ខេបអំពី សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅក្នុងច្បាប់ និងការអនុវត្តនៅកម្ពុជាដល់អ្នកអាន ដោយប្រៀបធៀបការគោរពសិទ្ធិនេះនៅកម្ពុជាជាមួយនឹងស្តង់ដារដែលកំណត់ត្រឹមច្បាប់អន្តរជាតិនៅក្នុងសន្ធិសញ្ញា និងបទ-ដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

នេះជាទិដ្ឋភាពមូលដ្ឋាននៃការលើកកម្ពស់នីតិរដ្ឋដែលជនត្រូវចោទទាំងអស់មានសិទ្ធិទទួលបានការជំនុំជម្រះស្មើភាព និងយុត្តិធម៌ ដោយមិនគិតពីស្ថានទម្ងន់ទោសនៃបទល្មើស។ ការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវការការប្រកាន់ខ្ជាប់ទៅនឹងវិធាននីតិវិធី និងការអនុវត្តមួយសំណុំដ៏ស្មុគស្មាញដើម្បីស្វែងរកភាពពិត។ នេះមិនចោទជាបញ្ហាចំពោះ

---

[284] May, T & Seiff, A 2013 "Scapegoat Killers' Acquitted" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី ២៦ ខែកញ្ញា ចូលមើលថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៥ តាមរយៈតំណភ្ជាប់ http://www.phnompenhpost.com/national/scapegoat-'killers'-acquitted

[285] សូមមើលព័ត៌មានទូទៅសង្ខេបនៃសំណុំរឿងលេខ ០០១ របស់អ.វ.ត.ក តាមរយៈ http://www.eccc.gov.kh/en/case/topic/1 ចូលមើលថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៥

លទ្ធផលចុងក្រោយនៃការជំនុំជម្រះនោះទេ គឺអាស្រ័យទៅលើការគោរពនីតិវិធីទាំងនោះ។ ប្រសិនបើនីតិវិធីទាំងនោះមិនត្រូវបានគោរព វាជាការបង្កាប់បញ្ហាដែលបុគ្គលបានទទួលសំណង មានប្រសិទ្ធភាព។

ទោះបីជាសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបានការពារជាទូទៅ នៅកម្ពុជា ប៉ុន្តែមានភាពមិនគ្រប់គ្រាន់ នៅក្នុងការអនុវត្តច្បាប់ទាំងនោះ នៅក្នុងករណីជាក់ស្តែង។ បន្ថែមពីនេះ ការទទួលបានសំណងដែលមានប្រសិទ្ធភាពនៅពេលដែលមានការរំលោភសិទ្ធិ ក្រៅពីតាមរយៈការលើកលែងទោសដល់ជនល្មើស គឺគ្មានអ្វីផ្សេងទាំងនៅក្នុងច្បាប់ និងនៅក្នុងការអនុវត្ត។ យើងសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជានឹងដោះស្រាយបញ្ហានេះដោយត្រួតពិនិត្យក្រមនីតិវិធីព្រហ្មទណ្ឌ និងគិតគូរពីការអនុម័ត ឬបន្ថែមបទបញ្ញត្តិចាំបាច់ ក្នុងការធានាការទទួលបានសំណងដែលមានប្រសិទ្ធភាព។

ក្នុងនាមជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយកម្ពុជា មានភារកិច្ចបង្កើនវឌ្ឍនភាពក្នុងការធានាការទទួលស្គាល់ពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាពិសេសលើកកម្ពស់ការយល់ដឹង និងកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល និងកម្មវិធីនៅសាលារៀន។ ការពិតដែលការអប់រំពីការជំនុំជម្រះដោយយុត្តិធម៌នៅសាលាច្បាប់ និងសម្រាប់មន្ត្រីតុលាការ និងនគរបាលនៅមានកម្រិត មានន័យថាទស្សនៈស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជារឿងចម្លែកសម្រាប់មន្ត្រីភាគច្រើនដែលធ្វើការនៅក្នុងវិស័យតុលាការ វិស័យអប់រំ និងសហគមន៍ដែលនៅឆ្ងាយៗ។ យើងសង្ឃឹមថា មេរៀនពី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចបន្សល់ទុកជាកេរតំណែលសម្រាប់បង្កើនការយល់ដឹង និងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដល់ប្រជាពលរដ្ឋខ្មែរ ជាពិសេសសម្រាប់អ្នកដែលធ្វើការនៅក្នុងវិស័យយុត្តិធម៌។ ប្រសិនបើ កម្ពុជាយកចិត្តទុកដាក់អំពីការជំរុញប្រសិទ្ធភាព និងនីត្យានុកូលភាព និងការបង្កើនទំនុកចិត្តសាធារណៈ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជាត្រូវតែគោរព និងធានាសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

# សកម្មភាពរបស់គណៈមេធាវី

# ១.ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ១.១.ទំនាក់ទំនងជាតិ

លោកមេធាវី សួន វិសាល ចុះសួរសុខទុក្ខនាយទាហាន និងពលទាហាននៅខេត្តព្រះវិហារ

នាថ្ងៃសុក្រ ១កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី និងអង្គភាពប្រឆាំងអំពើពុករលួយដឹកនាំដោយឯកឧត្តម ទូច ស៊ុនណារី បានចុះសួរសុខទុក្ខនាយទាហាននិងពលទាហានកងពលធំ អន្តរាគមន៍លេខ៣ ដែលឈរជើងនៅ ខេត្តព្រះវិហារ។

ក្នុងដំណើរចុះសួរសុខទុក្ខនេះ ប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី បាន បរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីចែករំលែកសុខទុក្ខ របស់នាយទាហាន និងពលទាហានកងពលធំ អន្តរាគមន៍លេខ៣ ក្នុងបុព្វហេតុការពារជាតិ ទឹកដី និងប្រជាជន។







## លោកមេធាវី សួន វិសាល ជួបពិភាក្សាការងារមួយតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

នាព្រឹកថ្ងៃអង្គារ ១១ រោច ខែចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០១៩ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា អមដោយអគ្គលេខាធិការ និង សមាជិកក្រុមប្រឹក្សាបានដឹកនាំគណៈប្រតិភូចូលជួបពិភាក្សាការងារជាមួយក្រុមការងារអគ្គនាយកដ្ឋានថវិកាដែលដឹកនាំដោយអគ្គនាយក អគ្គនាយករង និងសហការីតំណាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នៅក្នុងកិច្ចពិភាក្សានេះ លោកប្រធានគណៈមេធាវីបានធ្វើបទអន្តាគមន៍លើ សមិទ្ធិផលរបស់គណៈមេធាវី ជាពិសេស ការការពារជនក្រីក្រ។ សមភាគីភាគីទាំងពីរបានជជែក និងផ្លាស់ប្តូរយោបល់ជាវិជ្ជមានទៅលើខ្លឹមសារសំខាន់ៗ ពាក់ព័ន្ធនឹងថវិកាសម្រាប់ជួយជនក្រីក្រដែលមានចំនួនរឿងក្តីមកពឹងពាក់គណៈមេធាវីចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ជាលទ្ធផលតំណាងក្រសួងបានទទួលយកសំណូមពររបស់គណៈមេធាវីពាក់ព័ន្ធនឹងកង្វះថវិកាសម្រាប់ជួយជនក្រីក្រនេះសម្រាប់យកទៅពិចារណា។







### ១.២.ទំនាក់ទំនងអន្តរជាតិ

#### លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជាបានទទួលជួប និងសម្តែងការគួរសមជាមួយ ប្រធានគណៈមេធាវី និងគណៈប្រតិភូអម នៃខេត្ត GUANGDONG របស់សាធារណរដ្ឋប្រជាមានិតចិន

នាព្រឹកថ្ងៃចន្ទ ១០ រោច ខែចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានទទួលជួប និងសម្តែងការគួរសមជាមួយ ប្រធានគណៈមេធាវី និងគណៈប្រតិភូអម នៃខេត្ត GUANGDONG របស់សាធារណរដ្ឋប្រជាមានិតចិន។

នៅក្នុងការទទួលជួប និងសម្តែងការគួរសមនេះ គណៈមេធាវីទាំងពីរ បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការរវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈមេធាវីនៃខេត្ត GUANGDONG របស់សាធារណរដ្ឋប្រជាមានិតចិន។ នៅក្នុងកិច្ចពិភាក្សានេះ លោកប្រធានគណៈមេធាវីកម្ពុជាបានស្នើដល់ ប្រធានគណៈមេធាវី GUANGDONG របស់សាធារណរដ្ឋប្រជាមានិតចិនឲ្យមានការបណ្តុះបណ្តាលលើច្បាប់អន្តរជាតិ ផ្លាស់ប្តូរបទពិសោធន៍ និងសិក្ខាសាលារបស់គណៈមេធាវីទាំងពីរ។

ជាការកត់សម្គាល់ នៅក្នុងកិច្ចពិភាក្សានេះ សមភាគីទាំងពីរបានឯកភាពក្នុងការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក តាមរយៈការបញ្ជូនគណៈប្រតិភូទៅទស្សនកិច្ចសិក្សាពីគណៈមេធាវីរបស់ព្រះរាជាណាចក្រកម្ពុជា និងគណៈមេធាវីនៃខេត្ត GUANGDONG របស់សាធារណរដ្ឋប្រជាមានិតចិន និងផែនការអំពីកិច្ចសហប្រតិបត្តិការ រវាងសមភាគីទាំងពីរ ដើម្បីរៀបចំពិធីចុះអនុស្សារណៈយោគយល់នាពេលអនាគត។






គណៈមេធាវី

## លោកមេធាវីសួន វិសាល ប្រធានគណៈមេធាវីបានដឹកនាំប្រតិភូសមាជិកគណៈមេធាវីដើម្បីប្រជុំ និងពិភាក្សាការងារជាមួយប្រធានតុលាការកំពូលសឹង្ហបុរី

កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ នៅប្រទេសសឹង្ហបុរី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូគណៈមេធាវី ចូលរួមប្រជុំ និងពិភាក្សាការងារជាមួយនឹងតុលាការកំពូលប្រទេសសឹង្ហបុរី ដើម្បីពង្រឹងទំនាក់ទំនង និងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងគណៈមេធាវីកម្ពុជា និងសឹង្ហបុរី។ ជាលទ្ធផលកិច្ចប្រជុំទទួលបានជោគជ័យ ប្រកបដោយផ្លែផ្កា តាមការរំពឹងទុក។



## កិច្ចប្រជុំរវាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមួយមន្ត្រីបេសកកម្ម UN-ESCAP

នៅព្រឹកថ្ងៃ១១កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានទទួលជួប និងពិភាក្សាការងារជាមួយមន្ត្រីបេសកកម្ម UN-ESCAP អំពីប្រធានបទស្តីពី ការសម្រួលពាណិជ្ជកម្មឆ្លងព្រំដែនដោយមិនចាំបាច់ប្រើប្រាស់ក្រដាសស្នាមក្នុងប្រទេសអភិវឌ្ឍន៍តិចតួច។





## ២.សកម្មភាពបុណ្យចូលឆ្នាំខ្មែរ

### ពិធីសូត្រមន្ត ប្រោសព្រំ លើករាសី ក្នុងឱកាសពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ

នាព្រឹកថ្ងៃពុធ ០៦កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៩ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានប្រារព្ធពិធីសូត្រមន្ត ប្រោសព្រំ លើករាសី ក្នុងឱកាសពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣ គ.ស. ២០១៩ ។

ពិធីសូត្រមន្ត ប្រោសព្រំ លើករាសី ក្នុងឱកាសពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិនេះ មានការចូលរួម ដោយលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី រួមទាំងសមាជិក សមាជិកាក្រុមប្រឹក្សាគណៈមេធាវី សមាជិកសមាជិកាគណៈមេធាវី និងបុគ្គលិកគណៈមេធាវី។







## ៣.កិច្ចប្រជុំប្រចាំខែ

### កិច្ចប្រជុំបុគ្គលិកគណៈមេធាវីប្រចាំខែ និងរៀបចំផែនការសម្រាប់ មហាសន្និបាត

នៅព្រឹកថ្ងៃពុធ ១០កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការបានដឹកនាំកិច្ចប្រជុំបុគ្គលិកដើម្បីត្រួតពិនិត្យការងារប្រចាំខែ និងលើកទិសដៅការងារសម្រាប់រៀបចំមហាសន្និបាតប្រចាំឆ្នាំ២០១៩។

កិច្ចប្រជុំនេះមានការចូលរួមពីបុគ្គលិកគ្រប់នាយកដ្ឋាន រួមទាំងអគ្គលេខាធិការរងផងដែរ។




គណៈមេធាវី
នៃព្រះរាជាណាចក្រកម្ពុជា


គណៈមេធាវី
នៃព្រះរាជាណាចក្រកម្ពុជា

# គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

# នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោកមេធាវី កែ ប៊ុនធឿន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី ម៉ៃ ច័ន្ទសត្យា | អនុប្រធាននាយកដ្ឋាន |
| ៣-លោក ឃឹម ច័ន្ទធឿន | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី វ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ |
| ៥-លោក ខន សុខេង | ប្រធានការិ.ស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ |
| ៦-លោក ថា ប៊ុនថៃ | ប្រធានការិ.ព័ត៌មានវិទ្យា |
| ៧- លោក ស្រេង សីហាប៊ុននុត | ជំនួយការ ការិ.ព័ត៌មានវិទ្យា |
| ៨- កញ្ញា តាន់ ចរណៃ | បណ្ណារក្ស |
| ៩-លោកមេធាវី ហួត សុវណ្ណ | មន្ត្រីលិកស្ម័គ្រចិត្ត |
| ១០-លោក ជុំ ប៊ុនណារាយ | មន្ត្រីលិកហាត់ការ |
| ១១-លោក នួន វ៉ា | មន្ត្រីលិកហាត់ការ |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លោកមេធាវី សារិន ដេណូវ៉ា

DFDL

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា